# ព្រះ
# ត្រៃបិដកបាឡី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# វិនយបិដក បរិវារ
# បឋមភាគ
# ១២



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# Vinayapiṭaka Parivāra

## Paṭhamabhāga

## 12

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed and donated for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website:http://www.budaedu.org

**This book is strictly for free distribution, it is not for sale.**

**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# សេចក្តីណែនាំក្នុងការអាន

*១- ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។*

*ឧទាហរណ៍*

*-ពាក្យខ្មែរៈ* **សម្+ល** *ក្នុងពាក្យនេះ ព្យញ្ជនៈ* **ល** *គឺជាជើងរបស់ព្យញ្ជនៈ* **ម** *ដូច្នេះពាក្យនេះគឺ* **សម្ល** *។*

*-ពាក្យបាលីៈ* **តស្+ស** *គឺ* **តស្ស** *។*

*២- ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ* (**ជួន-ណាត**) *ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។*

*៣- ចំពោះ* **សង្ខឹកប្រាប់ពាក្យខុស-ត្រូវ** *ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។*

# វិនយបិដក បរិវារៈ

## បឋមភាគ

## ១២

## មហាវិភង្គ សោឡសមហាវារៈ ភិក្ខុនីវិភង្គ

## សោឡសមហាវារៈ សមុដ្ឋានសីសសង្ខេប

## កតិបុច្ឆាវារៈ និង វីសតិវារៈ

# វិនយបិដកេ បរិវារោ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## មហាវិភង្គេ សោឡស មហាវារា

[១] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមំ បារាជិកំ កត្ថ បញ្ញត្តំ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តិ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តិ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នំ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ

# វិនយបិដក បរិវារៈ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ*

# មហាវិភង្គ មហាវារៈ ១៦

[១] *សួរថា បឋមបារាជិក ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ (នូវកាលនៃការបញ្ញត្តសិក្ខាបទ) ឃើញច្បាស់ (នូវប្រយោជន៍ ១០ យ៉ាងនៃការបញ្ញត្តសិក្ខាបទ) ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ព្រោះរឿងរ៉ាវដូចម្តេច ។ (បញ្ញត្តិ ៩ យ៉ាងគឺ) បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ សព្វត្ថប្បញ្ញត្តិ ១ បទេសប្បញ្ញត្តិ ១ សាធារណប្បញ្ញត្តិ ១ អសាធារណប្បញ្ញត្តិ ១ ឯកតោបញ្ញត្តិ ១ ឧភតោបញ្ញត្តិ ១ មានក្នុងបឋមបារាជិកនោះដែរឬទេ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ បឋមបារាជិក ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ បណ្តាវិបត្តិ ៤ យ៉ាង បឋមបារាជិកចាត់ជាអ្វី ។ បណ្តាកងនៃអាបត្តិទាំង ៧ បឋមបារាជិកចាត់ចូលក្នុងកងអាបត្តិណា ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង បឋមបារាជិកតាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ បណ្តាអធិករណ៍ទាំង ៤ យ៉ាង*

អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោ កឹ តត្ថ បាតិមោក្ខំ កឹ តត្ថ អធិប្បាតិមោក្ខំ កា វិបត្តិ កា សម្បត្តិ កា បដិបត្តិ ។ កតិ អត្ថវសេ បដិច្ច ភគវតា បឋមំ បារាជិកំ បញ្ញត្តំ ។ កេ សិក្ខន្តិ ។ កេ សិក្ខិតសិក្ខា ។ កត្ថ ឋិតំ ។ កេ ធារេន្តិ ។ កស្ស វចនំ ។ កេនាភតន្តិ ។

[២] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សុទិន្នំ កលន្ទបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សុទិន្នោ កលន្ទបុត្តោ បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវិ តស្មឹ

បឋមបារាជិក ចាត់ចូលក្នុងអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ យ៉ាង បឋមបារាជិក រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ អ្វីជាវិន័យក្នុងបឋមបារា-ជិកនោះ អ្វីជាអភិវិន័យក្នុងបឋមបារាជិកនោះ អ្វីជាបាតិមោក្ខក្នុងបឋមបា-រាជិកនោះ អ្វីជាអធិប្បាតិមោក្ខក្នុងបឋមបារាជិកនោះ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ អ្វីជាសេចក្តីប្រតិបត្តិ (ក្នុងបឋមបារាជិកនោះ) ។ បឋមបារាជិក ព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ជនពួកណា សិក្សា ។ ជនពួកណា ដែលមានសិក្ខាសិក្សាហើយ ។ បឋមបារាជិក ឋិតនៅក្នុងជនពួកណា ។ ជនពួកណាទ្រទ្រង់ទុក ។ បឋមបារាជិក ជាពាក្យរបស់នរណា ។ នរណានាំមក ។

[២] សួរថា បឋមបារាជិក ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ទ្រង់បញ្ញត្តក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវសុទិន្នភិក្ខុជាកូននៃកលន្ទសេដ្ឋី ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលសុទិន្នភិក្ខុជាបុត្ត នៃកលន្ទសេដ្ឋីសេពមេថុនធម្មនឹងបុរាណទុតិយិកា

វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តី-តិ ។ ឯកា បញ្ញត្តិ ទ្វេ អនុប្បញ្ញត្តិយោ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។ សាធារណប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តី-តិ ។ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទាន-បរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ទុតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ

(ភរិយារបស់ខ្លួនពីដើម) ។ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ មានក្នុងបឋមបារាជិកនោះដែរឬទេ ។ មានតែបញ្ញត្តិ[១] ១ និងអនុប្បញ្ញត្តិ[២] ២ ឯអនុប្បន្នប្បញ្ញត្តិ[៣] មិនមានក្នុងបឋមបារាជិកនោះទេ ។ បឋមបារាជិកនោះ ជាសព្វត្ថប្បញ្ញត្តិ[៤] ឬជាបទេសប្បញ្ញត្តិ[៥] ។ ជាសព្វត្ថប្បញ្ញត្តិ ។ បឋមបារាជិកនោះ ជាសាធារណប្បញ្ញត្តិ[៦] ឬជាអសាធារណប្បញ្ញត្តិ[៧] ។ ជាសាធារណប្បញ្ញត្តិ ។ បឋមបារាជិកនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោ-បញ្ញត្តិ[៨] ។ ជាឧភតោបញ្ញត្តិ ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង បឋម-បារាជិកដាក់ចុះក្នុងឧទ្ទេសណារាប់បញ្ចូលក្នុងឧទ្ទេសណា ។ បឋមបារាជិកដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ បឋមបារាជិកមកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ២ ។ បណ្ដាវិបត្តិ ៤ យ៉ាង

---

១ អដ្ឋកថាថា សេចក្ដីបញ្ញត្តថា ភិក្ខុណាមួយសេពមេថុនធម្ម ត្រូវបារាជិកគ្មានសំវាសនេះ ជាបញ្ញត្តិ ១ ។ ២ ពាក្យថា ភិក្ខុសេពមេថុនធម្ម ដោយហោចទៅ សូម្បីតែនឹងសត្វតិរច្ឆានក្ដី មិនពោលលាសិក្ខាក្ដី ទាំងនេះចាត់ជា អនុប្បញ្ញត្តិពីរ ។ ៣ សេចក្ដីបញ្ញត្តិមុនកើតរឿងឡើងដូចជាទ្រង់បញ្ញត្តិគរុធម៌ ៨ ដល់ពួកភិក្ខុនី នេះចាត់ជាអនុប្បន្នប្បញ្ញត្តិ ។ នេះមិនមានក្នុងទីឯទៀតទេ ។ ៤ សិក្ខាបទដែលទ្រង់បញ្ញត្តទូទៅ ទាំងមជ្ឈិមបទេស ទាំងបច្ចន្តជនបទ ហៅថាសព្វត្ថប្បញ្ញត្តិ ។ ៥ សិក្ខាបទដែលទ្រង់បញ្ញត្តហាមក្នុងមជ្ឈិមបទេសមាន ៤ សិក្ខាបទគឺឧបសម្បទាដោយគណៈសង្ឃ មានភិក្ខុជាវិន័យធរជាគម្រប់ ៥ ស្បែកជើង ៤ ជាន់ ស្រង់ទឹកជានិច្ចកម្រាលស្បែក ហៅថា បទេសប្បញ្ញត្តិ ។ ៦ សិក្ខាបទដែលទ្រង់បញ្ញត្តទូទៅទាំងភិក្ខុទាំងភិក្ខុនី ហៅថា សាធារណប្បញ្ញត្តិ ។ ៧ សិក្ខាបទដែលទ្រង់បញ្ញត្តចំពោះតែភិក្ខុ ឬចំពោះតែភិក្ខុនីម្យ៉ាង ហៅថា អសាធារណប្បញ្ញត្តិ ។ ៨ ឯកតោបញ្ញត្តិ មានសេចក្ដីដូចអសាធារណប្បញ្ញត្តិ ឧភតោបញ្ញត្តិ មានសេចក្ដីដូចសាធារណប្បញ្ញត្តិ ។

កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ ចារាជិកាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតីតិ ។ ទ្វីហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច បដិញ្ញាតករណេន ច ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោតិ ។ បញ្ញត្តិ វិនយោ វិភត្តិ អភិវិនយោ ។ កឹ តត្ថ ចាតិមោក្ខំ កឹ តត្ថ អធិប្បាតិមោក្ខន្តិ ។ បញ្ញត្តិ ចាតិមោក្ខំ វិភត្តិ អធិប្បាតិមោក្ខំ ។ កា វិបត្តីតិ ។ អសំវរោ វិបត្តិ ។ កា សម្បត្តីតិ ។ សំវរោ សម្បត្តិ ។ កា បដិបត្តីតិ ។ ន ឯវរូបំ ករិស្សាមីតិ យាវជីវំ អាចាណាកោដិកំ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។

បឋមបារាជិក ចាត់ជាវិបត្តិអ្វី ។ ចាត់ជាសីលវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ បឋមបារាជិក ចាត់ចូលក្នុងកងនៃអាបត្តិណា ។ ចាត់ចូលក្នុងកងនៃអាបត្តិបារាជិក ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង បឋមបារាជិកតាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាទេ ។ បណ្តាអធិករណ៍ទាំង ៤ យ៉ាង បឋមបារាជិក ចាត់ជាអធិករណ៍ណា ។ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ យ៉ាង បឋមបារាជិករម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ រម្ងាប់ដោយសមថៈពីរយ៉ាង គឺដោយសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ ។ អ្វីជាវិន័យក្នុងបឋមបារាជិកនោះ អ្វីជាអភិវិន័យក្នុងបឋមបារាជិកនោះ ។ បញ្ញត្តិ ជាវិន័យ វិភត្តិ (បទភាជនៈ) ជាអភិវិន័យក្នុងបឋមបារាជិកនោះ ។ អ្វីជាបាតិមោក្ខក្នុងបឋមបារាជិកនោះ អ្វីជាអធិប្បាតិមោក្ខក្នុងបឋមបារាជិកនោះ ។ បញ្ញត្តិជាបាតិមោក្ខ វិភត្តិ (បទភាជនៈ) ជាអធិប្បាតិមោក្ខ ។ អ្វីជាវិបត្តិ ។ សេចក្តីមិនសង្រួម ជាវិបត្តិ ។ អ្វីជាសម្បត្តិ ។ សេចក្តីសង្រួម ជាសម្បត្តិ ។ អ្វីជាសេចក្តីប្រតិបត្តិ (ក្នុងបឋមបារាជិកនោះ) ។ ភិក្ខុសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយដរាបអស់ជីវិត មានជីវិតជាទីបំផុតដោយគិតថា អាត្មាអញនឹងមិនធ្វើអំពើមានសភាពយ៉ាងនេះទេ (នេះជាសេចក្តីប្រតិបត្តិ) ។

៤

មហាវិភង្គេ សោឡស មហាវារា បឋមបារាជិកំ

កតិ អត្ថវសេ បដិច្ច ភគវតា បឋមំ បារាជិកំ បញ្ញត្តន្តិ ។ ទស អត្ថវសេ បដិច្ច ភគវតា បឋមំ បារាជិកំ បញ្ញត្តំ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ កេ សិក្ខន្តីតិ ។ សេក្ខា ច បុថុជ្ជនកល្យាណកា ច សិក្ខន្តិ ។ កេ សិក្ខិតសិក្ខាតិ ។ អរហន្តោ សិក្ខិតសិក្ខា ។ កត្ថ ឋិតន្តិ ។ សិក្ខាកាមេសុ ឋិតំ ។ កេ ធារេន្តីតិ ។ យេសំ វត្តតិ តេ ធារេន្តិ ។ កស្ស វចនន្តិ ។ ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ កេនាភតន្តិ ។ បរម្បរាភតំ[១] ៗ

១ ឱ. ម. បរំបរាភតំ ។

បឋមបារាជិក ព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មាន ។ បឋមបារាជិក ព្រះមានព្រះភាគទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីនៅសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនអៀនខ្មាស ១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរារាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតាំងនៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។ ជនពួកណាតែងសិក្សា ។ ពួកសេក្ខៈនិងពួកកល្យាណបុថុជ្ជនតែងសិក្សា ។ ជនពួកណាដែលមានសិក្ខាសិក្សាហើយ ។ ពួកព្រះអរហន្តមានសិក្ខាសិក្សាហើយ ។ បឋមបារាជិកនោះ ឋិតនៅក្នុងពួកជនណា ។ ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល (អ្នកប្រាថ្នាការសិក្សា) ។ ជនពួកណារមែងទ្រទ្រង់ទុក ។ បឋមបារាជិកប្រព្រឹត្តទៅដល់ជនពួកណា ជនពួកនោះរមែងទ្រទ្រង់ទុក[១] ។ បឋមបារាជិកជាពាក្យរបស់អ្នកណា ។ ជាពាក្យរបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ។ អ្នកណានាំមក ។ ព្រះថេរៈ (ដូចមាននាមតទៅនេះ) នាំត ៗ គ្នាមក ។

---

១ អដ្ឋកថា ថា ពាក្យថាទ្រទ្រង់ទុក គឺចាំស្ទាត់ទាំងបាលីទាំងអដ្ឋកថា នៃបឋមបារាជិក ។

[៣] ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលីបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ[១] ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ[២]
ភទ្ទនាមោ ច បណ្ឌិតោ
ឯតេ នាគា មហាបញ្ញា
ជម្ពុទីបា ឥធាគតា
វិនយំ តេ វាចយឹសុ
បិដកំ តម្ពបណ្ណិយា
និកាយេ បញ្ច វាចេសុំ
សត្ត ចេវ បករណេ ។
តតោ អរិដ្ឋោ មេធាវី
តិស្សទត្តោ ច បណ្ឌិតោ
វិសារទោ កាឡសុមនោ

---

១ ជម្ពូសិរិវ្ហយេតិ កត្ថចិ ទិស្សតិ ។ ២ ឱ. ឧត្តិយោ សម្ពលោ តថា ។ ម. ឧដ្ដិយោ សម្បលោ តថា ។

[៣] ព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១ និងព្រះមោគ្គលីបុត្ត ១ អង្គទៀត ជាគម្រប់ ៥ ព្រះថេរៈទាំងនេះឋិតនៅក្នុងទ្វីបមានឈ្មោះថា ជម្ពូ ដ៏មានសិរី ។ តអំពីព្រះថេរៈទាំងនោះមក ព្រះមហាមហិន្ទ ១ ព្រះឥដ្ដិយៈ ១ ព្រះឧត្តិយៈ ១ ព្រះសម្ពលៈ ១ ព្រះភទ្ទនាមជាបណ្ឌិត ១ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន មកអំពីជម្ពូទ្វីប ហើយបានមកនៅក្នុងលង្កាទ្វីប ព្រះថេរៈទាំងនោះ បានបង្រៀនវិន័យ-បិដក បានបង្រៀននិកាយទាំង ៥ គម្ពីរ ព្រះអភិធម្មទាំង ៧ គម្ពីរ ក្នុងតម្ពបណ្ណិទ្វីប (កោះលង្កា) ។ តអំពីនោះមក (មានព្រះថេរៈច្រើនអង្គទៀតគឺ) ព្រះអរិដ្ឋៈជាអ្នកមានប្រាជ្ញា ១ ព្រះតិស្សទត្តជាបណ្ឌិត ១ ព្រះកាឡសុមនត្ថេរជាអ្នកក្លៀវក្លា ១

**៧**

មហាវិភង្គេ សោឡស មហាវារា ថេរនាមានិ

ថេរោ ច ទីឃនាមកោ
ទីឃសុមនោ ច បណ្ឌិតោ
បុនរេវ កាឡសុមនោ
នាគត្ថេរោ ច ពុទ្ធរក្ខិតោ
តិស្សត្ថេរោ ច មេធាវី
ទេវត្ថេរោ[១] ច បណ្ឌិតោ
បុនរេវ សុមនោ មេធាវី
វិនយេ ច វិសារទោ
ពហុស្សុតោ ចូឡនាគោ
គជោវ ទុប្បធំសិយោ
ធម្មបាលិតនាមោ ច
រោហណោ សាធុបូជិតោ
តស្ស សិស្សោ មហាបញ្ញោ
ខេមនាមោ តិបេដកី
ទីបេ តារការាជាវ
បញ្ញាយ អតិរោចតិ[២]

---

១ ម. រេវត្ថេរោ ។ ២ ឱ. ម. អតិរោចថ ។

មហាវិភង្គ មហាវារៈ ១៦ នាមរបស់ព្រះថេរៈទាំងឡាយ

ព្រះទីឃនាមកៈ ១ ព្រះទីឃសុមនៈ ជាបណ្ឌិត ១ ព្រះកាឡសុមនៈ ១ ព្រះនាគត្ថេរ ១ ព្រះពុទ្ធរក្ខិត ១ ព្រះតិស្សត្ថេរជាអ្នកមានប្រាជ្ញា ១ ព្រះទេវត្ថេរជាបណ្ឌិត ១ ព្រះសុមនៈមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ ១ ព្រះចូឡនាគជាពហុស្សូត ១ ព្រះគជត្ថេរជាអ្នកកំចាត់បង់ទោសដ៏អាក្រក់ ១ ព្រះថេរៈឈ្មោះធម្មបាលិត ដែលគេបូជាហើយដោយប្រពៃក្នុងរោហណជនបទ ១ សិស្សរបស់ព្រះធម្មបាលិតនោះឈ្មោះខេមៈ ជាអ្នកមានប្រាជ្ញាច្រើន ទ្រទ្រង់ព្រះត្រៃបិដករុងរឿងដោយបញ្ញាក្នុងទ្វីបដូចព្រះចន្ទ ១ ព្រះថេរៈឈ្មោះ

ឧបតិស្សោ ច មេធាវី
បុស្សទេវោ មហាគណី
បុនរេវ សុមនោ មេធាវី
បុប្ផនាមោ ពហុស្សុតោ
មហាកថី មហាសីវោ
បិដកេ សព្វត្ថ កោវិទោ
បុនរេវ ឧបាលិ មេធាវី
វិនយេ ច វិសារទោ
មហានាគោ មហាបញ្ញោ
សទ្ធម្មវំសកោវិទោ
បុនរេវ អភយោ មេធាវី
បិដកេ សព្វត្ថ កោវិទោ
តិស្សត្ថេរោ ច មេធាវី
វិនយេ ច វិសារទោ
តស្ស សិស្សោ មហាបញ្ញោ
បុស្សនាមោ[១] ពហុស្សុតោ
សាសនំ អនុរក្ខន្តោ

១ ឱ. ម. បុប្ផនាមោ ។

ឧបតិស្សៈជាអ្នកមានប្រាជ្ញា ១ ព្រះបុស្សទេវៈដែលជាមហា-ធម្មកថិក ១ ព្រះសុមនៈអ្នកមានប្រាជ្ញា ១ ព្រះបុប្ផៈជាពហុ-ស្សូត ១ ព្រះមហាសីវៈជាមហាធម្មកថិកឈ្លាសវៃ ក្នុងបិដកទាំងអស់ ១ ព្រះឧបាលិជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ ១ ព្រះមហានាគជាអ្នកមានប្រាជ្ញាច្រើនឈ្លាសវៃក្នុងវង្សព្រះសទ្ធម្ម ១ ព្រះអភ័យជាអ្នកមានប្រាជ្ញាឈ្លាសវៃក្នុងបិដកទាំងអស់ ១ ព្រះតិស្សត្ថេរជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ ១ សិស្សរបស់ព្រះតិស្សត្ថេរនោះ ឈ្មោះបុស្សៈជាអ្នកមានប្រាជ្ញាច្រើន ជាពហុស្សូត ជាអ្នករក្សាព្រះសាសនា

ជម្ពុទីបេ បតិដ្ឋិតោ
ចូឡាភយោ ច មេធាវី
វិនយេ ច វិសារទោ
តិស្សត្ថេរោ ច មេធាវី
សទ្ធម្មវំសកោវិទោ
ចូឡាទេវោ ច មេធាវី
វិនយេ ច វិសារទោ
សីវត្ថេរោ ច មេធាវី
វិនយេ សព្វត្ថ កោវិទោ
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[៤] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទុតិយំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ បញ្ញត្តំ ។ កំ អារព្ភាតិ ។ ធនិយំ កុម្ភការ-បុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ធនិយោ កុម្ភការ-

ប្រតិស្ឋានទុកក្នុងជម្ពូទ្វីប ១ ព្រះចូឡាភ័យជាអ្នកមានប្រាជ្ញា ក្លៀវក្លាក្នុងវិន័យ ១ ព្រះតិស្សត្ថេរជាអ្នកមានប្រាជ្ញាឈ្លាសវៃ ក្នុងវង្សព្រះសទ្ធម្ម ១ ព្រះចូឡាទេវៈជាអ្នកមានប្រាជ្ញាក្លៀវក្លា ក្នុងវិន័យ ១ ព្រះសីវត្ថេរជាអ្នកមានប្រាជ្ញាឈ្លាសវៃក្នុងវិន័យ ទាំងអស់ ១ ព្រះនាគត្ថេរទាំងនេះ សុទ្ធតែជាអ្នកមានប្រាជ្ញា ច្រើន ចេះវិន័យស្ទាត់ក្នុងមគ្គ បានប្រកាសវិន័យបិដកទុក ក្នុងតម្ពបណ្ណិទ្វីប (លង្កាទ្វីប) ។

[៤] សួរថា ទុតិយបារាជិក ដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តក្នុងទីណា ។ ឆ្លើយថា ទុតិយបារាជិក ព្រះអង្គទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវធនិយភិក្ខុជាកូននៃស្មូនឆ្នាំង ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលធនិយភិក្ខុជាកូននៃស្មូនឆ្នាំង

បុត្តោ រញ្ញោ ទារូនិ អទិន្នានិ(១) អាទិយិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ នត្ថិ អនុប្បន្នប្បញ្ញត្តិ(២) ។ ឆន្នំ អាបត្តិសមុដ្ឋានានំ(៣) តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[៤] តតិយំ ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ អញ្ញមញ្ញំ ជីវិតា វោរោបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ នត្ថិ អនុប្បន្នប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

---

១ ឱ. ម. អទិន្នំ ។ ២ សព្វត្ថ នត្ថិ អនុប្បន្នប្បញ្ញត្តីតិ ន ទិស្សតិ ។ ៣ សព្វត្ថ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ទិស្សតិ ។

យកឈើរបស់ព្រះរាជាដែលទ្រង់មិនបានប្រទាន ។ ទុតិយបារាជិកនោះ មានតែបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានឡើយ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង ទុតិយបារាជិកតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត ១ ។ បេ ។

[៥] សួរថា តតិយបារាជិក ព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយច្រើនរូប ផ្តាច់ជីវិតគ្នានិងគ្នា ។ តតិយបារាជិកនេះ មានតែបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានឡើយ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង តតិយបារាជិកតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត ១ ។ បេ ។

១១

មហាវិភង្គេ សោឡស មហាវារា ចតុត្ថបារាជិកំ ឧទានគាថា

[៦] ចតុត្ថំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ វគ្គុមុទាតីរិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ វគ្គុមុទាតីរិយា ភិក្ខូ គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ នត្ថិ អនុប្បន្នបញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

ចត្តារោ បារាជិកា និដ្ឋិតា ។

តស្សុទ្ទានំ

[៧] មេថុនាទិន្នាទានញ្ច
មនុស្សវិគ្គហុត្តរិ
បារាជិកានិ ចត្តារិ
ឆេជ្ជវត្ថូ អសំសយាតិ ។

មហាវិភង្គ មហាវារៈ ១៦ បារាជិក ទី ៤ ឧទ្ទានគាថា

[៦] សួរថា ចតុត្ថបារាជិក ព្រះអង្គបញ្ញត្តក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទា ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយ អ្នកនៅទៀបឆ្នេរស្ទឹងវគ្គុមុទានាំគ្នាពោលអួតនូវគុណ នៃឧត្តរិមនុស្សធម្មនៃគ្នានិងគ្នា ដល់គ្រហស្ថទាំងឡាយ ។ ចតុត្ថបារាជិកនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានឡើយ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង ចតុត្ថបារាជិកតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត ១ ។ បេ ។

ចប់ បារាជិក ៤ ។

ឧទ្ទានគឺបញ្ជីរឿងនៃបារាជិកនោះដូច្នេះ

[៧] បារាជិក ៤ គឺសេពមេថុន ១ លួចទ្រព្យគេ ១ សម្លាប់
មនុស្ស ១ ពោលអួតឧត្តរិមនុស្សធម្ម ១ ជាឆេជ្ជវត្ថុ (វត្ថុជា
ហេតុឲ្យដាច់ចាកភិក្ខុភាវៈ) បណ្ឌិតមិនត្រូវសង្ស័យឡើយ ។

[៨] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នបញ្ញត្តិ សព្វត្ថ បញ្ញត្តិ បទេសបញ្ញត្តិ សាធារណបញ្ញត្តិ អសាធារណបញ្ញត្តិ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នំ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោ កឹ តត្ថ បាតិមោក្ខំ កឹ តត្ថ អធិបាតិមោក្ខំ កា វិបត្តិ កា សម្បត្តិ

[៨] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិ ក្នុងទីណា ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ព្រោះរឿងរ៉ាវដូចម្តេច ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ សព្វត្ថប្បញ្ញត្តិ ១ បទេសប្បញ្ញត្តិ ១ សាធារណប្បញ្ញត្តិ ១ អសាធារណប្បញ្ញត្តិ ១ ឯកតោបញ្ញត្តិ ១ ឧភតោបញ្ញត្តិ ១ មានក្នុងបឋមសង្ឃាទិសេសនោះ ដែរឬទេ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង បឋមសង្ឃាទិសេសចាត់ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា ។ បណ្តាវិបត្តិ ៤ យ៉ាង បឋមសង្ឃាទិសេស ចាត់ជាវិបត្តិអ្វី ។ បណ្តាកងនៃអាបត្តិទាំង ៧ យ៉ាង បឋមសង្ឃាទិសេសចាត់ចូលក្នុងកងអាបត្តិណា ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង បឋមសង្ឃាទិសេសតាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ បណ្តាអធិករណ៍ទាំង ៤ យ៉ាង បឋមសង្ឃាទិសេសចាត់ជាអធិករណ៍អ្វី ។ បណ្តាសមថៈទាំង ៧ យ៉ាង បឋមសង្ឃាទិសេសរម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ អ្វីជាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាអធិបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ

កា បដិបត្តិ ។ កតិ អត្ថវសេ បដិច្ច ភគវតា ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិសេសោ បញ្ញត្តោ ។ កេ សិក្ខន្តិ ។ កេ សិក្ខិតសិក្ខា ។ កត្ថ ឋិតំ ។ កេ ធារេន្តិ ។ កស្ស វចនំ ។ កេនាភតន្តិ ។

[៩] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃា-ទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ សេយ្យសកំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា សេយ្យសកោ ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេសិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។ អសាធារណប្បញ្ញត្តិ ។ ឯក-តោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ។

សេចក្តីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នកព្យាយាមបញ្ចេញអសុចិ តើព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ជនពួកណា តែងសិក្សា ។ ជនពួកណា មានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះឋិតនៅក្នុងជនពួកណា ។ ជនពួកណាតែងទ្រទ្រង់ទុក ។ សិក្ខាបទនោះជាពាក្យរបស់នរណា ។ នរណានាំមក ។

[៩] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នកព្យាយាមបញ្ចេញអសុចិ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវសេយ្យសកភិក្ខុមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលសេយ្យសកភិក្ខុមានអាយុព្យាយាមបញ្ចេញអសុចិដោយដៃ ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ មានក្នុងសិក្ខាបទនោះដែរឬទេ ។ មានតែបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានក្នុងសិក្ខាបទនោះទេ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។

បញ្ចន្នំ ចាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយា-
បន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កត-
មេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ តតិយេន
ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា
វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ
កតមោ អាបត្តិក្ខន្ធោតិ ។ សង្ឃាទិសេសាបត្តិក្ខន្ធោ ។
ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋា-
តីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ
ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករ-
ណានំ កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។
សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតីតិ ។ ទ្វីហិ
សមថេហិ សម្មតិ សម្មុខាវិនយេន ច បដិញ្ញាតក-
រណេន ច ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិន-
យោតិ ។ បញ្ញត្តិ វិនយោ វិភត្តិ អភិវិនយោ ។ កឹ តត្ថ
ចាតិមោក្ខំ កឹ តត្ថ អធិប្បាតិមោក្ខន្តិ ។ បញ្ញត្តិ ចាតិ-
មោក្ខំ វិភត្តិ អធិប្បាតិមោក្ខំ ។ កា វិបត្តីតិ ។ អសំវរោ

បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះមកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទី ៣ ។ បណ្តាវិបត្តិទាំង ៤ សិក្ខាបទនោះចាត់ជាវិបត្តិអ្វី ។ ចាត់ជាសីលវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះចាត់ចូលក្នុងកងនៃអាបត្តិណា ។ ចាត់ចូលក្នុងកងនៃអាបត្តិសង្ឃាទិសេស ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បណ្តាអធិករណ៍ទាំង ៤ សិក្ខាបទនោះចាត់ចូលក្នុងអធិករណ៍ណា ។ ចាត់ចូលក្នុងអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ សិក្ខាបទនោះរម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ រម្ងាប់ដោយសមថៈពីរយ៉ាង គឺ សម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ ។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ ។ បញ្ញត្តិជាវិន័យ វិភត្តិជាអភិវិន័យ ។ អ្វីជាបាតិមោក្ខ ក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ ។ បញ្ញត្តិជាបាតិមោក្ខ វិភត្តិជាអធិប្បាតិមោក្ខ ។ អ្វីជាវិបត្តិ ។ ការមិនសង្រួម

វិបត្តិ ។ កា សម្បត្តីតិ ។ សំវរោ សម្បត្តិ ។ កា បដិ-
បត្តីតិ ។ ន ឯវរូបំ ករិស្សាមីតិ យាវជីវំ អាចាណកោដិកំ
សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ កតិ អត្ថវសេ
បដិច្ច ភគវតា ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិ-
សេសោ បញ្ញត្តោតិ ។ ទស អត្ថវសេ បដិច្ច ភគវតា ឧ-
បក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិសេសោ បញ្ញត្តោ
សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ
និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិ-
កានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ
បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិ-
យ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។
កេ សិក្ខន្តីតិ ។ សេក្ខា ច បុថុជ្ជនកល្យា-
ណកា ច សិក្ខន្តិ ។ កេ សិក្ខិតសិក្ខាតិ ។
អរហន្តោ សិក្ខិតសិក្ខា ។ កត្ថ ឋិតន្តិ ។

ជាវិបត្តិ ។ អ្វីជាសម្បត្តិ ។ ការសង្រួមជាសម្បត្តិ ។ សេចក្តីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្តេច ។ ភិក្ខុសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដល់អស់ជីវិត មានជីវិតជាទីបំផុត ដោយគិតថា អញនឹងមិនធ្វើកម្មយ៉ាងនេះទេ (នេះជាសេចក្តីប្រតិបត្តិ) ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិ តើព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានអៀនខ្មាស ១ ដើម្បីកិរិយានៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញ៉ាំងជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ១ ដើម្បីញ៉ាំងជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។ ពួកជនណាតែងសិក្សា ។ សេក្ខបុគ្គលនិងកល្យាណបុថុជ្ជនតែងសិក្សា ។ ជនពួកណាដែលមានសិក្ខាសិក្សាហើយ ។ ព្រះអរហន្តមានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះឋិតនៅក្នុងបុគ្គលពួកណា ។

សិក្ខាកាមេសុ ឋិតំ ។ កេ ធារេន្តីតិ ។ យេសំ វត្តតិ តេ ធារេន្តិ ។ កស្ស វចនន្តិ ។ ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ កេនាភតន្តិ ។ បរម្បរាភតំ ។

ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលីបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ ។ បេ ។
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[១០] យេន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ

*ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល ។ ជនពួកណាតែងទ្រទ្រង់ទុក ។ សិក្ខាបទនោះតែងប្រព្រឹត្តទៅ ដល់ជនពួកណា ជនពួកនោះតែងទ្រទ្រង់ទុក ។ សិក្ខាបទនោះ ជាពាក្យរបស់នរណា ។ ជាពាក្យរបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ សិក្ខាបទនោះ លោកអង្គណានាំមក ។ (ព្រះថេរៈដែលមាននាមដូចតទៅនេះ) នាំត ៗ គ្នាមក ។*

*ព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១*
*ព្រះមោគ្គលីបុត្ត ១ អង្គទៀតជាគម្រប់ ៥ ព្រះថេរៈទាំងនេះ*
*ឋិតនៅក្នុងទ្វីបមានឈ្មោះថាជម្ពូដ៏មានសិរី ។ តអំពីនោះមក*
*ព្រះមហិន្ទត្ថេរ ១ ព្រះឥដ្ដិយៈ ១ ព្រះឧត្តិយៈ ១ ព្រះសម្ពលៈ ១*
*។ បេ ។ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន ជាអ្នកចេះ*
*ព្រះវិន័យ ឈ្លាសក្នុងមគ្គ បានប្រកាសវិនយបិដកទុក ក្នុង*
*តម្ពបណ្ណិទ្វីប ។*

[១០] *សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុដែលស្ទាបអង្អែលកាយមាតុគ្រាមក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធ នូវព្រះឧទាយិ មានអាយុ ។*

អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។

[១១] មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[១២] មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិយាយ វណ្ណំ ភាសន្តស្ស សង្ឃាទិសេសោ កត្ថ

ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ ស្ទាបអង្អែលកាយមាតុគ្រាម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាងសិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បេ ។

[១១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលនិយាយចែចង់មាតុគ្រាមក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុនិយាយចែចង់មាតុគ្រាម ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើង ដោយសមុដ្ឋាន ៣ យ៉ាង គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយអំពីវាចានិងចិត្ត ។ បេ ។

[១២] សួរថា ព្រះមានព្រះភាគទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុ ដែលនិយាយសរសើរការបម្រើដោយកាម ដើម្បីខ្លួនក្នុងសំណាក់មាតុ-

បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អា-យស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ អភាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[១៣] សញ្ចរិត្តំ សមាបជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ សញ្ចរិត្តំ សមាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

គ្រាមក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវ-បុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ និយាយសរសើរការបម្រើដោយកាម ដើម្បីខ្លួនក្នុងសំណាក់មាតុគ្រាម ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[១៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុដែលប្រព្រឹត្តនិយាយដឹកនាំ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធ នូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ និយាយដឹកនាំ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្ប-ញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង គឺ តាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត ១ តាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយនិងចិត្ត ១ តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត ១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្តមិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយអំពីវាចា និងចិត្ត ១ ។ បេ ។

[១៨] សញ្ញាចិកាយ កុដឹ ការាបេន្តស្ស សង្ឃា-ទិសេសោ កត្ថ បញ្ញត្តោតិ ។ អាឡវិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាឡវិកេ[១] ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាឡវិកា ភិក្ខូ សញ្ញាចិកាយ កុដឹ ការាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[១៩] មហល្លកំ វិហារំ ការាបេន្តស្ស សង្ឃាទិ-សេសោ កត្ថ បញ្ញត្តោតិ ។ កោសម្ពិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឆន្នំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឆន្នោ វិហារវត្ថុំ សោធេន្តោ អញ្ញ-តរំ ចេតិយរុក្ខំ ឆេទាបេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

---

១ ឱ. ម. អាឡវកេ ។

មហាវិភង្គ មហាវារៈ ១៦ សង្ឃាទិសេស ទី ៦-៧

[១៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុដែលឲ្យគេធ្វើកុដិ (មិនមានទាយកជាម្ចាស់របស់) ដោយការសូមគ្រឿងឧបករណ៍របស់គេមកដោយខ្លួនឯង ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយដែលនៅក្នុងនគរអាឡវី ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយនៅក្នុងនគរអាឡវី ឲ្យគេធ្វើកុដិ (មិនមានទាយកជាម្ចាស់របស់) ដោយការសូមគ្រឿងឧបករណ៍របស់គេមកដោយខ្លួនឯង ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើង ដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[១៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលឲ្យគេធ្វើវិហារធំក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុ ជម្រះទីវិហារ បានប្រើគេឲ្យកាប់ដើមឈើដែលគេសន្មតថា ជាចេតិយ ១ ដើម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើង ដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[១៦] ភិក្ខុំ អមូលកេន ចាភជិកេន ធម្មេន អនុទ្ធំ-សេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ មេត្តិយភុម្មជកេ ភិក្ខូ អា-រព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ មេត្តិយភុម្មជកា ភិក្ខូ អាយ-ស្មន្តំ ទព្ពំ មល្លបុត្តំ អមូលកេន ចាភជិកេន ធម្មេន អនុទ្ធំសេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិ-សមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[១៧] ភិក្ខុំ អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ ឧបាទាយ ចាភជិកេន ធម្មេន អ-នុទ្ធំសេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ មេត្តិយភុម្មជកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្ពំ មល្លបុត្តំ អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ ឧបាទាយ ចាភជិកេន ធម្មេន អនុទ្ធំសេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។

[១៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលចោទ (បង្កាច់) ភិក្ខុផងគ្នាដោយអាបត្តិបារាជិកមិនមានមូល ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលមេត្តិយភិក្ខុនិងភុម្មជកភិក្ខុចោទ (បង្កាច់) ព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិកមិនមានមូល ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើង ដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[១៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលចោទ (បង្កាច់) ភិក្ខុផងគ្នាដោយអាបត្តិបារាជិក ព្រោះអាស្រ័យហេតុបន្តិចបន្តួចរបស់អធិករណ៍ ជាចំណែកដទៃមកជាគ្រឿងអាង ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលមេត្តិយភិក្ខុនិងភុម្មជកភិក្ខុចោទ (បង្កាច់) ព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិក ព្រោះអាស្រ័យហេតុបន្តិចបន្តួចរបស់អធិក-រណ៍ជាចំណែកដទៃមកជាគ្រឿងអាង ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។

ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[១៨] សង្ឃភេទកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ[១] នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ ទេវទត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ទេវទត្តោ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[១៩] ភេទានុវត្តកានំ ភិក្ខូនំ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តានំ សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ ទេវទត្តស្ស សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា អហេសុំ[២] តស្មឹ វត្ថុស្មឹ ។

---

១ សមនុភាសិយមានាយាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ម. ឯត្ថន្តរេ វគ្គវាទកាតិ ទិស្សតិ ។

បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[១៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នក (ព្យាយាម) បំបែកសង្ឃ ដែលសង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដងហើយនៅតែមិនលះបង់ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុឈ្មោះទេវ-ទត្ត ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលទេវទត្តភិក្ខុព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បេ ។

[១៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តតាមនូវភិក្ខុដែល (ព្យាយាម) បំបែកសង្ឃ សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដង នៅតែមិនលះបង់ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយច្រើនរូប ប្រព្រឹត្តតាមទេវទត្តជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ។

ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[២០] ទុព្វចស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ កោសម្ពិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឆន្នំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឆន្នោ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ អកាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[២១] កុលទូសកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អស្សជិបុនព្វសុកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អស្សជិបុនព្វសុកា ភិក្ខូ សង្ឃេន

សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាងសិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បេ ។

[២០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុអ្នក (រឹងរូស) ប្រដៅបានដោយក្រ សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដង នៅតែមិនលះបង់ ក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុ កាលដែលភិក្ខុទាំងឡាយ ពោលទូន្មានប្រកបដោយធម៌ បានធ្វើខ្លួនឲ្យជាអ្នកគឺគេស្តីប្រដៅមិនបាន ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បេ ។

[២១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នកទ្រុស្តត្រកូល សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដង នៅតែមិនលះបង់ ក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ សង្ឃ

២៣

មហាវិភង្គេ សោឡស មហាវារា ឧទ្ទានគាថា

បព្វាជនីយកម្មកតា ភិក្ខូ ឆន្ទគាមិតា ទោសគាមិតា មោហាគាមិតា ភយគាមិតា ចាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

តេរស សង្ឃាទិសេសា និដ្ឋិតា ។

តស្សុទ្ទានំ

[២២] វិស្សដ្ឋិ កាយសំសគ្គោ[១]
ទុដ្ឋុល្លំ អត្តកាមតំ[២]
សញ្ចរិត្តំ កុដី ចេវ
វិហារោ ច អមូលកំ
កិញ្ចិ លេសញ្ច ភេទោ ច
តថេវ អនុវត្តកា
ទុព្វចំ កុលទូសញ្ច[៣]
សង្ឃាទិសេស[៤]តេរសាតិ ។

---

១ ឱ. ម. កាយសំសគ្គំ ។ ២ ឱ. ម. អត្តកាមញ្ច ។ ៣ កុលទូសន្តិ បាឋោ បញ្ញាយតិ ។ ៤ ឱ. ម. សង្ឃាទិសេសា ។

បានធ្វើបញ្ញាជនីយកម្មហើយ (ត្រឡប់ដេរប្រទេច) ថា ភិក្ខុទាំងឡាយ លុះក្នុងអំណាចសេចក្តីស្រឡាញ់ លុះក្នុងអំណាចសេចក្តីស្អប់ លុះក្នុងអំណាចសេចក្តីល្ងង់ លុះក្នុងអំណាចសេចក្តីខ្លាច ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បេ ។

ចប់ សង្ឃាទិសេស ១៣ ។

ឧទ្ទាន គឺបញ្ជីរឿង នៃសង្ឃាទិសេសនោះដូច្នេះ

[២២] សង្ឃាទិសេសទាំង ១៣ គឺ សុក្កវិស្សដ្ឋិ ១ កាយសំសគ្គៈ ១ ទុដ្ឋុល្លវាចៈ ១ អត្តកាមបារិចរិយៈ ១ សញ្ចរិត្តៈ ១ កុដិការៈ ១ មហល្លកវិហារៈ ១ អមូលកៈ ១ កិញ្ចិទេស (អញ្ញភាគិយៈ) ១ សង្ឃភេទកៈ ១ ភេទានុវត្តកៈ ១ ទុព្វចៈ ១ កុលទូសកៈ ១ ។

[២៣] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមោ អធិយតោ កត្ថ បញ្ញត្តោ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តិ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តិ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នំ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោ ។ កឹ តត្ថ ចាតិមោក្ខំ កឹ តត្ថ អធិប្បាតិមោក្ខំ ។ កា វិបត្តិ កា សម្បត្តិ កា បដិបត្តិ ។ កតិ អត្ថវសេ បដិច្ច ភគវតា បឋមោ អធិយតោ បញ្ញត្តោ ។ កោ

[២៣] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី ១ ក្នុងទីណា ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ព្រោះរឿងរ៉ាវដូចម្តេច ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ សព្វត្ថប្បញ្ញត្តិ ១ បទេសប្បញ្ញត្តិ ១ សាធារណប្បញ្ញត្តិ ១ អសាធារណប្បញ្ញត្តិ ១ ឯកតោបញ្ញត្តិ ១ ឧភតោបញ្ញត្តិ ១ មានក្នុងអនិយតៈទី ១ នោះដែរឬទេ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេស ត្រូវឧទ្ទេសណា ។ បណ្តាវិបត្តិទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាវិបត្តិអ្វី ។ បណ្តាកងនៃអាបត្តិទាំង ៧ យ៉ាង សិក្ខាបទនោះ ចាត់ចូលក្នុងអាបត្តិកងណា ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ បណ្តាអធិករណ៍ទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាអធិករណ៍អ្វី ។ បណ្តាសមថៈទាំង ៧ យ៉ាង សិក្ខាបទនោះ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ ។ អ្វីជាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ ។ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ សេចក្តីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តអនិយតៈទី ១ ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ជនពួក

សិក្ខន្តិ ។ កេ សិក្ខិតសិក្ខា ។ កត្ថ បិតំ ។ កេ ជាវេន្តិ ។ កស្ស វចនំ ។ កេនាភតន្តិ ។

[២៤] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បបមោ អនិយតោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលង្កម្មនិយេ និសជ្ជំ កប្បេសិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។ អសាធារណប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ បញ្ចន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន

ណាតែងសិក្សា ។ ជនពួកណា មានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះ ឋិតនៅក្នុងជនពួកណា ។ ជនពួកណា តែងទ្រទ្រង់ទុក ។ សិក្ខាបទនោះ ជាពាក្យរបស់នរណា ។ សិក្ខាបទនោះ នរណានាំមក ។

[២៤] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី ១ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវ-ព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ តែម្នាក់ឯង សម្រេចនូវការអង្គុយលើអាសនៈដ៏ស្ងាត់ កំបាំងល្មមធ្វើ (សេវនកិច្ចបាន) ជាមួយនឹងមាតុគ្រាមតែម្នាក់ ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ ក្នុងអនិយតៈ ទី ១ នោះ មានដែរឬទេ ។ មានតែបញ្ញត្តិ ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះទេ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេស-ប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។ បណ្តាបាតិ-មោក្ខុទ្ទេសទាំង ៥ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទ

ឧទ្ទេសំ អាគច្ឆតីតិ ។ ចតុត្ថេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សិយា សីលវិបត្តិ សិយា អាចារវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ សិយា បារាជិកាបត្តិក្ខន្ធោ សិយា សង្ឃាទិសេសាបត្តិក្ខន្ធោ សិយា បាចិត្តិយាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតីតិ ។ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោតិ ។ បញ្ញត្តិ វិនយោ វិភត្តិ អភិវិនយោ ។ កឹ តត្ថ បាតិមោក្ខំ តត្ថ អធិប្បាតិមោក្ខន្តិ ។ បញ្ញត្តិ បាតិមោក្ខំ វិភត្តិ អធិប្បាតិមោក្ខំ ។ កា វិបត្តីតិ ។ អសំវរោ វិបត្តិ ។ កា សម្បត្តីតិ ។

នោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៤ ។ បណ្តាវិបត្តិទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាវិបត្តិអ្វី ។ សិក្ខា-បទនោះ ចាត់ជាសីលវិបត្តិក៏មាន ជាអាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ យ៉ាង សិក្ខាបទនោះ ចាត់ជាកងនៃអាបត្តិណា ។ ចាត់ជាកងនៃអាបត្តិបារាជិកក៏មាន ចាត់ជាកងនៃអាបត្តិសង្ឃាទិសេសក៏មាន ចាត់ជាកងនៃអាបត្តិបាចិត្តិយៈក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាទេ ។ សួរថា បណ្តាអធិករណ៍ទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាអធិករណ៍អ្វី ។ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ យ៉ាង សិក្ខាបទនោះ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ រម្ងាប់ដោយសមថៈ ៣ យ៉ាងគឺ ដោយសម្មុខា-វិន័យ ១ បដិញ្ញាតករណៈ ១ សម្មុខាវិន័យនិងតិណវត្ថារកៈ ១ ។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ ។ បញ្ញត្តិជាវិន័យ វិភត្តិជាអភិវិន័យ ។ អ្វីជាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ ។ បញ្ញត្តិជាបាតិមោក្ខ វិភត្តិជាអធិប្បាតិ-មោក្ខ ។ អ្វីជាវិបត្តិ ។ សេចក្តីមិនសង្រួមជាវិបត្តិ ។ អ្វីជាសម្បត្តិ ។

២៧

មហាវិភង្គេ សោឡស មហាវារា បឋមោ អនិយតោ

សំវរេ សម្បត្តិ ។ កា បដិបត្តីតិ ។ ន ឯវរូបំ ការិស្សាមីតិ យាវជីវំ អាចាណកោដិកំ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ កតិ អត្ថវសេ បដិច្ច ភគវតា បឋមោ អនិយតោ បញ្ញត្តោតិ ។ ទស អត្ថវសេ បដិច្ច ភគវតា បឋមោ អនិយតោ បញ្ញត្តោ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ កេ សិក្ខន្តីតិ ។ សេក្ខា ច បុថុជ្ជនកល្យាណកា ច សិក្ខន្តិ ។ កេ សិក្ខិតសិក្ខាតិ ។ អរហន្តោ សិក្ខិតសិក្ខា ។ កត្ថ ឋិតន្តិ ។ សិក្ខាកាមេសុ ឋិតំ ។

សេចក្តីសង្រួមជាសម្បត្តិ ។ សេចក្តីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្តេច ។ ភិក្ខុសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដល់អស់ជីវិត មានជីវិតជាទីបំផុត ដោយសេចក្តីកំណត់ក្នុងចិត្តថា អញនឹងមិនធ្វើកម្មមានសភាពយ៉ាងនេះឡើយ (នេះជាសេចក្តីប្រតិបត្តិ) ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តអនិយតៈទី ១ ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តអនិយតៈទី ១ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺ ដើម្បីល្អដល់សង្ឃ ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិនបុគ្គលដែលមិនអៀនខ្មាស ១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរាំងរាអាសវៈទាំងឡាយ ដែលកើតឡើងក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវៈទាំងឡាយដែលកើតឡើងក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។ ពួកជនណា តែងសិក្សា ។ ពួកសេក្ខបុគ្គលនិងកល្យាណបុថុជ្ជនតែងសិក្សា ។ ពួកជនណា មានសិក្ខាសិក្សាហើយ ។ ព្រះអរហន្តទាំងឡាយ មានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះ ឋិតនៅក្នុងជនពួកណា ។ ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល ។

កោ ធារេន្តីតិ ។ យេសំ វត្តតិ តេ ធារេន្តិ ។ កស្ស វចនន្តិ ។ ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ កេនាភតន្តិ ។ បរម្បរាភតំ ។

ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលីបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ ។ បេ ។
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[២៨] យេន្ត ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទុតិយោ អនិយតោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ

ជនពួកណា តែងទ្រទ្រង់ទុក ។ សិក្ខាបទនោះ ប្រព្រឹត្តទៅដល់ពួកជនណា ពួកជននោះតែងទ្រទ្រង់ទុក ។ សិក្ខាបទនោះ ជាពាក្យរបស់នរណា ។ ជាពាក្យរបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ។ សិក្ខាបទនោះ នរ-ណានាំមក ។ ព្រះថេរៈទាំងឡាយ (ដូចមាននាមតទៅនេះ) នាំតៗគ្នាមក ។

ព្រះឧបាលិ ១ ព្រះទាសកៈ ១ ព្រះសោណកៈ ១ ព្រះសិគ្គវៈ ១
និងព្រះមោគ្គលីបុត្ត ១អង្គទៀតជាគម្រប់ ៥ ព្រះថេរៈទាំងនេះ
នៅក្នុងទ្វីបមានឈ្មោះថា ជម្ពូ ដ៏មានសិរី ។ តអំពីនោះមក
ព្រះមហិន្ទៈ ១ ព្រះឥដ្ដិយៈ ១ ព្រះឧត្តិយៈ ១ ព្រះសម្ពលៈ ១
។ បេ ។ ព្រះនាគត្ថេរទាំងឡាយ នេះមានបញ្ញាច្រើន ចេះ
ព្រះវិន័យ ស្ទាត់ជំនាញក្នុងមគ្គ បានប្រកាសវិនយបិដកទុក
ក្នុងតម្ពបណ្ណិទ្វីប ។

[២៥] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី ២ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះ

២៩

មហាវិភង្គេ សោឡស មហាវារា ទុតិយោ អនិយតោ

មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេស-ប្បញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។ អសាធារណប្បញ្ញត្តិ ។ ឯក-តោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាប-ន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ចតុត្ថេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សិយា សីលវិបត្តិ សិយា អាចារវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ សិយា សង្ឃាទិសេសាបត្តិក្ខន្ធោ សិយា ចាចិត្តិយាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋា-តីតិ ។ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា

រឿងរ៉ាវដែលឧទាយិភិក្ខុមានអាយុ តែម្នាក់ឯង សម្រេចការអង្គុយក្នុងទីកំបាំងជាមួយនឹងមាតុគ្រាមតែម្នាក់ ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ មានក្នុងសិក្ខាបទនោះដែរឬទេ ។ មានតែបញ្ញត្តិ ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះទេ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ២ ។ បណ្តាវិបត្តិទាំង ៤ យ៉ាង សិក្ខាបទនោះចាត់ជាវិបត្តិអ្វី ។ ចាត់ជាសីលវិបត្តិក៏មាន ចាត់ជាអាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ចាត់ជាកងនៃអាបត្តិណា ។ ជាកងនៃអាបត្តិសង្ឃាទិសេសក៏មាន ជាកងនៃអាបត្តិបាចិត្តិយៈក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង

កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតីតិ ។ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

ទ្វេ អនិយតា និដ្ឋិតា ។

# តស្សុទ្ទានំ

[២៦] អលង្កម្មនិយញ្ចេវ
តថេវ ច ន ហេវ ខោ
អនិយតា សុបញ្ញត្តា
ពុទ្ធសេដ្ឋេន តាទិនាតិ ។

គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយអំពីវាចានិងចិត្ត ១ ។ បណ្តាអធិករណ៍ទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាអធិករណ៍ណា ។ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ យ៉ាង សិក្ខាបទនោះរម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ រម្ងាប់ដោយសមថៈ ៣ យ៉ាង គឺដោយសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ ដោយសម្មុខាវិន័យ និងតិណវត្ថារកៈ ១ ។

ចប់អនិយតៈ ទាំងពីរ ។

# ឧទ្ទាន គឺបញ្ជីរឿងនៃអនិយតៈនោះ ដូច្នេះ

[២៦] អនិយតៈ (ទាំងពីរ) គឺ អលង្កម្មនិយៈ ១ នាលង្កម្មនិយៈ ១ ដែលព្រះពុទ្ធប្រសើរ មានគុណធម៌ដ៏មាំមួនទ្រង់បញ្ញត្តទុកហើយ ដោយល្អ ។

[២៧] យេន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អតិរេកចីវរំ ទសាហំ អតិក្កាមេន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កាត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ អតិរេកចីវរំ[១] ធារេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[២៨] ឯករត្តំ តិចីវរេន វិប្បវសន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កាត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ ភិក្ខូនំ ហត្ថេ ចីវរំ និក្ខិបិត្វា សន្ត-រុត្តរេន ជនបទចារិកំ បក្កមឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ

១ ឯត្ថន្តរេ ទសាហាតិក្កន្តន្តិ កត្ថចិ បោត្ថកេ បញ្ញាយតិ ។

[២៧] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈចំពោះភិក្ខុដែលទុកអតិរេកចីវរឲ្យកន្លងហួសពី ១០ ថ្ងៃទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុទ្រទ្រង់អតិរេកចីវរ (ទុកឲ្យកន្លង ១០ ថ្ងៃទៅ) ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង គឺតាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត ១ តាំងឡើងអំពីកាយ វាចា និងចិត្ត ១ ។ បេ ។

[២៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈចំពោះភិក្ខុដែលនៅប្រាសចាកត្រៃចីវរអស់មួយយប់ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបផ្ញើចីវរ ក្នុងដៃនៃភិក្ខុទាំងឡាយហើយ (ស្លៀកដណ្ដប់) តែស្បង់និងចីពរចេញដើរទៅកាន់ជនបទចារិក ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង

ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[២៩] អកាលចីវរំ បដិគ្គហេត្វា មាសំ អតិក្កាមេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ អកាលចីវរំ បដិគ្គហេត្វា មាសំ អតិក្កាមេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[៣០] អញ្ញាតិកាយ ភិក្ខុនិយា បុរាណចីវរំ ធោវាបេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ អញ្ញាតិកាយ ភិក្ខុនិយា បុរាណចីវរំ ធោវាបេសិ តស្មឹ

សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង គឺតាំងឡើងអំពីកាយនិង វាចា មិនតាំងឡើងអំពីចិត្ត ១ តាំងឡើងអំពីកាយ វាចា និងចិត្ត ១ ។ បេ ។

[២៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុទទួលអកាលចីវរហើយទុកឲ្យកន្លងមួយខែទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបទទួលអកាលចីវរហើយ ទុកឲ្យកន្លងហួសមួយខែទៅ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង គឺតាំងឡើងអំពីកាយ និងវាចា មិនតាំងឡើងអំពីចិត្ត ១ តាំងឡើងអំពីកាយ វាចា និងចិត្ត ១ ។ បេ ។

[៣០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលប្រើនាងភិក្ខុនី មិនមែនជាញាតិឲ្យលាងចីវរចាស់ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវឧទាយិភិក្ខុមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិ មានអាយុ ប្រើភិក្ខុនីមិនមែនជាញាតិ

វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៣១] អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ ចីវរំ បដិគ្គណ្ហន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ ចីវរំ បដិគ្គហេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៣២] អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ អញ្ញាតកំ សេដ្ឋិបុត្តំ ចីវរំ វិញ្ញាបេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ

ឲ្យលាងចីវរចាស់ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៦ យ៉ាង ។ បេ ។

[៣១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុអ្នកទទួលចីវរអំពីដៃភិក្ខុនីមិនមែនជាញាតិ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ ទទួលចីវរអំពីដៃភិក្ខុនី មិនមែនជាញាតិ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៣២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលសូមចីវរនឹងគហបតី ឬគហបតានី ដែលមិនមែនជាញាតិ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ សូមចីវរនឹងសេដ្ឋិបុត្តដែលមិនមែនជាញាតិ ។ សិក្ខាបទនោះមានបញ្ញត្តិ ១

ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៣៣] អញ្ញាតកំ គហបតឹ វា គហបតានឹ វា តតុត្តរឹ ចីវរំ វិញ្ញាបេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ន មត្តំ ជានិត្វា ពហុំ ចីវរំ វិញ្ញាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៣៤] បុព្វេ អប្បវារិតេន[១] អញ្ញាតកំ គហបតិកំ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ បុព្វេ អប្បវារិតោ អញ្ញាតកំ គហបតិកំ ឧបសង្កមិត្វា

១ ម. អប្បវារិតស្ស ។

អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៣៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលសូមចីវរនឹងគហបតី ឬគហបតានីដែលមិនមែនជាញាតិ ឲ្យលើសជាងកំណត់ដែលគេប្រគេននោះទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយ-ភិក្ខុមិនស្គាល់ប្រមាណ (ក្នុងការសូម) ហើយសូមចីវរជាច្រើន ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៣៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុអ្នកចូលទៅរកគហបតីមិនមែនជាញាតិ ដែលគេមិនបានបវា-រណាទុកមុនទេ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ គេមិនបានបវារណាទុកមុន ហើយចូលទៅរកគហបតីដែលមិនមែនជាញាតិ

ចីវរេ វិកប្បំ អាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៣៥] បុព្វេ អប្បវារិតេន[១] អញ្ញាតកោ គហបតិកោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជនស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ បុព្វេ អប្បវារិតោ អញ្ញាតកោ គហបតិកោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

១ ម. អប្បវារិតស្ស ។

ដល់នូវកិរិយាកំណត់ក្នុងចីវរ[១] ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៣៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលចូលទៅរកគហបតីទាំងឡាយមិនមែនជាញាតិ ដែលគេមិនបានបវារណាទុកមុន ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ គេមិនបានបវារណាទុកមុន ហើយចូលទៅរកគហបតីទាំងឡាយដែលមិនមែនជាញាតិ ដល់នូវកិរិយាកំណត់ក្នុងចីវរ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

---

១ កំណត់ប្រវែងទំហំ និងសាច់ចីវរ តាមដែលខ្លួនពេញចិត្ត គឺចង់បានឲ្យល្អហួសហេតុ ។

[៣៦] អតិរេកតិក្ខត្តុំ ចោទនាយ អតិរេកឆក្ខត្តុំ ឋានេន ចីវរំ អភិនិប្ផាទេន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ ឧបាសកេន អជ្ជុណ្ហោ ភន្តេ អាគមេហីតិ វុច្ចមានោ នាគមេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

កឋិនវគ្គោ បឋមោ ។

តស្សុទ្ទានំ

[៣៧] អតិរេកេករត្តញ្ច
អកាលចោរាណាវេនំ
បដិគ្គហាណបញ្ចមញ្ចេវ
វិញ្ញត្តិ ច តទុត្តរិ
ទ្វេ អប្បវារិតា ចេវ
តិក្ខត្តុំ ចោទនាយ ចាតិ[១] ។

១ បដិគ្គហាញ្ចបញ្ចេវ វិញ្ញត្តិ ច តទុត្តរិ ទ្វេ អប្បវារិតាចេវ តិក្ខត្តុំ ចោទនាយ វាតីតិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[៣៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលញ៉ាំងចីវរឲ្យសម្រេច ដោយការតឹងទារហួសកំណត់បីដង ដោយឈរហួសកំណត់ ៦ ដង ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ ដែលឧបាសកនិយាយ (អង្វរ) ថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់រង់ចាំក្នុងថ្ងៃនេះ ១ ថ្ងៃសិន ហើយមិនបានបង្អង់ចាំ ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

ចប់ កឋិនវគ្គទី ១ ។

# ឧទ្ទាន គឺបញ្ជីរឿង នៃកឋិនវគ្គនោះដូច្នេះ

[៣៧] អតិរេកចីវរ ១ ចីវរដែលភិក្ខុនៅប្រាសចាកមួយរាត្រី ១ អកាលចីវរ ១ ការប្រើភិក្ខុនីមិនមែនជាញាតិឲ្យគក់លាងចីវរចាស់ ១ ទទួលចីវរអំពីដៃភិក្ខុនី ១ ទៀតជាគម្រប់ប្រាំ ការសូមចីវរអំពីគ្រហស្ថមិនមែនជាញាតិ ១ ការសូមឲ្យលើសពីស្បង់ចីពរ ១ ភិក្ខុដែលគេមិនបានបវារណាមានពីរយ៉ាង ១ ការតឹងទារចីវរឲ្យហួសកំណត់បីដង ១ ។

[៣៨] កោសិយមិស្សកំ សន្ថតំ ការាបេន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ អាឡវិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ កោសិយការកេ ឧបសង្កមិត្វា ឯវមាហំសុ ពហូ អាវុសោ កោសការកេ[1] បចថ អម្ហាកំបិ ទស្សថ មយំបិ ឥច្ឆាម កោសិយមិស្សកំ សន្ថតំ ការាបេតុន្តិ[2] តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៣៩] សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

---

១ កោសីយការកេតិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ម. កាតុន្តិ ។

[៣៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលឲ្យគេធ្វើសន្ថតលាយដោយសូត្រ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុចូលទៅរកពួកអ្នកធ្វើសូត្រហើយនិយាយថា ម្នាលអ្នកមានអាយុទាំងឡាយ សូមអ្នកទាំងឡាយ ស្ងោរនាងឲ្យច្រើនហើយឲ្យមកពួកអាត្មាខ្លះ ឯអាត្មាចង់ឲ្យគេធ្វើសន្ថតលាយដោយសូត្រ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៣៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលឲ្យគេធ្វើសន្ថតនឹងរោមចៀមមានពណ៌ខ្មៅសុទ្ធ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុឲ្យគេធ្វើសន្ថត លាយរោមចៀមមានពណ៌ខ្មៅសុទ្ធ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៤០] អជានយិត្វា តុលំ ឱជាតានំ តុលំ គោចរិយា-
នំ នវំ សន្ថតំ ការាបេន្តស្ស និស្សគ្គិយំ បាចិត្តិយំ
កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។
ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា
ភិក្ខូ ថោកំយេវ ឱដាតានំ(១) អន្តេ អាទយិត្វា តថេវ
សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេសុំ
តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋា-
នានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៤១] អនុវស្សំ សន្ថតំ ការាបេន្តស្ស និស្សគ្គិយំ
បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ
អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។
សម្ពហុលា ភិក្ខូ អនុវស្សំ សន្ថតំ ការាបេសុំ តស្មឹ វត្ថុ-
ស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិ-
សមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

១ ឱ. ម. ថោកញ្ញេវ ឱទាតំ ។

[៤០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែល (ធ្វើឯង) ឬប្រើឲ្យគេធ្វើនូវសន្ថ័តថ្មី មិនលាយរោមចៀមស មួយជញ្ជីង រោមចៀមក្រហម មួយជញ្ជីង (១ ភាគ) ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុឲ្យគេធ្វើសន្ថ័ត ដោយរោមចៀមមានពណ៌ខ្មៅសុទ្ធយ៉ាងនោះដែរ តែលាយដោយរោមចៀមសបន្តិចត្រង់ជាយ ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៤១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលឲ្យគេធ្វើសន្ថ័តរាល់ឆ្នាំ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបឲ្យគេធ្វើសន្ថ័តរាល់ ៗ ឆ្នាំ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៤២] អនាទយិត្វា បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថឹ នវំ និសីទនសន្ថតំ ការាបេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ សន្ថតានិ ឧជ្ឈិត្វា អារញ្ញកង្គំ(១) បិណ្ឌបាតិកង្គំ បំសុកូលិកង្គំ សម្មាទយឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៤៣] ឯឡកលោមានិ បដិគ្គហេត្វា តិយោជនំ អតិក្កាមេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អញ្ញតរំ ភិក្ខុំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អញ្ញតរោ ភិក្ខុ ឯឡកលោមានិ បដិគ្គហេត្វា តិយោជនំ អតិក្កាមេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។

---

១ អារញ្ញិកង្គន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[៤២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលឲ្យគេធ្វើសន្ថ័ត សម្រាប់ទ្រាប់អង្គុយថ្មី មិនលាយសន្ថ័តចាស់មួយចំអាមព្រះសុគតដោយជុំវិញ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបលះចោលសន្ថ័ត ហើយសមាទាននូវអារញ្ញិកង្គធុតង្គ បិណ្ឌបាតិកង្គធុតង្គ បំសុកូលិកង្គ-ធុតង្គ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៤៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទទួលរោមចៀមនាំឲ្យកន្លងហួស ៣ យោជន៍ទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុមួយរូបទទួលរោមចៀម (នាំទៅ) ឲ្យកន្លងហួស ៣ យោ-ជន៍ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានពីរយ៉ាង គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត ១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ ។ បេ ។

[៤៤] អញ្ញាតិកាយ ភិក្ខុនិយា ឯឡកលោមានិ ធោវាបេន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សក្កេសុ បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ អញ្ញាតិកាហិ ភិក្ខុនីហិ ឯឡកលោមានិ ធោវាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៤៥] រូបិយំ បដិគ្គណ្ហន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ រូបិយំ បដិគ្គហេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៤៦] នានប្បការកំ រូបិយសំវោហារំ សមាបជ្ជន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។

[៤៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលប្រើភិក្ខុនីមិនមែនជាញាតិ ឲ្យលាងរោមចៀម ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងសក្កជនបទ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុប្រើភិក្ខុនីទាំងឡាយ មិនមែនជាញាតិ ឲ្យលាងរោមចៀម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៤៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទទួលរូបិយៈ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុទទួលរូបិយៈ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៦ យ៉ាង ។ បេ ។

[៤៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលប្រព្រឹត្តទិញដូរដោយរូបិយៈ មានប្រការផ្សេង ៗ ក្នុងទីណា ។

សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ នានប្ប-ការកំ រូបិយសំវោហារំ សមាបជ្ជឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋា-នេហិ សមុដ្ឋាតិ ។ បេ ។

[៤៧] នានប្បការកំ កយវិក្កយំ សមាបជ្ជ-ន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ បរិព្វាជកេន សទ្ធឹ កយវិក្កយំ សមាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

កោសិយវគ្គោ ទុតិយោ ។

ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុប្រព្រឹត្តការទិញដូរដោយរូបិយៈមានប្រការផ្សេង ៗ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៤៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈចំពោះភិក្ខុដែលប្រព្រឹត្តការទិញនិងការលក់មានប្រការផ្សេង ៗ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវ ដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ ប្រព្រឹត្តការទិញនិងការលក់ជាមួយនឹងបរិព្វាជក ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

ចប់ កោសិយវគ្គ ទី ២ ។

# តស្សុទ្ទានំ

[៤៨] មិស្សកំ សុទ្ធកញ្ចេវ
តុលញ្ច អនុវស្សកំ
បុរាណសន្ថតញ្ចេវ
លោមានិ ហារណេន ច
ធោវនំ រូបិយញ្ចេវ
ឧភោ ច នានប្បការកន្តិ ។

[៤៩] អតិរេកបត្តំ ទសាហំ អតិក្កាមេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ អតិរេកបត្តំ ធារេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

# ឧទ្ទាន គឺបញ្ជីរឿងនៃកោសិយវគ្គនោះដូច្នេះ

[៤៨] ភិក្ខុធ្វើសន្ថ័តដោយរោមចៀមលាយសូត្រ ១ ភិក្ខុធ្វើសន្ថ័តដោយរោមចៀម មានពណ៌ខ្មៅសុទ្ធ ១ ភិក្ខុធ្វើសន្ថ័តលាយរោមចៀមសមួយជញ្ជីង ក្រហមមួយជញ្ជីង ១ ភិក្ខុធ្វើសន្ថ័តរាល់ឆ្នាំ ១ ភិក្ខុធ្វើសន្ថ័តថ្មីត្រូវលាយនឹងសន្ថ័តចាស់ ១ ភិក្ខុទទួលរោមចៀមនាំទៅបានតែត្រឹមបីយោជន៍ ១ ភិក្ខុប្រើភិក្ខុនីឲ្យលាយរោមចៀម ១ ភិក្ខុទទួលរូបិយៈ ១ ភិក្ខុទិញលក់ផ្លាស់ប្តូរដោយរូបិយវត្ថុមានប្រការផ្សេង ៗ មានពីរសិក្ខាបទ ១ ។

[៤៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈចំពោះភិក្ខុដែលទុកអតិរេកបាត្រឲ្យកន្លងហួស ១០ ថ្ងៃទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុទ្រទ្រង់អតិរេកបាត្រ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋាន ២ យ៉ាង គឺតាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត ១ តាំងឡើងអំពីកាយ វាចា និងចិត្ត ១ ។ បេ ។

[៤០] ឩនបញ្ចពន្ធនេន បត្តេន អញ្ញំ នវំ បត្តំ ចេតាបេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សក្កេសុ បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ អប្បមត្តកេនបិ ភិន្នេន អប្បមត្តកេនបិ ខណ្ឌេន វិលិខិតមត្តេនបិ ពហូ បត្តេ វិញ្ញាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៤១] ភេសជ្ជានិ បដិគ្គហេត្វា សត្តាហំ អតិក្កាមេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ ភេសជ្ជានិ បដិគ្គហេត្វា សត្តាហំ អតិក្កាមេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ (កឋិនកោ) ។ បេ ។

[៥០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលមានបាត្រមានចំណង គឺស្នាមប្រេះបែកមិនទាន់ដល់ប្រាំអន្ទើ ហើយឲ្យគេទិញបាត្រថ្មីទៀត ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងសក្កជនបទ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយ-ភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុមានបាត្រគ្រាន់តែបែកបន្តិចបន្តួចខ្លះ គ្រាន់តែដាច់បន្តិចបន្តួចខ្លះ គ្រាន់តែមានស្នាមប្រេះបន្តិចបន្តួចខ្លះ ហើយសូមបាត្រជាច្រើន ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាងសិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៥១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទទួលភេសជ្ជៈ ហើយទុកឲ្យកន្លងហួស ៧ ថ្ងៃទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបទទួលភេសជ្ជៈហើយទុកឲ្យកន្លងហួស ៧ ថ្ងៃ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង (ដូចក្នុងកឋិនសិក្ខាបទ) ។ បេ ។

[៤២] អតិរេកមាសេ សេសេ គិម្ហានំ[១] វស្សិកសាដិកាចីវរំ បរិយេសន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ អតិរេកមាសេ សេសេ គិម្ហានំ វស្សិកសាដិកចីវរំ បរិយេសឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៤៣] ភិក្ខុស្ស សាមំ ចីវរំ ទត្វា កុបិតេន អនត្តមនេន អច្ឆិន្ទន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ ភិក្ខុស្ស សាមំ ចីវរំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

---

១ ឱ. ម. គិម្ហានេ ។

[៥២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលស្វែងរកវស្សិកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀងក្នុងកាល ដែលហួសពីខែជាខាងចុងនៃរដូវក្តៅទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្ត ក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយ-ភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុនាំគ្នា ស្វែងរកវស្សិកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង ក្នុងកាលដែលហួសពីខែ ជាខាងចុងនៃរដូវក្តៅ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ទាំង ៦ យ៉ាង ។ បេ ។

[៥៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលបានឲ្យចីវរខ្លួនឯងដល់ភិក្ខុផងគ្នា ហើយមានចិត្តខឹងអាក់ អន់ដណ្តើមយកវិញ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមាន អាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យ-បុត្តមានអាយុ បានឲ្យចីវរខ្លួនឯងដល់ភិក្ខុផងគ្នា ហើយមានចិត្តអាក់អន់ ដណ្តើមយកវិញ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង ៦ យ៉ាងសិក្ខាបទនោះតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[៤៨] សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋា-នានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៤៩] បុព្វេ អប្បវារិតេន[១] អញ្ញាតកស្ស គហបតិ-កស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧបនន្ទោ សក្យបុត្តោ បុព្វេ អប្បវារិតោ អញ្ញាតកស្ស គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិ តស្មឹ វត្ថុស្មឹ ។

១ អប្បវារិតស្សាតិ សព្វត្ថ បោត្ថកេ ទិស្សតិ ។

[៤៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលសូមអំបោះ (អំពីគ្រហស្ថ) ដោយខ្លួនឯង យកមកឲ្យជាង តម្បាញត្បាញចីវរ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុសូមអំបោះ (អំពីគ្រហស្ថ) ដោយខ្លួនឯង ហើយឲ្យជាងតម្បាញត្បាញចីវរ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៤៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលគេមិនបានបវារណាជាមុន ហើយចូលទៅរកជាងតម្បាញរបស់គហបតី ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (ចង់បានឲ្យល្អហួសហេតុ) ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ ដែលគេមិនបានបវារណាទុកជាមុន ហើយចូលទៅរកជាងតម្បាញរបស់គហបតី មិនមែនជាញាតិដល់នូវកិរិយាកំណត់ក្នុងចីវរ ។

ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៤៦] អច្ចេកចីវរំ បដិគ្គហេត្វា ចីវរកាលសមយំ អតិក្កាមេន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ អច្ចេកចីវរំ បដិគ្គហេត្វា ចីវរកាលសមយំ អតិក្កាមេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ (កឋិនកោ) ។ បេ ។

[៤៧] តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិត្វា អតិរេកឆារត្តំ វិប្បវសន្តស្ស និស្សគ្គិយំ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិត្វា អតិរេកឆារត្តំ វិប្បវសឹសុ តស្មឹ វត្ថុស្មឹ ។

សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៨៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទទួលអច្ចេកចីវរ ហើយទុកឲ្យកន្លងសម័យនៃចីវរកាលទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុ-គ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបទទួលអច្ចេកចីវរ ហើយទុកឲ្យកន្លងសម័យនៃចីវរកាលទៅ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង (ដូចក្នុងកឋិនកសិក្ខាបទ) ។ បេ ។

[៨៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទុកចីវរ បណ្ដាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាក (ចីវរនោះ) ឲ្យលើស ៦ រាត្រីទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបទុកចីវរ បណ្ដាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាក (ចីវរនោះ) ឲ្យលើសពី ៦ រាត្រីទៅ ។

ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋា-នេហិ សមុដ្ឋាតិ (កឋិនកោ) ។ បេ ។

[៤៨] ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិ-ណាមេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

បត្តវគ្គោ តតិយោ ។

# តស្សុទ្ទានំ

[៤៩] អតិរេកញ្ច បត្តញ្ច
ឩនេន ពន្ធនេន ច
ភេសជ្ជំ សាដកាញ្ចេវ
កុបិតេន អច្ឆិន្ទនំ
ទុវេ តន្តវាយា ចេវ

សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង (ដូចក្នុងកឋិនកសិក្ខាបទ) ។ បេ ។

[៤៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលដឹងថា លាភគេបង្អោនទៅ ដើម្បីសង្ឃ ហើយបង្អោនមក ដើម្បីខ្លួនវិញ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុដឹងថា លាភដែលគេបង្អោនទៅ ដើម្បីសង្ឃ ហើយក៏ត្រឡប់បង្អោនមក ដើម្បីខ្លួនវិញ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

ចប់ បត្តវគ្គ ទី ៣ ។

# ឧទ្ទាន គឺបញ្ជីរឿងនៃបត្តវគ្គនោះដូច្នេះ

[៤៩] ភិក្ខុទុកអតិរេកបាត្រ ១ ភិក្ខុមានបាត្រមានចំណាំង មិនទាន់ដល់ប្រាំអន្លើ ១ ភិក្ខុទុកភេសជ្ជៈ ១ ភិក្ខុស្វែងរកសំពត់ងូតទឹកភ្លៀង ១ ភិក្ខុឲ្យចីវរដល់ភិក្ខុឯទៀតហើយមានចិត្តអាក់អន់ដណ្ដើមយកវិញ ១ ភិក្ខុសូមឲ្យជាងតម្បាញត្បាញចីវរ

អច្ចេកចីវរេន ច
ឆារត្តំ វិប្បវាសេន
អត្តនោ បរិណាមនាតិ[១] ។

តឹស និស្សគ្គិយា បាចិត្តិយា និដ្ឋិតា[២] ។

[៦០] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្បជានមុសាវាទេ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ហត្ថកំ សក្យបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ហត្ថកោ សក្យបុត្តោ តិត្ថិយេហិ សទ្ធឹ សល្លបន្តោ អវជានិត្វា បដិជានិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

---

១ តេសំ តេសំ វគ្គានំ អវសានេ ឧទ្ទានានិ ឱរោបិយបោត្ថកេ ន ទិស្សន្តិ ។ ២ ឥតោ បរំ តេសំ តេសំ វគ្គានំ ឧទ្ទានំ ទស្សិតំ តំ បន វិសទិសំ ហោតិ ។ ឥច្ចន្នេន តត្ថ ឱលោកេតព្វំ ។

មានពីរសិក្ខាបទ ១ ភិក្ខុទទួលអច្ចេកចីវរទុកឲ្យកន្លងសម័យនៃចីវរកាល ១ ភិក្ខុទុកចីវរណាមួយក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកចីវរលើស ៦ រាត្រី ១ ភិក្ខុបង្អោនសង្ឃលាភមកដើម្បីខ្លួនឯង ១ ។

ចប់ និស្សគ្គិយបាចិត្តិយៈ ៣០ ។

[៦០] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តបាចិត្តិយៈព្រោះពោលពាក្យកុហកដោយដឹងខ្លួន ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវហត្ថកភិក្ខុ ជាសក្យបុត្ត ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលហត្ថកភិក្ខុជាសក្យបុត្តនិយាយចរចាជាមួយនឹងតិរ្ថិយទាំងឡាយ គេចកែសំដីហើយត្រឡប់ទទួលប្តេជ្ញា ប្តេជ្ញាហើយបែរជាគេចកែសំដីវិញ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាងគឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយអំពីវាចានិងចិត្ត ១ ។ បេ ។

[៦១] ឱមសវាទេ ចាចិត្តិយំ កាត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ បេសលេ-ហិ ភិក្ខូហិ សទ្ធឹ ភណ្ឌាដ្ឋា បេសលេ ភិក្ខូ ឱមសឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៦២] ភិក្ខុបេសុញ្ញេ ចាចិត្តិយំ កាត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ បេសុញ្ញំ ឧបសំហរឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អា-បត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៦១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈ ព្រោះពោលពាក្យចាក់ដោត (ដេរប្រទេចភិក្ខុផងគ្នា) ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុ ទាស់ទែងនឹងភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ហើយពោលចាក់ដោត (ដេរប្រទេច) ភិក្ខុដែលមានសីលជាទីស្រឡាញ់ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[៦២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈ ព្រោះពោលពាក្យញុះញង់ភិក្ខុផងគ្នា ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយ-ភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុនាំពាក្យញុះញង់របស់ភិក្ខុទាំងឡាយ ដែលបង្កហេតុឈ្លោះទាស់ទែងគ្នា ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[៦៣] អនុបសម្បន្នំ បទសោ ធម្មំ វាចេន្តស្ស បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ឧបាសកេ បទសោ ធម្មំ វាចេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ ។ បេ ។

[៦៤] អនុបសម្បន្នេន ឧត្តរិទ្វិរត្តតិរត្តំ[១] សហ សេយ្យំ កប្បេន្តស្ស បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ អាឡវិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ អនុបសម្បន្នេន សហ សេយ្យំ កប្បេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។

១ ឧត្តរិទិរត្តតិរត្តន្តិ កត្ថចិ បោត្ថកេ ទិស្សន្តិ ។

[៦៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលបង្រៀនធម៌ដោយបទ ដល់អនុបសម្បន្ន ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុបង្រៀនធម៌ដោយបទដល់ពួកឧបាសក ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាងគឺតាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយនិងចិត្ត ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ ។ បេ ។

[៦៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលសម្រេចការដេកនៅជាមួយនឹងអនុបសម្បន្ន ឲ្យលើសជាងពីរបីរាត្រីឡើងទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុច្រើនរូបសម្រេចការដេកនៅជាមួយនឹងអនុបសម្បន្ន ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត ១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ ។ បេ ។

[៦៤] មាតុគ្គាមេន សហ សេយ្យំ កប្បេន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ អនុរុទ្ធំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា អនុរុទ្ធោ មាតុគ្គាមេន សហ សេយ្យំ កប្បេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ (ឯឡកលោមកោ) ។ បេ ។

[៦៦] មាតុគ្គាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមស្ស ធម្មំ ទេសេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ទ្វេ អនុប្បញ្ញត្តិយោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ (បទសោធម្មេ) ។ បេ ។

[៦៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលសម្រេចការដេកនៅជាមួយនឹងមាតុគ្រាម ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះអនុរុទ្ធមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះអនុរុទ្ធមានអាយុ សម្រេចការដេកនៅ ជាមួយនឹងមាតុគ្រាម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង (ដូចក្នុងឯឡកលោមក-សិក្ខាបទ) ។ បេ ។

[៦៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលសម្ដែងធម៌ដល់មាតុគ្រាមឲ្យលើសជាងប្រាំ — ប្រាំមួយម៉ាត់ឡើងទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ សម្ដែងធម៌ដល់មាតុ-គ្រាម ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ២ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង (ដូចក្នុងបទសោធម្មសិក្ខាបទ) ។ បេ ។

[៦៧] អនុបសម្បន្នស្ស ឧត្តរិមនុស្សធម្មំ ភូតំ អារោចេន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ វគ្គុមុទាតីរិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ វគ្គុមុទាតីរិយា ភិក្ខូ គិហីនំ អញ្ញ-មញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ សិយា កាយ-តោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ ។ បេ ។

[៦៨] ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋា-នេហិ សមុដ្ឋាតិ (អចិន្នាបានសមុដ្ឋានេ) ។ បេ ។

[៦៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលប្រាប់ឧត្តរិមនុស្សធម្មដែលមានពិតដល់អនុបសម្ប័ន្ន ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងឈ្មោះវគ្គុមុទា ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុអ្នកនៅទៀបឆ្នេរស្ទឹងឈ្មោះវគ្គុមុទាពោលអួតឧត្តរិមនុស្សធម្មនៃគ្នានឹងគ្នាដល់គ្រហស្ថទាំងឡាយ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង គឺ តាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា និងចិត្ត ១ តាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយនិងចិត្ត ១ តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត ១ ។ បេ ។

[៦៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នាដល់អនុបសម្ប័ន្ន ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នាដល់អនុបសម្ប័ន្ន ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង (ដូចសមុដ្ឋាននៃអទិន្នាទាន) ។ បេ ។

[៦៩] បឋវីខណនស្ស បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ អាឡវិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាឡវិកេ[១] ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាឡវិកា ភិក្ខូ បឋវឹ ខណឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

មុសាវាទវគ្គោ បឋមោ ។

តស្សុទ្ទានំ

[៧០] មុសាឱមសបេសុញ្ញំ
បទសោ ទ្វេ និបជ្ជានា
ទេសនារោចនា ចេវ
ទុដ្ឋុល្លំ បឋវីខណេតិ ។

[៧១] ភូតគាមបាតព្យតាយ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ អាឡវិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាឡវិកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាឡវិកា

១ ឱ. ម. អាឡវកេ ។

[៦៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលជីកដី ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកភិក្ខុនៅក្នុងនគរអាឡវី ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុនៅក្នុងនគរអាឡវីនាំគ្នាជីកដី ។ សិក្ខាបទនោះ មានតែបញ្ញត្ត ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

ចប់ មុសាវាទវគ្គទី ១ ។

## ឧទ្ទាន គឺបញ្ជីរឿងនៃមុសាវាទវគ្គនោះដូច្នេះ

[៧០] ភិក្ខុពោលពាក្យកុហក ១ ពោលពាក្យចាក់ដោត ១
ពោលពាក្យញុះញង់ ១ បង្រៀនធម៌ដោយបទ ១ ដេករួមនឹង
អនុបសម្បន្នមានពីរសិក្ខាបទ ១ ការសម្តែងធម៌ ១ ការអួត
ឧត្តរិមនុស្សធម្ម ១ ការប្រាប់ទុដ្ឋុល្លាបត្តិ ១ ការជីកដី ១ ។

[៧១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលធ្វើភូតគាមឲ្យវិនាសក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកភិក្ខុអ្នកនៅក្នុងនគរអាឡវី ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុអ្នកនៅក្នុងនគរអាឡវី

ភិក្ខូ វុត្ថំ ធិដ្ឋីសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៧២] អញ្ញវាទកេ វិហេសកេ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ កោសម្ពិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឆន្នំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឆន្នោ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អញ្ញេនញ្ញំ បដិចរិ តស្មឹ វត្ថុស្មឹ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៧៣] ឧជ្ឈាបនកេ ខីយនកេ ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ បញ្ញត្តំ ។ កំ អារព្ភាតិ ។ មេត្តិយភុម្មជកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ ភិក្ខូ ឧជ្ឈាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា

កាប់ដើមឈើ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[៧២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុពោលពាក្យដទៃធ្វើឲ្យសង្ឃលំបាក ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុ កាលត្រូវគេសាកសួរដោយអាបត្តិក្នុងកណ្ដាលជំនុំសង្ឃ ហើយត្រឡប់ពោលបិទបាំងពាក្យដទៃដោយពាក្យដទៃវិញ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[៧៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលបង្គាប់ភិក្ខុដទៃ ឲ្យពោលទោសតិះដៀល (ភិក្ខុផងគ្នា) ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងដែលមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ប្រើភិក្ខុទាំងឡាយឲ្យពោលទោសព្រះទព្វមល្លបុត្តមានអាយុ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១

អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ ស-
មុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៧៤] សង្ឃិកំ មញ្ចំ វា បីឋំ វា ភិសឹ វា កោច្ឆំ វា អជ្ឈោកាសេ សន្ថរិត្វា អនុទ្ធរិត្វា អនាបុច្ឆា បក្កមន្តស្ស បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ សង្ឃិកំ សេនាសនំ អជ្ឈោកាសេ សន្ថរិត្វា អនុទ្ធរិត្វា អនាបុច្ឆា បក្កមឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ (កឋិនកេ) ។ បេ ។

[៧៥] សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា អនុទ្ធរិត្វា អនាបុច្ឆា បក្កមន្តស្ស បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សត្តរសវគ្គិយេ

អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[៧៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលយកគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ជារបស់សង្ឃទៅក្រាលទុកក្នុងទីវាលមិនសាយកមកទុកដោយខ្លួនឯង (ក្តី) មិនប្រើអ្នកដទៃឲ្យយកមកទុក (ក្តី) ហើយដើរចៀសចេញទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបក្រាលសេនាសនៈរបស់សង្ឃក្នុងទីវាល មិនសាយកមកទុកដោយខ្លួនឯង ទាំងមិនប្រាប់ (អ្នកដទៃឲ្យសាយកមកទុក) ហើយដើរចៀសចេញទៅ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាងសិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង (ដូចក្នុងកឋិនកសិក្ខាបទ) ។ បេ ។

[៧៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលក្រាលកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃ មិនសាយកមកទុកដោយខ្លួនឯង (ក្តី) មិនប្រាប់ (អ្នកដទៃឲ្យសាយកមកទុកក្តី) ហើយដើរចៀសចេញទៅ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកសត្តរសវគ្គិយ-

ភិក្ខុ អាបជ្ជតិ ។ កិស្មឹ វត្ថុស្មិន្តិ ។ សត្តរសវគ្គិយា ភិក្ខូ សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា អនុទ្ធរិត្វា អនាបុច្ឆា បក្កមឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិ-សមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ (កឋិនកេ) ។ បេ ។

[៧៦] សង្ឃិកេ វិហារេ ជានំ បុព្វុបគតំ ភិក្ខុំ អនុបខជ្ជ សេយ្យំ កប្បេន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ថេរេ ភិក្ខូ អនុបខជ្ជ សេយ្យំ កប្បេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។

ភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកសត្តរសវគ្គិយភិក្ខុក្រាលកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃ មិនសាយកមកទុកវិញ ទាំងមិនបានប្រាប់ (អ្នកដទៃឲ្យសាយកមកទុក) ហើយដើរចៀសចេញទៅ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង (ដូចក្នុងកឋិនកសិក្ខាបទ) ។ បេ ។

[៧៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលដឹងថា មានភិក្ខុចូលទៅនៅមុន ហើយចូលទៅច្រៀតបៀតសម្រេចការដេកនៅក្នុងវិហារជារបស់សង្ឃ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយ-ភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុចូលទៅច្រៀតបៀតភិក្ខុជាថេរៈទាំងឡាយ ហើយសម្រេចការដេកនៅ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ។ បេ ។

[៧៧] ភិក្ខុំ កុបិតេន អនត្តមនេន សង្ឃិកា វិហារា និក្កឌ្ឍន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ កុបិតា អនត្តមនា ភិក្ខូ សង្ឃិកា វិហារា និក្ក-ឌ្ឍឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិ-សមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៧៨] សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ វា បីឋំ វា អភិនិសីទន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អញ្ញតរំ ភិក្ខុំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អញ្ញតរោ ភិក្ខុ សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ[១] សហសា អភិនិសីទិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។

---

១ មញ្ចំ វា បីឋំ វាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[៧៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលមានចិត្តខឹងអាក់អន់ហើយ ចាប់ទង់ទាញភិក្ខុផង់គ្នា ឲ្យចេញចាកវិហារជារបស់សង្ឃ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះ រឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុមានចិត្តខឹងអាក់អន់ចាប់ទង់ទាញភិក្ខុទាំងឡាយឲ្យចេញចាកវិហារជារបស់សង្ឃ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាងសិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[៧៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តិបាចិត្តិយៈចំពោះភិក្ខុដែលអង្គុយសង្កត់គ្រែ ឬតាំង ដែលមានជើងគ្រាន់តែផ្គុំទុកឰដ៏ថ្នាក់ខាងលើក្នុងវិហារជារបស់សង្ឃក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធបុគ្គលណា ។ ទ្រង់ប្រារព្ធភិក្ខុ ១ រូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុ ១ រូប អង្គុយសង្កត់ភ្លាមនូវគ្រែដែលមានជើងគ្រាន់តែផ្គុំទុកឰដ៏ថ្នាក់ខាងលើ ក្នុងវិហារជារបស់សង្ឃ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត ១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ ។ បេ ។

[៧៩] ទ្វិត្តិបរិយាយេ អជិជ្ជហិត្វា តទុត្តរឹ អជិជ្ជ-ហន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ កោសម្ពិយា បញ្ញ-ត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឆន្នំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឆន្នោ កាតបរិយោសិតំ វិហារំ បុនប្បុនំ ឆាទាបេសិ បុនប្បុនំ លិម្បាបេសិ អតិភារិកោ វិហារោ បរិបតិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[៨០] ជានំ សប្បាណកំ ឧទកំ តិណំ វា មត្តិកំ វា សិញ្ចន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ អាឡវិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាឡវិកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាឡវិកា ភិក្ខូ ជានំ សប្បាណកំ ឧទកំ តិណម្បិ មត្តិកម្បិ[១] សិញ្ចិំសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋា-នេហិ សមុដ្ឋាតិ ។ បេ ។

ភូតគាមវគ្គោ ទុតិយោ ។

---

១ តិណំ វា មត្តិកំ វាតិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[៧៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលបូកដំបូលពីរបីជាន់ ហើយនៅតែបូកថែមឲ្យលើសពីនោះទៅទៀត ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុ ឲ្យគេលាប ឲ្យគេបូករឿយ ៗ នូវវិហារដែលខ្លួនធ្វើជាស្រេចហើយ វិហារធ្ងន់ពេកក៏រលំបាក់ទៅ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[៨០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលដឹងថា ទឹកមានសត្វ ហើយយកទៅចាក់ស្រោចស្មៅឬដីក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកភិក្ខុអ្នកនៅក្នុងដែនអាឡវី ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុអ្នកនៅក្នុងដែនអាឡវីដឹងថា ទឹកមានសត្វ ហើយយកទៅស្រោចស្មៅឬដី ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

ចប់ ភូតគាមវគ្គទី ២ ។

## តស្សុទ្ទានំ

[៨១] រុក្ខុបច្ចូនព្វោវ
បេសុញ្ញុជ្ឈាបនេន ច
អជ្ឈោកាសោ វិហារោ ច
អនុបខជ្ជនិកឌ្ឍិនា
វេហាសកុដិលេបនា
សប្បាណកវិសិញ្ចន្តិ ។

[៨២] អសម្មតេន ភិក្ខុនិយោ ឱវទន្តស្ស បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ អសម្មតា ភិក្ខុនិយោ ឱវទឹសុ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុបញ្ញត្តិ អនុប្បន្នបញ្ញត្តីតិ ។ ឯកា បញ្ញត្តិ ឯកា អនុបញ្ញត្តិ អនុប្បន្នបញ្ញត្តិ តស្មឹ នត្ថិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ ។ បេ ។

# ឧទ្ទានគឺបញ្ជីរឿងនៃភូតគាមវគ្គនោះដូច្នេះ

[៨១] ភិក្ខុកាប់ដើមឈើ ១ ភិក្ខុញុះញង់ភិក្ខុផងគ្នា ១ ភិក្ខុពោលទោសគ្នា ១ ភិក្ខុយកសេនាសនៈទៅតាំងទុកក្នុងទីវាល ១ យកកម្រាលទៅក្រាលក្នុងវិហារ ១ ភិក្ខុចូលទៅដេកជ្រៀតបៀត ១ ភិក្ខុទង់ទាញភិក្ខុផងគ្នា ១ ភិក្ខុអង្គុយសង្កត់គ្រែឬតាំងដែលគេទុកព្យួរថ្នាក់ខាងលើ ១ ភិក្ខុបូកលាបដំបូល ១ ភិក្ខុដឹងថា ទឹកមានសត្វ ហើយស្រោច (ស្មៅឬដី) ១ ។

[៨២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលសង្ឃមិនបានសន្មត ហើយទៅទូន្មានភិក្ខុនី ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុ សង្ឃមិនបានសន្មតហើយទៅទូន្មានភិក្ខុនី ។ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សិក្ខាបទនោះ មានដែរឬទេ ។ មានតែបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានក្នុងសិក្ខាបទនោះទេ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើង ដោយសមុដ្ឋាន ២ យ៉ាង គឺតាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយនិងចិត្ត ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ ។ បេ ។

[៨៣] អត្ថង្គតេ សុរិយេ ភិក្ខុនិយោ ឱវទន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ចូឡបន្ថកំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ចូឡបន្ថកោ អត្ថង្គតេ សុរិយេ ភិក្ខុនិយោ ឱវទិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ (បទសោធម្មេ) ។ បេ ។

[៨៤] ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទន្តស្ស ចាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ សក្កេសុ បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ (កឋិនកោ) ។ បេ ។

[៣៥៩] ជានំ តថាវាទិនា ភិក្ខុនា អកាជានុ-ជម្មេន តំ ទិដ្ឋឹ អប្បដិនិស្សជ្ជេន សទ្ធឹ សម្ភុញ្ជេយ្យ ចេ អាបត្តិយោ អាបជ្ជតិ សម្ភុញ្ជតិ បយោគេ ទុក្កដំ សម្ភុត្តេ អាបត្តិ បាចិត្តិយស្ស ។

[៣៦០] ជានំ តថានាសិតំ សមណុទ្ទេសំ ឧប-លាបេយ្យ ចេ អាបត្តិយោ អាបជ្ជតិ ឧបលាបេតិ បយោគេ ទុក្កដំ ឧបលាបិតេ អាបត្តិ បាចិត្តិយស្ស ។

សប្បាណកវគ្គោ សត្តមោ ។

[៣៦១] ភិក្ខុ[១] ភិក្ខូហិ សហធម្មិកំ វុច្ចមានោ ឯ តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ នញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមីតិ ភណេយ្យ ចេ អាបត្តិយោ អាបជ្ជតិ ភណតិ បយោគេ ទុក្កដំ ភណិតេ អាបត្តិ បាចិត្តិយស្ស ។

១ ឱ. ម. ភិក្ខូតិ បទំ នត្ថិ ។

[៣៥៩] ភិក្ខុដឹងហើយបរិភោគរួមជាមួយគ្នា នឹងភិក្ខុដែលពោលដូច្នោះ ជាអ្នកមិនធ្វើតាមធម៌ ជាអ្នកមិនលះទិដ្ឋិនោះចេញ ត្រូវអាត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបរិភោគរួម លុះបរិភោគរួម ត្រូវអាបត្តិបាចិត្តយៈ ។

[៣៦០] ភិក្ខុដឹងថា សាមណេរ ដែលភិក្ខុឯទៀត ឲ្យវិនាសទៅដូច្នោះ ហើយទៅប្រលោមយកមក ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រលោម លុះនិយាយប្រលោមហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ សប្បាណកវគ្គ ទី ៧ ។

[៣៦១] ភិក្ខុដែលភិក្ខុទាំងឡាយពោលដាស់តឿន ប្រកបដោយធម៌ហើយនិយាយ (នឹងភិក្ខុទាំងឡាយ) យ៉ាងនេះវិញថា ម្នាលអាវុសោ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនុ៎ះនៅឡើយ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃជាអ្នកឈ្លាស ជាអ្នកទ្រទ្រង់វិន័យ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងនិយាយ លុះនិយាយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦២] វិជយំ វិវណ្ណេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វិវណ្ណេតិ បយោគេ ទុក្កដំ វិវណ្ណិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៦៣] មោហេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អនារោបិតេ មោហេ មោហេតិ អាបត្តិ ទុក្កដស្ស អារោបិតេ មោហេ មោហេតិ អាបត្តិ បាចិត្តិយស្ស ។

[៣៦៤] ភិក្ខុស្ស កុបិតោ អនត្តមនោ បហារំ ទេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បហរតិ បយោគេ ទុក្កដំ បហដេ អាបត្តិ បាចិត្តិយស្ស ។

[៣៦៥] ភិក្ខុស្ស កុបិតោ អនត្តមនោ តលសត្តិកំ ឧគ្គិរន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧគ្គិរតិ បយោគេ ទុក្កដំ ឧគ្គិរិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៦៦] ភិក្ខុំ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អនុទ្ធំសេតិ បយោគេ ទុក្កដំ អនុទ្ធំសិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៦២] ភិក្ខុពោលបង្អាប់វិន័យ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងពោលបង្អាប់ លុះពោលបង្អាប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៣] ភិក្ខុក្លែងធ្វើជាវង្វេង (ក្លែងពើធ្វើជាមិនដឹង) ត្រូវអាបត្តិ ២ គឺ កាលបើមោហារោបនកម្ម សង្ឃមិនទាន់សូត្រប្រកាសទេ ភិក្ខុក្លែងធ្វើជាវង្វេង ត្រូវអាបត្តិទុក្កដ កាលបើមោហារោបនកម្ម សង្ឃបានសូត្រប្រកាសហើយ នៅតែក្លែងធ្វើជាវង្វេង ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៤] ភិក្ខុក្រោធអាក់អន់ចិត្ត ឲ្យប្រហារភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រហារ លុះប្រហារហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៥] ភិក្ខុក្រោធអាក់អន់ចិត្ត ង៉ាជន្ទលំពែងគឺបាតដៃ ដល់ភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងង៉ាជន្ទ លុះង៉ាជន្ទ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៦] ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេស មិនមានមូល ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងចោទ លុះចោទ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៧] ភិក្ខុស្ស សញ្ចិច្ច កុក្កុច្ចំ ឧបទហន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧបទហតិ បយោគេ ទុក្កដំ ឧបទហិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៦៨] ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ ឧបស្សុតឹ តិដ្ឋន្តោ ទ្វេ អាបត្តិយោ អា-បជ្ជតិ សោស្សាមីតិ គច្ឆតិ អាបត្តិ ទុក្កដស្ស យត្ថ ឋិតោ សុណាតិ អាបត្តិ ចាចិត្តិយស្ស ។

[៣៦៩] ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ខីយ-តិ បយោគេ ទុក្កដំ ខីយិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៧០] សង្ឃេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិសាយ ហត្ថចាសំ អវិជហន្តស្ស អាបត្តិ ទុក្កដស្ស វិជហិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៦៧] ភិក្ខុក្លែងបង្កសេចក្តីវង្វេស ឲ្យកើតឡើងដល់ភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបង្កហេតុ លុះបង្ក (ហេតុនោះ) ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៨] កាលបើភិក្ខុទាំងឡាយ កំពុងប្រកួតប្រកាន់ ឈ្លោះទាស់ទែងគ្នា ភិក្ខុឈរអែបចាំស្តាប់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទៅដោយគិតថា អញនឹងចាំស្តាប់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ក្នុងទីដែលឈរស្តាប់ ។

[៣៦៩] ភិក្ខុបានឲ្យឆន្ទៈ ចំពោះកម្មទាំងឡាយ ដែលប្រកបដោយធម៌ លុះមកខាងក្រោយ ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងតិះដៀល លុះតិះដៀល ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧០] កាលបើពាក្យវិនិច្ឆ័យ កំពុងប្រព្រឹត្តទៅក្នុងជំនុំសង្ឃ ភិក្ខុមិនឲ្យឆន្ទៈ ហើយស្រាប់តែក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិ ២ គឺ កាលបើមិនទាន់លះបង់ហត្ថបាសបរិស័ទទៅទេ ត្រូវអាបត្តិទុក្កដ លុះលះ (ហត្ថបាស) ចេញទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧១] សមកេ្តន សង្ហ៊េន ចីវរំ ឧត្វា បច្ឆា ទីយនជម្មំ អាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ទីយតិ បយោគេ ទុក្កដំ ទីយិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៧២] ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គ-លស្ស បរិណាមេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិ-ណាមេតិ បយោគេ ទុក្កដំ បរិណាមិតេ អាបត្តិ ចា-ចិត្តិយស្ស ។

សហាធម្មិកវគ្គោ អដ្ឋមោ ។

[៣៧៣] បុព្វេ អប្បដិសំវិទិតោ រញ្ញោ អន្តេបុរំ បវិសន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ ចាទំ ឧម្មារំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ ចាទំ អតិក្កាមេតិ អាបត្តិ ចាចិត្តិយស្ស ។

[៣៧៤] រតនំ ឧគ្គណ្ហន្តោ ទ្វេ អាបត្តិយោ អា-បជ្ជតិ គណ្ហាតិ បយោគេ ទុក្កដំ គហិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៧១] សង្ឃព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយភិក្ខុណាមួយ ត្រឡប់តិះដៀលជាខាងក្រោយ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងតិះដៀល លុះតិះដៀល ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧២] ភិក្ខុដឹងថា លាភជារបស់សង្ឃ គេបង្អោនទៅដើម្បីសង្ឃរួចហើយ ត្រឡប់បង្អោនមកដើម្បីបុគ្គលវិញ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបង្អោនទៅ លុះបង្អោនទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ សហធម្មិកវគ្គ ទី ៨ ។

[៣៧៣] ភិក្ខុដែលមិនទាន់បានទូលស្នើព្រះបរមក្សត្រ ឲ្យទ្រង់ជ្រាបជាមុនទេ ហើយស្រាប់តែចូលទៅកាន់ខាងក្នុងព្រះរាជដំណាក់ ត្រូវអាបត្តិ ២ គឺ ឈានជំហានទី ១ ឲ្យកន្លងធរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៤] ភិក្ខុរើសយករតនវត្ថុ (គ្រឿងប្រើប្រាស់របស់គ្រហស្ថ) ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងរើសយក លុះរើសយក ត្រូវអាបត្តិបាចិត្តិយៈ ។

មហាវិភង្គេ សោឡស មហាវារា បាចិត្តិយកណ្ឌោ រាជវគ្គោ

[៣៧៥] សន្តំ ភិក្ខុំ អនាបុច្ឆា វិកាលេ គាមំ បវិសន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ បរិក្ខេបំ បវិសន្តោ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

[៣៧៦] អដ្ឋិមយំ វា ទន្តមយំ វា វិសាណមយំ វា សូចិឃរំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧៧] បមាណាតិក្កន្តំ មញ្ចំ វា បីឋំ វា ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧៨] មញ្ចំ វា បីឋំ វា តូលោនទ្ធំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧៩] បមាណាតិក្កន្តំ និសីទនំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧៥] ភិក្ខុមិនលាភិក្ខុផងគ្នាដែលមាននៅ ចូលទៅកាន់ស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិ ២ គឺ ឈានជំហានទី ១ ឲ្យកន្លងហួសរបងទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យកន្លងទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៦] ភិក្ខុឲ្យគេធ្វើបំពង់ម្ជុលនឹងឆ្អឹងក្តី ភ្លុកក្តី ស្នែងក្តី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៧] ភិក្ខុឲ្យគេធ្វើគ្រែក្តី តាំងក្តី ឲ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៨] ភិក្ខុឲ្យគេធ្វើគ្រែក្តី តាំងក្តី ញាត់ដោយសំឡី[១] ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៩] ភិក្ខុឲ្យគេធ្វើនិសីទនៈ ឲ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

---

១ មើលក្នុងមហាវិភង្គភាគទី ៤ ត្រង់រតនវគ្គ សិក្ខាបទទី ៦ បព្វៈ ៣៧៨ ទំព័រ ៣៩០ ។

[៣៨០] បមាណាតិក្កន្តំ កណ្ឌុប្បដិច្ឆាទឹ ការា-បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៨១] បមាណាតិក្កន្តំ វស្សិកសាដិកំ ការា-បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៨២] សុគតចីវរប្បមាណំ ចីវរំ ការាបេន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ សុគតចីវរប្បមាណំ ចី-វរំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ ចាចិត្តិយស្ស សុគតចីវរប្បមាណំ ចីវរំ ការាបេន្តោ ឥមា ទ្វេ អា-បត្តិយោ អាបជ្ជតិ ។

រាជវគ្គោ នវមោ ។

ខុទ្ទកា និដ្ឋិតា ។

[៣៨០] ភិក្ខុឲ្យគេធ្វើសំពត់សម្រាប់គ្របកមឬដំបៅ ឲ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៨១] ភិក្ខុឲ្យគេធ្វើសំពត់សម្រាប់ងូតទឹកភ្លៀង ឲ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៨២] ភិក្ខុឲ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុឲ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុឲ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិ ២ នេះឯង ។

ចប់ រាជវគ្គ ទី ៩ ។

ចប់ ពួកខុទ្ទកសិក្ខាបទ ។

[៣៨៣] អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិ-គ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។

[៣៨៤] ភិក្ខុនិយា វោសាសន្តិយា ន និវារេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោ-ហារេ អាបត្តិ បាដិទេសនីយស្ស ។

[៣៨៣] ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនី មិនមែនជាញាតិដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនី មិនមែនជាញាតិដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនី មិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិ ២ នេះឯង ។

[៣៨៤] ភិក្ខុមិនហាមឃាត់ភិក្ខុនីដែលបង្គាប់ (ទាយកឲ្យប្រគេនរបស់នេះ របស់នោះ) ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៣៨៥] សេក្ខសម្មតេសុ កុលេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

[៣៨៦] អារញ្ញកេសុ សេនាសនេសុ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អារញ្ញកេសុ សេនាសនេសុ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស អារញ្ញកេសុ សេនាសនេសុ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។

ចត្តារោ បាដិទេសនីយា និដ្ឋិតា ។

[៣៨៥] ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ក្នុងត្រកូលដែលសង្ឃសន្មតថាជាសេក្ខត្រកូល ដោយដៃខ្លួនឯងមកឆាន់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៣៨៦] ភិក្ខុ (នៅ) ក្នុងសេនាសនៈ ដែលតាំងនៅក្នុងព្រៃហើយទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឲ្យដំណឹងមកជាមុនដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុ (នៅ) ក្នុងសេនាសនៈ ដែលតាំងនៅក្នុងព្រៃ ហើយទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឲ្យដំណឹងមកជាមុនដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុ (នៅ) ក្នុងសេនាសនៈ ដែលតាំងនៅក្នុងព្រៃទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឲ្យដំណឹងមកជាមុនដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិ ២ នេះឯង ។

ចប់ បាដិទេសនីយៈ ៤ ។

[៣៨៧] អនាទរិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ និវាសេន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អនាទរិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ និ-វាសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ អនាទរិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ និវាសេន្តោ ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។

[៣៨៨] អនាទរិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ ចារុបេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៨៩] អនាទរិយំ បដិច្ច កាយំ វិវរិត្វា អន្តរ-ឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩០] អនាទរិយំ បដិច្ច កាយំ វិវរិត្វា អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩១] អនាទរិយំ បដិច្ច ហត្ថំ វា ចាទំ វា កី-ឡាបេន្តោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩២] អនាទរិយំ បដិច្ច ហត្ថំ វា ចាទំ វា កីឡាបេន្តោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៨៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ស្បៀកស្បង់ស្ពុយមុខ ឬស្ពុយក្រោយ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ ស្បៀកស្បង់ស្ពុយមុខ ឬស្ពុយក្រោយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ ស្បៀកស្បង់ស្ពុយមុខ ឬស្ពុយក្រោយ ត្រូវអាបត្តិ ១ នេះឯង ។

[៣៨៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឃ្លុំចីពរឲ្យស្ពុយមុខ ឬស្ពុយក្រោយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៨៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បើកកាយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បើកកាយអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រវាសដៃឬជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយគ្រវាសដៃឬជើងក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៣] អជានរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៤] អជានរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៥] អជានរិយំ បដិច្ច ឧក្ខិត្តកាយ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៦] អជានរិយំ បដិច្ច ឧក្ខិត្តកាយ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

បឋមោ វគ្គោ[១] ។

[៣៩៧] អជានរិយំ បដិច្ច ឧជ្ជគ្ឃិកាយ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៨] អជានរិយំ បដិច្ច ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៩] អជានរិយំ បដិច្ច ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

---

១ ឱ. ម. បរិមណ្ឌលវគ្គោ បឋមោ ។

[៣៩៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរងាកមើលពីសពាសទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយងាកមើលពីសពាសក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សើយចីវរដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សើយចីវរអង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ១ ។

[៣៩៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរទៅក្នុងចន្លោះផ្ទះដោយសំណើចខ្លាំង ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយក្នុងចន្លោះផ្ទះដោយសំណើចខ្លាំង ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើសំឡេងហ៊ោ សំឡេងខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០០] អជានរិយំ បដិច្ច ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០១] អជានរិយំ បដិច្ច កាយប្បចាលកំ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០២] អជានរិយំ បដិច្ច កាយប្បចាលកំ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៣] អជានរិយំ បដិច្ច ពាហុប្បចាលកំ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៤] អជានរិយំ បដិច្ច ពាហុប្បចាលកំ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៥] អជានរិយំ បដិច្ច សីសប្បចាលកំ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៦] អជានរិយំ បដិច្ច សីសប្បចាលកំ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

ទុតិយោ វគ្គោ[១] ។

---

១ ឱ. ម. ឧជ្ជគ្ឃិកវគ្គោ ទុតិយោ ។

[៤០០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើសំឡេងហ៊ោ សំឡេងខ្លាំង អង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រលែងកាយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយគ្រលែងកាយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រវាសដៃទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយក្តារដៃក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរធ្វើក្បាលងេកងោកទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយធ្វើក្បាលងេកងោកក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ២ ។

[៤០៧] អជានន្តិយំ បដិច្ច ខម្ភកតោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៨] អជានន្តិយំ បដិច្ច ខម្ភកតោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៩] អជានន្តិយំ បដិច្ច ឱគុណ្ឋិតោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១០] អជានន្តិយំ បដិច្ច ឱគុណ្ឋិតោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១១] អជានន្តិយំ បដិច្ច ឧក្កុដិកាយ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១២] អជានន្តិយំ បដិច្ច បល្លត្ថិកាយ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៣] អជានន្តិយំ បដិច្ច អសក្កច្ចំ បិណ្ឌបាតំ បដិគ្គណ្ហន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៤] អជានន្តិយំ បដិច្ច តហំ តហំ ឱលោកេន្តោ បិណ្ឌបាតំ បដិគ្គណ្ហន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៧] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរស្ទឹមចង្កេះទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៨] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយស្ទឹមចង្កេះក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៩] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរទទូរក្បាលទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១០] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយទទូរក្បាលក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១១] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរបំអើតជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១២] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ទទួលបិណ្ឌបាតដោយមិនគោរព ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ងាកមើលពីសពាសទទួលបិណ្ឌបាត ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

១៦៧

មហាវិភង្គេ សោឡស មហាវារា សេក្ខិយកណ្ឌេ ចតុត្ថោ វគ្គោ

[៤១៥] អជានរិយំ បដិច្ច សូបញ្ញេវ ពហុំ បដិគ្គ-ណ្ហន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៦] អជានរិយំ បដិច្ច ថូបីកតំ បិណ្ឌបាតំ បដិគ្គណ្ហន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

តតិយោ វគ្គោ[១] ។

[៤១៧] អជានរិយំ បដិច្ច អសក្កច្ចំ បិណ្ឌបាតំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៨] អជានរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ បិណ្ឌបាតំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៩] អជានរិយំ បដិច្ច តហំ តហំ ឱមសិត្វា បិណ្ឌបាតំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២០] អជានរិយំ បដិច្ច សូបញ្ញេវ ពហុំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២១] អជានរិយំ បដិច្ច ថូបតោ ឱមទ្ទិត្វា បិណ្ឌ-បាតំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

១ ឱ. ម. ខម្ភកតវគ្គោ តតិយោ ។

[៤១៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលសម្លច្រើន (ជាង បាយ) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលបិណ្ឌបាតឲ្យកំពុង ហួសពីកណ្តាប់បាត្រទៅ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ៣ ។

[៤១៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បិណ្ឌបាតដោយមិន គោរព ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បិណ្ឌបាតងាកមើល ពីសពាស ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កកាយ (បាយ) ត្រង់ទី នោះ ៗ ឆាន់បិណ្ឌបាត ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់សម្លច្រើន (ជាង បាយ) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ច្រូមចុះអំពីកំពូលបាយ ឆាន់បិណ្ឌបាត ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២២] អនាទរិយំ បដិច្ច សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៣] អនាទរិយំ បដិច្ច សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៤] អនាទរិយំ បដិច្ច ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៥] អនាទរិយំ បដិច្ច មហន្តំ កពឡំ ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៦] អនាទរិយំ បដិច្ច ទីឃំ អាលោបំ ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

ចតុត្ថោ វគ្គោ[១] ។

[៤២៧] អនាទរិយំ បដិច្ច អនាហដេ កពឡេ មុខទ្វារំ វិវរន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៨] អនាទរិយំ បដិច្ច ភុញ្ជន្តោ សព្វំ ហត្ថំ មុខេ បក្ខិបន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

---

១ ឱ. ម. បិណ្ឌបាតវគ្គោ ចតុត្ថោ ។

[៤២២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កកាយបាយលុបសម្ល ឬម្ហូបក្រៀម ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ខ្លួនមិនឈឺ សូមសម្ល ឬបាយ ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងឆាន់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ មានសេចក្តីសំគាល់ដើម្បីលើកទោស ហើយសំឡឹងមើលបាត្រពួកភិក្ខុដទៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើពំនូតបាយឲ្យធំ (ពេក) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើពំនូតបាយ ឲ្យវែង (ពេក) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ៤ ។

[៤២៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កាលដែលពំនូតបាយមិនទាន់ដល់មាត់ ហាមាត់ចាំ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់ញាត់ម្រាមដៃទាំងអស់ទៅក្នុងមាត់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

មហាវិភង្គេ សោឡស មហាវារា សេខិយកណ្ឌេ បញ្ចមោ វគ្គោ

[៤២៩] អជានរិយំ បដិច្ច សកាពឡ្បេន មុខេន ព្យាហរន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣០] អជានរិយំ បដិច្ច បិណ្ឌុក្ខេបកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣១] អជានរិយំ បដិច្ច កពឡាវច្ឆេទកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣២] អជានរិយំ បដិច្ច អវគណ្ឌការកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៣] អជានរិយំ បដិច្ច ហត្ថនិទ្ធូនកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៤] អជានរិយំ បដិច្ច សិត្ថាវការកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៥] អជានរិយំ បដិច្ច ជិវ្ហានិច្ឆារកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៦] អជានរិយំ បដិច្ច ចបុចបុការកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

បញ្ចមោ វគ្គោ[១] ។

---

១ ឱ. ម. កពឡវគ្គោ បញ្ចមោ ។

[៤២៩] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ និយាយទាំងពំនូតបាយនៅក្នុងមាត់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣០] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់បោះដុំបាយ (ទៅក្នុងមាត់) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣១] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់ខាំកាត់ពំនូតបាយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣២] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់បៀមពំនូតបាយឲ្យទុលថ្ពាល់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់រលាស់ដៃបណ្ដើរ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់ធ្វើគ្រាប់បាយឲ្យជ្រុះរាយពាយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៥] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់លៀនអណ្ដាត ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៦] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់ឮសូរផ្ចប់ ៗ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ៥ ។

[៤៣៧] អជានន្តិយំ បដិច្ច សុរុសុរុការកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៨] អជានន្តិយំ បដិច្ច ហត្ថនិល្លេហកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៩] អជានន្តិយំ បដិច្ច បត្តនិល្លេហកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៤០] អជានន្តិយំ បដិច្ច ឱដ្ឋនិល្លេហកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៤១] អជានន្តិយំ បដិច្ច សាមិសេន ហត្ថេន បា-នីយថាលកំ បដិគ្គណ្ហន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៤២] អជានន្តិយំ បដិច្ច សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៤៣] អជានន្តិយំ បដិច្ច ឆត្តបាណិស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធាន់ឰស្វរគ្រូក ៗ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធាន់លិទ្ធដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធាន់លិទ្ធបាត្រ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធាន់លិទ្ធបបូរមាត់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ មានដៃប្រឡាក់ដោយអាមិសៈ ទទួលផ្តិលទឹក ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ចាក់ទឹកលាងបាត្រ ទាំងគ្រាប់បាយ បោលក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សមានឆត្រក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

១៧១

មហាវិភង្គេ សោឡស មហាវារា សេក្ខិយកណ្ឌោ សត្តមោ វគ្គោ

[៥៥៥] អជានរិយំ បដិច្ច ទណ្ឌបាណិស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៨] អជានរិយំ បដិច្ច សត្ថបាណិស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៦] អជានរិយំ បដិច្ច អាវុធបាណិស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

ឆដ្ឋោ វគ្គោ(១) ។

[៥៥៧] អជានរិយំ បដិច្ច បាទុការូឡ្ហស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៨] អជានរិយំ បដិច្ច ឧបាហនារូឡ្ហស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៩] អជានរិយំ បដិច្ច យានគតស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៩០] អជានរិយំ បដិច្ច សយនគតស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

---

១ ឱ. ម. សុរុសុរុវគ្គោ ឆដ្ឋោ ។

[៤៤៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស មានដំបងក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស មានគ្រឿងសស្ត្រាក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស មានគ្រឿងអាវុធក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ៦ ។

[៤៤៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ពាក់ទ្រនាប់ជើង ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស ពាក់ស្បែកជើង ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស ដែលនៅលើយាន ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៥០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស ដែលនៅលើដំណេក ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩១] អជានន្តិយំ បដិច្ច បល្លត្ថិកាយ និសិន្នស្ស ជម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩២] អជានន្តិយំ បដិច្ច វេឋិតសីសស្ស ជម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៣] អជានន្តិយំ បដិច្ច ឱគុណ្ឋិតសីសស្ស ជម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៤] អជានន្តិយំ បដិច្ច ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស ជម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៥] អជានន្តិយំ បដិច្ច នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស ជម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៦] អជានន្តិយំ បដិច្ច ឋិតោ និសិន្នស្ស ជម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៧] អជានន្តិយំ បដិច្ច បច្ឆតោ គច្ឆន្តោ បុរ-តោ គច្ឆន្តស្ស ជម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩១] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ ដល់មនុស្ស ដែលអង្គុយត្របោមក្បាលជង្គង់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩២] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ ដល់មនុស្ស ដែលជួតក្បាល ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ ដល់មនុស្ស ដែលទទូរក្បាល ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយលើផែនដី សម្ដែងធម៌ ដល់មនុស្សដែលអង្គុយលើអាសនៈ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩៥] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយលើអាសនៈទាប សម្ដែងធម៌ ដល់មនុស្សដែលអង្គុយលើអាសនៈខ្ពស់ ត្រូវអាបត្តិ ១ គឺទុក្កដ ។

[៤៩៦] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឈរសម្ដែងធម៌ ដល់មនុស្សដែលអង្គុយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩៧] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរពីខាងក្រោយ សំ-ដែងធម៌ ដល់មនុស្សដែលដើរពីខាងមុខ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

មហាវិភង្គេ សោឡស មហាវារា សេក្ខិយកណ្ឌេ សត្តមោ វគ្គោ

[៥៥៨] អជានរិយំ បដិច្ច ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៩] អជានរិយំ បដិច្ច បិតោ ឧច្ចារំ វា បស្សាវំ វា ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៦០] អជានរិយំ បដិច្ច ហរិតេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៦១] អជានរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អជានរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ អជានរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។

សត្តមោ វគ្គោ[១] ។

បញ្ចសត្តតិ សេក្ខិយា និដ្ឋិតា[២] ។

កតាបត្តិវារំ និដ្ឋិតំ ទុតិយំ ។

---

១ ម. បាទុកវគ្គោ សត្តមោ ។ ២ សេក្ខិយា និដ្ឋិតា ។

[៤៥៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរក្រៅផ្លូវ សម្តែងធម៌ដល់មនុស្សដែលដើរតាមផ្លូវ ត្រូវអាបត្តិ ១ គឺទុក្កដ ។

[៤៥៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឈរបន្ទោឧច្ចារៈ ឬបស្សាវៈ ត្រូវអាបត្តិ ១ គឺទុក្កដ ។

[៤៦០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ដាក់លើវត្ថុខៀវស្រស់ ត្រូវអាបត្តិ ១ គឺទុក្កដ ។

[៤៦១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ ១ គឺទុក្កដ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ ១ នេះឯង ។

ចប់ វគ្គទី ៧ ។

ចប់ ពួកសេក្ខិយវត្ត ៧៥ ។

ចប់ កតាបត្តិវារៈទី ២ ។

[៤៦២] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ បេ ។ អជានរិយំ បដិច្ច ឧងកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជតិ ។ អជានរិយំ បដិច្ច ឧងកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជតិ អាចារវិបត្តឹ ។

វិបត្តិវារំ និដ្ឋិតំ តតិយំ ។

[៤៦៣] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិ-តា ។ មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ តីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិ-យា ចារាជិកាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេ-ន សិយា ទុក្កដាបត្តិក្ខន្ធេន ។ បេ ។ អជានរិយំ

[៤៦២] បណ្តាវិបត្តិទាំង ៤ អាបត្តិរបស់ភិក្ខុ ដែលសេពមេ-ថុនធម្ម រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បេ ។ បណ្តាវិបត្តិទាំង ៤ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រាប់បញ្ចូល ក្នុងវិបត្តិ ១ គឺ អាចារវិបត្តិ ។

ចប់ វិបត្តិវារៈ ទី ៣ ។

[៤៦៣] បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម លោកសង្គ្រោះដោយកងនៃអាបត្តិ ៣ កង គឺ កងនៃបារាជិកាបត្តិក៏មាន កងនៃថុល្លច្ចយាបត្តិក៏មាន កងនៃទុក្កដាបត្តិក៏មាន ។ បេ ។ បណ្តាកងនៃអាបត្តិ

បដិច្ច ឧតកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ អជានន្តិយំ បដិច្ច ឧតកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ សត្តន្នំ អាបត្តិក្ខន្ធានំ ឯកេន អាបត្តិក្ខន្ធេន សង្គហិតា ទុក្កដាបត្តិក្ខន្ធេន ។

សង្គហិតវារំ និដ្ឋិតំ ចតុត្ថំ ។

[៤៦៤] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ បេ ។ អជានន្តិយំ បដិច្ច ឧតកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ អជានន្តិយំ បដិច្ច

ទាំង ៧ អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក លោកសង្គ្រោះដោយកង នៃអាបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក លោកសង្គ្រោះដោយកងនៃអាបត្តិ ១ គឺទុក្កដាបត្តិ ។

ចប់ សង្គហិតវារៈ ទី ៤ ។

[៤៦៤] បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បេ ។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើ

ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

សមុដ្ឋានវារំ និដ្ឋិតំ បញ្ចមំ ។

[៤៦៥] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តា-ធិករណំ ។ បេ ។ អជានរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ចតុន្នំ អធិ-ករណានំ កតមំ អធិករណំ ។ អជានរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។

អធិករណវារំ និដ្ឋិតំ ឆដ្ឋំ ។

[៤៦៦] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ មេថុនំ

បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។

ចប់ សមុដ្ឋានវារៈ ទី ៥ ។

[៤៦៥] បណ្តាអធិករណ៍ ទាំង ៤ អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម ចាត់ជាអធិករណ៍ណា ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម ចាត់ជាអាបត្តាធិករណ៍ ។ បេ ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើ-ពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ចាត់ជាអធិករណ៍ណា ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ចាត់ជាអាបត្តាធិករណ៍ ។

ចប់ អធិករណវារៈ ទី ៦ ។

[៤៦៦] បណ្តាសមថៈទាំង ៧ អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាសមថៈទាំង ៧

១៧៧



ជម្មំ បដិសេវន្តស្ស អាបត្តិយោ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាត-ការណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។ អជានវិយំ បដិច្ច ឧជកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ អជានវិយំ បដិច្ច ឧជកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតការណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមថវារំ និដ្ឋិតំ សត្តមំ ។

អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម រម្ងាប់ដោយសមថៈ ៣ គឺ សម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យនិងតិណវត្ថារកៈក៏មានខ្លះ[១] ។ បេ ។ បណ្តាសមថៈទាំង ៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាសមថៈទាំង ៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រម្ងាប់ដោយសមថៈ ៣ គឺ សម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យនិងតិណវត្ថារកៈក៏មានខ្លះ ។

ចប់ សមថវារៈ ទី ៧ ។

---

១ ក្នុងទីនេះ បើនិយាយតាមឈ្មោះសមថៈ ឃើញថា ៣ តែបើនិយាយតាមសេចក្តីរួមនៅតែ ២ វិញ ដូចសេចក្តីដែលប្រែហើយនេះ ។ ព្រោះក្នុងសុមង្គលវិលាសិនីអដ្ឋកថាទីឃនិកាយ ត្រង់សង្គីតិសូត្រ ពន្យល់ថា អាបត្តាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យតែម្យ៉ាងមិនបានទេ ដូចយ៉ាងភិក្ខុសម្តែងលហុកាបត្តិក្នុងសំណាក់ភិក្ខុ ១ រូប ឬកណ្តាលជំនុំសង្ឃ ឬគណៈ ក្នុងកាលណា ទើបហៅថា អាបត្តាធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ ក្នុងកាលនោះ ។ ព្រោះហេតុដូច្នោះ បានជាលោកពោលថា អាបត្តាធិករណ៍តែងរម្ងាប់ដោយន័យ ២ យ៉ាង គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មានខ្លះ ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មានខ្លះ ដោយប្រការដូច្នេះ ។

[៤៦៧] មេថុនំ ធម្មំ បដិសេវន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ មេថុនំ ធម្មំ បដិសេវន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ អក្ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ បារាជិកស្ស យេភុយ្យេន ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ ថុល្លច្ចយស្ស វិវដកតេ មុខេ អច្ឆុបន្តំ អង្គជាតំ បវេសេតិ អាបត្តិ ទុក្កដស្ស មេថុនំ ធម្មំ បដិសេវន្តោ ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ តីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។

[៤៦៧] ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ ៣ គឺ សេពមេថុនធម្មនឹងសរីរៈ ដែលសត្វមិនទាន់ទំពាស៊ី ត្រូវអាបត្តិបារាជិក សេពមេថុនធម្មនឹងសរីរៈដែលសត្វទំពា-ស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ បញ្ចូលអង្គជាតទៅក្នុងទ្វារមាត់ដែលហា តែមិនឲ្យប៉ះពាល់ ត្រូវអាបត្តិទុក្កដ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ ៣ នេះឯង ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះរាប់បញ្ចូល ក្នុងវិបត្តិណា ។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិទាំងនោះ ចាត់ចូលក្នុងអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ អាបត្តិទាំងនោះ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីល-វិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ លោកសង្គ្រោះ ដោយកងនៃអាបត្តិ ៣ គឺ កងនៃបារាជិកាបត្តិក៏មាន កងនៃថុល្លច្ចយាបត្តិក៏មាន កងនៃទុក្កដាបត្តិក៏មាន ។

មហាវិភង្គេ សោឡស មហាវារា សមុច្ចយវារំ

ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។ សា អាបត្តិ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជតិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។

បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បណ្តាអធិករណ៍ទាំង ២ អាបត្តិទាំងនោះ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៤ អាបត្តិទាំងនោះ រម្ងាប់ដោយសមថៈ ៣ គឺសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យនិងតិណវត្ថារកៈក៏មានខ្លះ ។ បេ ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ ១ គឺទុក្កដ ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ ១ នេះឯង ។ បណ្តាវិបត្តិទាំង ៤ អាបត្តិនោះ រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិនោះ លោកសង្រ្គោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិនោះ ចាត់ជាអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ អាបត្តិនោះ រម្ងាប់ដោយសមថៈប៉ុន្មាន ។

សា អាបត្តិ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជតិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ឯកេន អាបត្តិក្ខន្ធេន សង្គហិតា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមុច្ចយវារំ និដ្ឋិតំ អដ្ឋមំ ។

ឥមេ អដ្ឋ វារា សជ្ឈាយមគ្គេន លិខិតា ។

## តស្សុទ្ទានំ

[៤៦៨] កត្ថ បញ្ញត្តិ កតី ច
វិបត្តិសង្គហេន ច
សមុដ្ឋានាធិករណា
សមថោ ច សមុច្ចយោតិ ។

បណ្ដាវិបត្តិទាំង ៤ អាបត្តិនោះ រាប់បញ្ចូល ក្នុងវិបត្តិ ១ គឺ អាចារៈវិបត្តិ ។ បណ្ដាកងនៃអាបត្តិទាំង ៧ អាបត្តិនោះ លោកសង្គ្រោះដោយកងនៃអាបត្តិ ១ គឺកងនៃទុក្កដាបត្តិ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បណ្ដាអធិករណ៍ទាំង ៤ អាបត្តិនោះ ចាត់ជាអាបត្តាធិករណ៍ ។ បណ្ដាសមថៈទាំង ៧ អាបត្តិនោះ រម្ងាប់ដោយសមថៈ ៣ គឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈ ក៏មានខ្លះ សម្មុខាវិន័យនិងតិណវត្ថារកៈ ក៏មានខ្លះ ។

ចប់ សមុច្ចយវារៈ ទី ៨ ។

វារៈទាំង ៨ ប្រការនេះ លោកកត់ត្រាទុកសម្រាប់ស្វាធ្យាយ ។

# ឧទ្ទាន គឺបញ្ជីរឿងនៃមហាវារៈនោះដូច្នេះ

[៤៦៨] រឿងព្រះមានព្រះភាគ (ទ្រង់បញ្ញត្តសិក្ខាបទនោះ ៗ) ក្នុងទីណា ១ រឿងបញ្ញត្តិទាំង ៩ យ៉ាង ១ រឿងព្រះមានព្រះភាគ ទ្រង់បញ្ញត្តវិន័យ ព្រោះអាស្រ័យប្រយោជន៍ប៉ុន្មានយ៉ាង ១ រឿងសង្គ្រោះអាបត្តិចូលនឹងវិបត្តិ ១ សមុដ្ឋាន និងអធិករណ៍ ១ សមថៈ ១ សមុច្ចយៈ (ការរួបរួម) ១ ។

[៤៦៩] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន មេថុនំ ធម្មំ បដិសេវនប្បច្ចយា ចារាជិកំ កត្ថ បញ្ញត្តំ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ បេ ។ កោធាភជន្តិ ។ យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន មេថុនំ ធម្មំ បដិសេវនប្បច្ចយា ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សុទិន្នំ កលន្ទបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សុទិន្នោ កលន្ទបុត្តោ បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ ទ្វេ អនុប្បញ្ញត្តិយោ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថប្បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។

[៤៦៩] បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺសេពមេថុនធម្ម បារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ព្រោះរឿងដូចម្តេច ។ បេ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។ បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺសេពមេថុនធម្ម បារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងវេសាលី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី សេពមេថុនធម្មនឹងស្រីជាប្រពន្ធពីដើម ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នបញ្ញត្តិឬទេ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ២ ឯអនុប្បន្នបញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ ។ សិក្ខាបទនោះ ជាសព្វត្ថបញ្ញត្តិ ឬជាបទេសបញ្ញត្តិ ។ សិក្ខាបទនោះជា សព្វត្ថបញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណបញ្ញត្តិ ឬជាអសាធារណបញ្ញត្តិ ។

សាធារណាប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញ-ត្តីតិ ។ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិមោក្ខុទ្ទេ-សានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ទុតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ ចារាជិ-កាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។ កោធាភជន្តិ ។ បរម្បរាភជំ ។

ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលិបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ[១] ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ ។ បេ ។

១ ជម្ពុសិរិវ្ហយេតិបិ បាឋោ ។

សិក្ខាបទនោះ ជាសាធារណបញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬ ជាឧភតោបញ្ញត្តិ ។ សិក្ខាបទនោះ ជាឧភតោបញ្ញត្តិ ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង ៥ សិក្ខាបទនោះ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ សិក្ខាបទនោះ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ២ ។ បណ្ដាវិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី ។ សិក្ខាបទនោះ ជាសីលវិបត្តិ ។ បណ្ដាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី ។ សិក្ខាបទនោះ ជាកងនៃអាបត្តិបារាជិក ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។ បេ ។ សិក្ខាបទនោះ បុគ្គលណា បាននាំមក ។ ព្រះថេរៈទាំងឡាយ ដូចមានឈ្មោះខាងក្រោមបាននាំត ៗ គ្នាមក ។

គឺព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១
និងព្រះមោគ្គលិបុត្តជាគម្រប់ ៥ អង្គ ១ ឯព្រះថេរៈទាំងនេះ នៅ
ក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី ។ តពីនោះមកព្រះអរហន្តទាំង-
ឡាយ គឺព្រះថេរៈឈ្មោះមហិន្ទ ១ ឥដ្ដិយៈ ១ ឧត្តិយៈ ១ សម្ពលៈ ១
។ បេ ។

ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[៤៧០] យេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អទិន្នំ អទិយនប្បច្ចយា បារាជិកំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ បញ្ញត្តំ ។ កំ អារព្ភាតិ ។ ធនិយំ កុម្ភការបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ធនិយោ កុម្ភការបុត្តោ រញ្ញោ ទារូនិ អទិន្នានិ អាទិយិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

ព្រះនាគត្ថេរទាំងនេះ លោកមានប្រាជ្ញាច្រើន ស្គាល់ច្បាស់នូវព្រះវិន័យ លោកឈ្លាសក្នុងមគ្គ បាននាំគ្នាប្រកាស នូវព្រះវិនយបិដក ទុកក្នុងតម្ពបណ្ណិទ្វីប គឺកោះលង្កា ។

[៤៧០] បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ហើយទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ បារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងធនិយភិក្ខុ ជាកូននៃស្មូនឆ្នាំង ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលធនិយភិក្ខុ ជាកូននៃស្មូនឆ្នាំង យកឈើព្រះរាជទ្រព្យ ដែលគេមិនបានឲ្យ ។ សិក្ខាបទនោះមានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។

[៤៧១] សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបនប្បច្ចយា ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលេ ភិក្ខូ អញ្ញមញ្ញំ ជីវិតា វោរោបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤៧២] អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបនប្បច្ចយា ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ វគ្គុមុទាតីរិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ វគ្គុមុទាតីរិយា ភិក្ខូ គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច

[៤៧១] បារាជិកសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺក្លែងធ្វើរាងកាយមនុស្សឲ្យធ្លាក់ចុះចាកជីវិត ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលភិក្ខុច្រើនរូបញុំាងគ្នានឹងគ្នាឲ្យធ្លាក់ចុះចាកជីវិត ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។

[៤៧២] បារាជិកសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ ដែលនៅប្រឞបច្នេរស្ទឹងវគ្គុមុទា ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកភិក្ខុនៅប្រឞបច្នេរស្ទឹងវគ្គុមុទា ពោលសរសើរគុណឧត្តរិមនុស្សធម្មនៃគ្នានឹងគ្នាដល់ពួកគ្រហស្ថ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិង

ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤៧៣] យេន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបក្កមិត្វា អសុចឹ មោចនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ បេ ។ កេនាភតន្តិ ។ យេន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបក្កមិត្វា អសុចឹ មោចនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ សេយ្យសកំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា សេយ្យសកោ ឧបក្កមិត្វា អសុចឹ មោចេសិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្ន-

ចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបាន តាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។

[៤៧៣] សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ ១០ យ៉ាង) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺព្យាយាមញ៉ាំងអសុចិឲ្យឃ្លាតចេញ សង្ឃាទិសេស-សិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ព្រោះរឿងដូចម្តេច ។ បេ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។ សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មា-សម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ ១០ យ៉ាង) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺ ព្យាយាមញ៉ាំងអសុចិឲ្យឃ្លាតចេញ សង្ឃាទិសេសសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងព្រះសេយ្យសកៈមានអាយុ ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងព្រះសេយ្យសកៈមានអាយុ ព្យាយាមញ៉ាំងអសុចិឲ្យឃ្លាតចេញ ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្ន-

ប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ អនុប្បន្ន-ប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថប្បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញ-ត្តីតិ ។ អសាធាណប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិមោក្ខុទ្ទេ-សានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និ-ទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆ-តីតិ ។ តតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អា-បត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ សង្ឃាទិសេសា-បត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋា-នេហិ សមុដ្ឋាតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។ កោធាភជន្តិ ។ បរម្បរាភជំ ។

ឧចាលិ ទាសកោ ចេវ

សោណកោ សិគ្គវោ តថា

មោគ្គលិបុត្តេន បញ្ចមា

ប្បញ្ញត្តិ ដែរឬទេ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណ-ប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯក-តោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ សិក្ខាបទនោះ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៣ ។ បណ្តាវិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី ។ ជាសីលវិបត្តិ ។ បណ្តាកងអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី ។ ជាកងនៃអាបត្តិសង្ឃាទិសេស ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។ បេ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។ ព្រះថេរៈទាំងឡាយ ដូចមាននាមខាងក្រោម បាននាំត ៗ គ្នាមក ។

គឺព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១
និងព្រះមោគ្គលិបុត្តជាគម្រប់ ៥ អង្គ ១ ព្រះថេរៈទាំងនេះ បិត

១៨៧



ឯតេ ជម្ពុសិរិវ្ហយេ ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ
។ បេ ។
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[៤៧៤] មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

នៅក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី ។ តអំពីនោះ មកមានព្រះអរហន្តទាំងឡាយទៀតគឺ ព្រះថេរៈឈ្មោះមហិន្ទ ១ ឥដ្ដិយៈ ១ ឧត្តិយៈ ១ សម្ពលៈ ១

។ បេ ។

ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន ចេះដឹងនូវព្រះវិន័យ ឈ្លាសក្នុងមគ្គ នាំគ្នាប្រកាសព្រះវិនយបិដក ទុកក្នុងតម្ពបណ្ណិទ្វីប ។

[៤៧៤] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺដល់នូវកាយសំសគ្គៈជាមួយនឹងមាតុគ្រាម (ប៉ះពាល់កាយមាតុគ្រាមជាដើម) ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងព្រះឧទាយិមានអាយុ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងព្រះឧទាយិមានអាយុ ដល់នូវកាយសំសគ្គៈជាមួយនឹងមាតុគ្រាម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។

[៤៧៥] មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន-
ប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា
បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។
កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមំ ទុដ្ឋុ-
ល្លាហិ វាចាហិ ឱភាសិ តស្មឹ វត្ថុស្មឹ ។ ឯកា
បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ
សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ
ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ
ន កាយតោ សិយា កាយតោ ច វាចតោ ច
ចិត្តតោ ច សមុដ្ឋាតិ ។

[៤៧៦] មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិចរិយាយ
វណ្ណំ ភាសនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោ-
តិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ
ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា
ឧទាយិ មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិចរិយាយ
វណ្ណំ អភាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ
អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៤៧៥] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺនិយាយលោមមាតុគ្រាមដោយសំដីថែចង់ ទ្រង់បញ្ញត្តក្នុងទីណា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងព្រះឧទាយិមានអាយុ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងព្រះឧទាយិមានអាយុ និយាយលោមមាតុគ្រាមដោយសំដីថែចង់ ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។

[៤៧៦] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺនិយាយសរសើរការបម្រើដោយកាមចំពោះខ្លួន ក្នុងសំណាក់នៃមាតុគ្រាម ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងព្រះឧទាយិមានអាយុ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងព្រះឧទាយិមានអាយុ និយាយសរសើរការបម្រើដោយកាមចំពោះខ្លួនក្នុងសំណាក់នៃមាតុគ្រាម សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ ។

[៤៧៧] សញ្ចរិត្តំ សមាបជ្ជនប្បច្ចយា សង្ឃាទិ-
សេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ
អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុ-
ស្មិន្តិ ។ អាយស្មា ឧទាយិ សញ្ចរិត្តំ សមាបជ្ជិ តស្មឹ
វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ
អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ
សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ
សិយា វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ
សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ
សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន
វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន
កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ
ច សមុដ្ឋាតិ ។

[៤៧៨] សញ្ញាចិកាយ កុដឹ ការាបនប្បច្ចយា
សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ អាឡវិយា បញ្ញ-
ត្តោ ។ កំ អារព្ភាតិ ។ អាឡវិកេ ភិក្ខូ អារព្ភ ។ កិស្មឹ
វត្ថុស្មិន្តិ ។ អាឡវិកា ភិក្ខូ សញ្ញាចិកាយ កុដឹ

[៤៧៧] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺប្រព្រឹត្តនិយាយដឹកនាំ ស្ត្រីដើម្បីបុរស ដឹកនាំបុរសដើម្បីស្ត្រី ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងព្រះឧទាយិមានអាយុ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងព្រះឧទាយិមានអាយុ ប្រព្រឹត្តនិយាយដឹកនាំស្ត្រីដើម្បីបុរស ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយនិងចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។

[៤៧៨] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺការប្រើគេឲ្យធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍ដោយខ្លួនឯង ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងដែនអាឡវី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ ដែលនៅក្នុងដែនអាឡវី ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលពួកភិក្ខុនៅក្នុងដែនអាឡវី ប្រើគេឲ្យធ្វើកុដិ

កោរាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អា-
បត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៤៧៩] មហល្លកំ វិហារំ ការាបនប្បច្ចយា សង្ឃា-
ទិសេសោ កត្ថ បញ្ញត្តោតិ ។ កោសម្ពិយា បញ្ញត្តោ ។
កំ អារព្ភាតិ ។ អាយស្មន្តំ ឆន្នំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។
អាយស្មា ឆន្នោ វិហារវត្ថុំ សោធេន្តោ អញ្ញតរំ ចេតិយរុក្ខំ
ឆេទាបេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អា-
បត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៤៨០] ភិក្ខុំ អមូលកេន បារាជិកេន ធម្មេន
អនុទ្ធំសនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។
រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ មេត្តិយភុម្មជ-
កេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ មេត្តិយភុម្មជកា
ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ អមូលកេន បារាជិកេន
ធម្មេន អនុទ្ធំសេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។
ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

ដោយការសូមគ្រឿងឧបករណ៍ដោយខ្លួនឯង ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ ។

[៤៧៩] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺការប្រើគេឲ្យធ្វើវិហារធំ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងព្រះឆន្នៈមានអាយុ ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលព្រះឆន្នៈមានអាយុ កាលនឹងជំរះទីដីនៃវិហារ ក៏ប្រើគេឲ្យកាប់ដើមឈើដែលជាទីគោរព ១ ដើម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ ។

[៤៨០] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះ ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុឈ្មោះមេត្តិយៈ និងភុម្មជកៈ ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងភិក្ខុឈ្មោះមេត្តិយៈ និងភុម្មជកៈ បានចោទព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិក មិនមានមូល ។ សិក្ខាបទនោះ មានតែបញ្ញត្ត ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ ។

[៤៨១] ភិក្ខុំ អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ មេត្តិយភុម្មជកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្ពំ មល្លបុត្តំ អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៤៨២] សង្ឃភេទកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ ទេវទត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ទេវទត្តោ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤៨១] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺការកាន់យកនូវលេសជាគ្រឿងអាងបន្តិចបន្តួច របស់អធិករណ៍ ជាចំណែកដទៃ ហើយចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិក ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុឈ្មោះមេត្តិយៈ និងភុម្មជកៈ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងភិក្ខុឈ្មោះមេត្តិយៈ និង ភុម្មជកៈ យកលេសជាគ្រឿងអាងបន្តិចបន្តួច របស់អធិករណ៍ជាចំណែកដទៃ ហើយចោទព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិក ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋានៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ ។

[៤៨២] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគម្រប់បីដង ក៏នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុឈ្មោះទេវទត្ត ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងភិក្ខុឈ្មោះទេវទត្ត ព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត ។

[៤៨៣] ភេទានុវត្តកានំ ភិក្ខូនំ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា សង្ឃាទិ-សេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុ-ស្មិន្តិ ។ សម្ពហុលា ភិក្ខូ ទេវទត្តស្ស សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា អហេសុំ វគ្គវាទកា តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤៨៤] ទុព្វចស្ស ភិក្ខុនោ យាវតតិយំ សមនុ-ភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ កោសម្ពិយា បញ្ញត្តោ ។ កំ អា-រព្ភាតិ ។ អាយស្មន្តំ ឆន្នំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឆន្នោ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ អកាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។

[៤៨៣] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដង ក៏នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលភិក្ខុច្រើនរូប ប្រព្រឹត្តតាមទេវទត្ត ដែលជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ហើយជាអ្នកពោលពាក្យប្រមូលពួក ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋានៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត ។

[៤៨៤] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺ ភិក្ខុដែលគេប្រដៅបានដោយក្រ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដង ក៏នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធព្រះឆន្នៈមានអាយុ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលព្រះឆន្នៈមានអាយុ កាលភិក្ខុទាំងឡាយ និយាយប្រដៅតាមធម៌ ក៏ធ្វើខ្លួនឲ្យគេស្ដីថា មិនបាន ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១

ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ ។ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤៨៥] កុលទូសកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេ-សោ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ អស្សជិបុនព្វសុកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អស្សជិបុនព្វសុកា ភិក្ខូ សង្ឃេន បព្វាជ-នីយកម្មកតា ភិក្ខូ ឆន្ទគាមិតា ទោសគាមិតា មោហ-គាមិតា ភយគាមិតា[1] ចាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[៤៨៦] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណាប្បច្ចយា ទុក្កដំ កត្ថ

---

១ ឆន្ទគាមិនោ ។ល។ ភយគាមិនោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត ។

[៤៨៥] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺភិក្ខុអ្នកទ្រុស្តត្រកូល កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់បីដង ក៏នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ត្រឡប់ជាបន្ទោសសង្ឃថា សង្ឃលុះក្នុងឆន្ទាគតិ លុះក្នុងទោសាគតិ លុះក្នុងមោហាគតិ លុះក្នុងភយាគតិ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋានៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត ។ បេ ។

[៤៨៦] អាបត្តិទុក្កដណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺការអាស្រ័យនូវសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក

បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ អកំសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

កត្ថប្បញ្ញត្តិវារំ និដ្ឋិតំ បឋមំ ។

[៤៨៧] មេថុនំ ធម្មំ បដិសេវនប្បច្ចយា កាតិ អាបត្តិយោ អាបជ្ជតិ ។ មេថុនំ ធម្មំ បដិសេវនប្បច្ចយា ចតស្សោ អាបត្តិយោ អាបជ្ជតិ អក្ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ បារាជិកស្ស យេភុយ្យេន ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ ថុល្លច្ចយស្ស វិវដកតេ មុខេ អច្ឆុបន្តំ អង្គជាតំ បវេសេតិ អាបត្តិ ទុក្កដស្ស ជតុមដ្ឋកេ បាចិត្តិយំ មេថុនំ ធម្មំ បដិសេវនប្បច្ចយា ឥមា ចតស្សោ អាបត្តិយោ អាបជ្ជតិ ។

អាបត្តិទុក្កដនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តិក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ បានបន្ទោឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះ ក្នុងទឹក ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។

ចប់ កត្ថប្បញ្ញត្តិវារៈ ជាបឋម ។

[៤៨៧] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យគឺការសេពមេថុនធម្ម ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ ៤ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម គឺភិក្ខុសេពមេថុនធម្ម នឹងសរីរៈសព ដែលសត្វមិនទាន់ទំពាស៊ី ត្រូវអាបត្តិបារាជិក ភិក្ខុសេពមេថុនធម្ម នឹងសរីរៈសព ដែលសត្វទំពាស៊ីដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុបញ្ចូលអង្គជាត (ខ្លួន) ទៅក្នុងមុខ-ទ្វារដែលបើកហា តែមិនឲ្យប៉ះពាល់ ត្រូវអាបត្តិទុក្កដ ភិក្ខុនីត្រូវអាបត្តិបាចិត្តិយៈ ព្រោះអង្គជាតិដែលធ្វើដោយជ័រឈើ ឬកាកលាក់ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិទាំង ៤ នេះ ព្រោះបច្ច័យគឺការសេពមេថុនធម្ម ។

[៤៨៨] អទិន្នំ អាទិយនប្បច្ចយា កតិ អាបត្តិ-យោ អាបជ្ជតិ ។ អទិន្នំ អាទិយនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ បញ្ចមាសកំ វា អតិរេកបញ្ច-មាសកំ វា អគ្ឃនកំ អទិន្នំ ថេយ្យសង្ខាតំ អាទិយ-តិ អាបត្តិ បារាជិកស្ស អតិរេកមាសកំ វា ឩនបញ្ច-មាសកំ វា អគ្ឃនកំ អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ អាបត្តិ ថុល្លច្ចយស្ស មាសកំ វា ឩនមាសកំ វា អគ្ឃន-កំ អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ អាបត្តិ ទុក្កដស្ស អទិន្នំ អាទិយនប្បច្ចយា ឥមា តិស្សោ អាបត្តិយោតិ អាបជ្ជតិ ។

[៤៨៩] សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបនប្បច្ច-យា កតិ អាបត្តិយោ អាបជ្ជតិ ។ សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ មនុស្សំ ឧទ្ទិស្ស ឱបាតំ ខណតិ បបតិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស បបតិតេ ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស មរតិ អាបត្តិ បារាជិកស្ស

[៤៨៨] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការកាន់យកទ្រព្យដែលគេមិនបានឲ្យ ។ ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការកាន់យកទ្រព្យដែលគេមិនបានឲ្យ គឺភិក្ខុមានថេយ្យចិត្តកាន់យកទ្រព្យមានតម្លៃ ៥ មាសក ឬច្រើនជាង ៥ មាសកឡើងទៅ ដែលគេមិនបានឲ្យ ត្រូវអាបត្តិបារាជិក ភិក្ខុមានថេយ្យចិត្ត កាន់យកទ្រព្យ មានតម្លៃច្រើនជាង ១ មាសក ឬថយអំពី ៥ មាសកមក ដែលគេមិនបានឲ្យ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុមានថេយ្យចិត្ត កាន់យកទ្រព្យមានតម្លៃ ៤ មាសក ឬថយចុះអំពី ១ មាសកមក ដែលគេមិនបានឲ្យ ត្រូវអាបត្តិទុក្កដ ភិក្ខុត្រូវអាបត្តិទាំង ៣ នេះ ព្រោះបច្ច័យ គឺការកាន់យកទ្រព្យដែលគេមិនបានឲ្យ ។

[៤៨៩] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការក្លែងញុំាងរាងកាយនៃមនុស្សឲ្យធ្លាក់ចុះចាកជីវិត ។ ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការក្លែងញុំាងរាងកាយនៃមនុស្ស ឲ្យធ្លាក់ចុះចាកជីវិត គឺភិក្ខុជីករណ្តៅ ចំពោះមនុស្ស ដោយតាំងចិត្តថា មនុស្សនឹងស្លាប់ ត្រូវអាបត្តិទុក្កដ កាលបើមនុស្សធ្លាក់ទៅហើយ មានទុក្ខវេទនាកើតឡើង ត្រូវអាបត្តិថុល្លច្ច័យ បើមនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក

សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបនប្បច្ចយា ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

[៤៩០] អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបនប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ អាបត្តិ បារាជិកស្ស យោ តេ វិហារេ វសតិ សោ ភិក្ខុ អរហាតិ ភណតិ បដិវិជានន្តស្ស អាបត្តិ ថុល្លច្ចយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបនប្បច្ចយា ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

[៤៩១] ឧបក្កមិត្វា អសុចឹ មោចនប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ ឧបក្កមិត្វា អសុចឹ មោចនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ចេតេតិ ឧបក្កមតិ ន មុច្ចតិ អាបត្តិ ថុល្លច្ចយស្ស បយោគេ ទុក្កដំ ។

ភិក្ខុត្រូវអាបត្តិទាំង ៣ នេះ ព្រោះបច្ច័យ គឺការក្លែងញុំាងរាងកាយនៃមនុស្សឲ្យធ្លាក់ចុះចាកជីវិត ។

[៤៩០] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺកិរិយាពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត (ក្នុងខ្លួន) ។ ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺកិរិយាពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត (ក្នុងខ្លួន) គឺភិក្ខុជាអ្នកមានប្រាថ្នាអាក្រក់ មានសេចក្តីប្រាថ្នាគ្របសង្កត់ ក៏ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត (ក្នុងខ្លួន) ត្រូវអាបត្តិបារាជិក ភិក្ខុពោលថា ភិក្ខុណា នៅក្នុងវិហាររបស់អ្នក ភិក្ខុនោះ ជាព្រះអរហន្ត កាលបើគេដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ កាលបើគេមិនដឹងសេចក្តីច្បាស់ ត្រូវអាបត្តិទុក្កដ ភិក្ខុត្រូវអាបត្តិទាំង ៣ នេះ ព្រោះបច្ច័យ គឺកិរិយាពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត (ក្នុងខ្លួន) ។

[៤៩១] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការព្យាយាមបញ្ចេញអសុចិ ។ ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺព្យាយាមបញ្ចេញអសុចិ គឺភិក្ខុគិតនឹងបញ្ចេញអសុចិ ក៏ព្យាយាមញុំាងអសុចិឲ្យឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុគិតនឹងបញ្ចេញអសុចិ ក៏ព្យាយាម ប៉ុន្តែទឹកអសុចិមិនឃ្លាតចេញ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលព្យាយាម ។

១៩៧

## មហាវិភង្គេ សោឡស មហាវារា កតាបត្តិវារំ

[៤៩២] កាយសំសគ្គំ សមាបជ្ជនប្បច្ចយា បញ្ច អាបត្តិយោ អាបជ្ជតិ អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គលស្ស អធក្ខកំ ឧព្ភជានុមណ្ឌលំ គហណំ សាទិយតិ អាបត្តិ បារាជិកស្ស ភិក្ខុ កាយេន កាយំ អាមសតិ អាបត្តិ សង្ឃាទិសេសស្ស កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស អង្គុលិបតោទកេ បាចិត្តិយំ កាយសំសគ្គំ សមាបជ្ជនប្បច្ចយា ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។

[៤៩៣] មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ វច្ចមគ្គំ បស្សាវមគ្គំ អាទិស្ស វណ្ណម្បិ ភណតិ អវណ្ណម្បិ ភណតិ អាបត្តិ សង្ឃាទិសេសស្ស វច្ចមគ្គំ បស្សាវមគ្គំ ឋបេត្វា អធក្ខកំ ឧព្ភជានុមណ្ឌលំ អាទិស្ស វណ្ណម្បិ ភណតិ អវណ្ណម្បិ ភណតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធំ អាទិស្ស វណ្ណម្បិ ភណតិ អវណ្ណម្បិ ភណតិ អាបត្តិ ទុក្កដស្ស ។

[៤៩២] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ ៥ ព្រោះបច្ច័យ គឺការដល់នូវកាយសំសគ្គៈ គឺភិក្ខុនីមានតម្រេក ហើយត្រេកអរនឹងការចាប់ ពាល់សរីរប្រទេស ខាងក្រោមដងកាំបិតចុះមក ខាងលើមណ្ឌលនៃជង្គង់ឡើងទៅនៃបុរសបុគ្គល ដែលមានតម្រេកដូចគ្នា ត្រូវអាបត្តិបារាជិក ភិក្ខុប៉ះពាល់កាយស្រីដោយកាយរបស់ខ្លួន ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុប៉ះពាល់នូវវត្ថុដែលជាប់ដោយកាយស្រី ដោយកាយរបស់ខ្លួន ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុប៉ះពាល់នូវវត្ថុដែលជាប់នឹងកាយស្រី ដោយវត្ថុដែលជាប់នឹងកាយរបស់ខ្លួន ត្រូវអាបត្តិទុក្កដ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះជន្លួញគឺម្រាមដៃ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិទាំង ៥ នេះ ព្រោះបច្ច័យ គឺការដល់នូវកាយសំសគ្គៈ ។

[៤៩៣] ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការនិយាយល្បួងមាតុគ្រាមដោយសំដីអាក្រក់ គឺភិក្ខុពោលសរសើរក្តី ពោលបង្អាប់ក្តី ចំពោះវច្ចមគ្គ ឬបស្សាវមគ្គ ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុមិនពោលចំពោះវច្ចមគ្គនិងបស្សាវមគ្គ គ្រាន់តែពោលសរសើរក្តី ពោលបង្អាប់ក្តី ចំពោះខាងក្រោមដងកាំបិតចុះមក ខាងលើមណ្ឌលនៃជង្គង់ឡើងទៅ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុពោលសរសើរក្តី ពោលបង្អាប់ក្តី ចំពោះវត្ថុដែលជាប់ដោយកាយ ត្រូវអាបត្តិទុក្កដ ។

[៤៩៤] អត្តកាមចារិចរិយាយ វណ្ណំ ភាសនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ សង្ឃាទិ-សេសស្ស បណ្ឌកស្ស សន្តិកេ អត្តកាមចារិចរិយា-យ វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយស្ស តិរច្ឆានគតស្ស សន្តិកេ អត្តកាមចារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទុក្កដស្ស ។

[៤៩៥] សញ្ចរិត្តំ សមាបជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ បដិគ្គណ្ហាតិ វីមំសតិ បច្ចាហរតិ អាបត្តិ សង្ឃាទិសេសស្ស បដិគ្គណ្ហាតិ វីមំសតិ ន បច្ចាហរតិ អាបត្តិ ថុល្លច្ចយស្ស បដិគ្គណ្ហាតិ ន វីមំ-សតិ ន បច្ចាហរតិ អាបត្តិ ទុក្កដស្ស ។

[៤៩៦] សញ្ញាចិកាយ កុដឹ ការាបនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ឯកបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។

[៤៩៤] ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការពោលនូវគុណនៃការបម្រើដោយកាមចំពោះខ្លួន គឺភិក្ខុពោលនូវគុណនៃការបម្រើដោយកាមចំពោះខ្លួន ក្នុងសំណាក់នៃមាតុគ្រាម ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុពោលនូវគុណនៃការបម្រើដោយកាមចំពោះខ្លួន ក្នុងសំណាក់នៃបណ្ឌក (ខ្ទើយ) ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុពោលនូវគុណនៃការបម្រើដោយកាមចំពោះខ្លួន ក្នុងសំណាក់នៃសត្វតិរច្ឆាន (ញី) ត្រូវអាបត្តិទុក្កដ ។

[៤៩៥] ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការប្រព្រឹត្តិនិយាយដឹកនាំស្ត្រីឲ្យបុរស ដឹកនាំបុរសឲ្យស្ត្រី គឺភិក្ខុទទួលពាក្យផង ទៅនិយាយប្រាប់ផង ត្រឡប់មកប្រាប់វិញផង ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទទួលពាក្យផង ទៅនិយាយប្រាប់ផង តែមិនត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុគ្រាន់តែទទួលពាក្យ តែមិនបានទៅនិយាយប្រាប់ផង មិនបានត្រឡប់មក (ប្រាប់) វិញផង ត្រូវអាបត្តិទុក្កដ ។

[៤៩៦] ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការប្រើគេឲ្យធ្វើកុដិដោយសូមគ្រឿងឧបករណ៍ដោយខ្លួនឯង គឺភិក្ខុកំពុងប្រើគេឲ្យធ្វើ ក្នុងប្រយោគដែលប្រើ ត្រូវអាបត្តិទុក្កដ កាលបើបាយអមួយដុំមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ កាលបើដុំបាយអនោះ មកដល់ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

មហាវិភង្គេ សោឡស មហាវារា កតាបត្តិវារំ

[៤៩៧] មហល្លកំ វិហារំ ការាបនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ឯកបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មិំ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។

[៤៩៨] ភិក្ខុំ អមូលកេន ចារាជិកេន ធម្មេន អនុទ្ធំសនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ អនោ-កាសំ ការាបេត្វា ចាវនាធិប្បាយោ វទេតិ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ឱកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទេតិ អាបត្តិ ឱមសវាទស្ស ។

[៤៩៩] ភិក្ខុំ អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧចាទាយ ចារាជិកេន ធម្មេន អនុទ្ធំសនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ អនោកាសំ ការាបេត្វា ចាវនាធិប្បាយោ វទេតិ អា-បត្តិ សង្ឃាទិសេសេន ទុក្កដស្ស ឱកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទេតិ អាបត្តិ ឱមសវាទស្ស ។

[៤៩៧] ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការប្រើគេឲ្យធ្វើវិហារធំ គឺភិក្ខុកំពុងប្រើគេឲ្យធ្វើ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើ កាលបើបាយអមួយដុំមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ កាលបើដុំបាយអនោះ មកដល់ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[៤៩៨] ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល គឺភិក្ខុមានបំណងដើម្បីឲ្យគេឃ្លាតចាកព្រហ្មចរិយធម៌ មិនបានសូមឱកាសហើយចោទ ត្រូវអាបត្តិទុក្កដ ព្រមទាំងសង្ឃាទិសេស ភិក្ខុមានបំណងដើម្បីជេរ តែបានសូមឱកាសហើយចោទ ត្រូវអាបត្តិឱមសវាទបាចិត្តិយៈ ។

[៤៩៩] ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការកាន់យកនូវលេសជាគ្រឿងអាងបន្តិចបន្តួច របស់អធិករណ៍ ជាចំណែកដទៃ ហើយចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក គឺភិក្ខុមានបំណងដើម្បីឲ្យគេឃ្លាតចាកព្រហ្មចរិយធម៌ មិនបានសូមឱកាសហើយចោទ ត្រូវអាបត្តិទុក្កដ ព្រមទាំងសង្ឃាទិសេស ភិក្ខុមានបំណងដើម្បីជេរ តែសូមឱកាសហើយចោទ ត្រូវអាបត្តិឱមសវាទបាចិត្តិយៈ ។

[៤០០] សង្ឃភេទកោ ភិក្ខុ យាវតតិយំ សមនុ-
ភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ
អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា
កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៤០១] ភេទានុវត្តកា ភិក្ខូ យាវតតិយំ សមនុ-
ភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ
អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា
កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៤០២] ទុព្វចោ ភិក្ខុ យាវតតិយំ សមនុភាសនាយ
នប្បដិនិស្សជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ
ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្ម-
វាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៩០០] ភិក្ខុអ្នកបំបែកសង្ឃ ត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដង ហើយនៅតែមិនលះបង់កម្មនោះចេញ គឺត្រូវអាបត្តិទុក្កដ ដោយសូត្រញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ដោយកម្មវាចាពីរលើក លុះចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស ។

[៩០១] ភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តតាមនូវភិក្ខុអ្នកបំបែកសង្ឃ ត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺកាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដង ហើយនៅតែមិនលះបង់កម្មនោះចេញ គឺ ត្រូវអាបត្តិទុក្កដ ដោយសូត្រញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ដោយកម្មវាចាពីរលើក លុះចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស ។

[៩០២] ភិក្ខុដែលគេប្រដៅក្រ ត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺ កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់បីដង ហើយនៅតែមិនលះបង់នូវកម្មនោះចេញ គឺ ត្រូវអាបត្តិទុក្កដ ដោយសូត្រញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ដោយកម្មវាចាពីរលើក លុះចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស ។

[៤០៣] កុលទូសកោ ភិក្ខុ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។

[៤០៤] អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណប្បច្ចយា ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណប្បច្ចយា ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។

កតាបត្តិវារំ និដ្ឋិតំ ទុតិយំ ។

[៤០៥] មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ

[៥០៣] ភិក្ខុអ្នកទ្រុស្តត្រកូល ត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺកាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដង ហើយនៅតែមិនលះបង់កម្មនោះចេញ គឺត្រូវអាបត្តិទុក្កដ ដោយសូត្រញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ដោយកម្មវាចាពីរលើក លុះចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។

[៥០៤] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក ។ ភិក្ខុត្រូវអាបត្តិទុក្កដ ១ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក ភិក្ខុត្រូវអាបត្តិ ១ នេះឯង ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក ។

ចប់ កតាបត្តិវារៈ ទី ២ ។

[៥០៥] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ២

វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ បេ ។ អដ្ឋានវិយំ បដិច្ច ឧជកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ការណាប្បច្ចយា អាបត្តិ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជតិ ។ អដ្ឋានវិយំ បដិច្ច ឧជកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ការណាប្បច្ចយា អាបត្តិ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជតិ អាចារវិបត្តឹ ។

វិបត្តិវារំ និដ្ឋិតំ តតិយំ ។

[៤០៦] មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិ-តា ។ មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ ចតូហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ បេ ។ អដ្ឋានវិយំ បដិច្ច ឧជកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ការណាប្បច្ចយា អាបត្តិ សត្តន្នំ អាបត្តិក្ខន្ធានំ

គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បេ ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាវិបត្តិទាំ ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។

ចប់ វិបត្តិវារៈ ទី ៣ ។

[៥០៦] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាកងនៃអាបត្តិទាំង ៧ សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាកងនៃអាបត្តិទាំង ៧ សង្គ្រោះដោយកងនៃអាបត្តិ ៤ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្ល-ច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បេ ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាកងនៃអាបត្តិទាំង ៧ សង្គ្រោះដោយ

កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោណប្បច្ចយា អាបត្តិ សត្តន្នំ អាបត្តិក្ខន្ធានំ ឯកេន អាបត្តិក្ខន្ធេន សង្គហិតា ទុក្កដាបត្តិក្ខន្ធេន ។

សង្គហិតវារំ និដ្ឋិតំ ចតុត្ថំ ។

[៤០៧] មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ បេ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោណប្បច្ចយា អាបត្តិ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោណប្បច្ចយា អាបត្តិ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

សមុដ្ឋានវារំ និដ្ឋិតំ បញ្ចមំ ។

កងនៃអាបត្តិប៉ុន្មាន ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាកងនៃអាបត្តិទាំង ៧ សង្គ្រោះដោយកងនៃអាបត្តិ ១ គឺកងនៃអាបត្តិទុក្កដ ។

ចប់ សង្គហិតវារៈ ទី ៤ ។

[៤០៧] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ ពួកអាបត្តិព្រោះបច្ច័យ គឺការសេពមេថុនធម្មបណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។ បេ ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។

ចប់ សមុដ្ឋានវារៈ ទី ៥ ។

[៤០៨] មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ បេ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណប្បច្ចយា អាបត្តិ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណ-ប្បច្ចយា អាបត្តិ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។

អធិករណវារំ និដ្ឋិតំ ឆដ្ឋំ ។

[៤០៩] មេថុនំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ មេថុ-នំ ធម្មំ បដិសេវនប្បច្ចយា អាបត្តិយោ សត្តន្នំ សមថា-នំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណប្បច្ចយា អាបត្តិ

[៥០៨] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្ដាអធិករណ៍ទាំង ៤ ជាអធិករណ៍អ្វី ។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្ដាអធិករណ៍ ទាំង ៤ ជាអាបត្តាធិករណ៍ ។ បេ ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក បណ្ដាអធិករណ៍ទាំង ៤ ជាអធិករណ៍អ្វី ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក បណ្ដាអធិករណ៍ទាំង ៤ ជាអាបត្តាធិករណ៍ ។

ចប់ អធិករណវារៈ ទី ៦ ។

[៥០៩] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្ដាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្ដាសមថៈទាំង ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន ។ បេ ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក បណ្ដាសមថៈ

សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ អជា-ននិយំ បដិច្ច ឧជកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណាប្បច្ចយា អាបត្តិ សត្តន្នំ សមថានំ តីហិ សមថេ-ហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេ-ន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមថវារំ និដ្ឋិតំ សត្តមំ ។

[៤១០] មេថុនំ ធម្មំ បដិសេវនប្បច្ចយា កតិ អា-បត្តិយោ អាបជ្ជតិ ។ មេថុនំ ធម្មំ បដិសេវនប្បច្ចយា ចតស្សោ អាបត្តិយោ អាបជ្ជតិ អក្ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ បារាជិកស្ស យេ-ភុយ្យេន ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ ថុល្លច្ចយស្ស វិវដកេ មុខេ អច្ឆុបន្តំ អង្គជាតំ បវេ-សេតិ អាបត្តិ ទុក្កដស្ស ជតុមដ្ឋកេ បាចិត្តិយំ មេថុនំ ធម្មំ បដិសេវនប្បច្ចយា ឥមា ចតស្សោ អាបត្តិយោ អា-បជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ

ទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈទាំង ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន ។

ចប់ សមថវារៈ ទី ៧ ។

[៤១០] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការសេពមេថុនធម្ម ។ ភិក្ខុ ភិក្ខុនីត្រូវអាបត្តិ ៤ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម គឺភិក្ខុសេពមេថុធម្ម នឹងសរីរៈ (សព) ដែលសត្វមិនទាន់ទំពាស៊ី ត្រូវអាបត្តិបារាជិក ភិក្ខុសេពមេថុនធម្ម នឹងសរីរៈ (សព) ដែលសត្វទំពាស៊ីដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុបញ្ចូលអង្គជាត (ខ្លួន) ទៅក្នុងមុខទ្វារ ដែលបើកហា តែមិនឲ្យប៉ះពាល់ ត្រូវអាបត្តិទុក្កដ ភិក្ខុនីត្រូវអាបត្តិបាចិត្តិយៈ ព្រោះអង្គជាតដែលធ្វើដោយជ័រឈើ ឬកាកលាក់ជ័រលីង[១] ភិក្ខុ ភិក្ខុនីត្រូវអាបត្តិទាំង ៤ នេះ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។

១ មើលភិក្ខុនីវិភង្គ បច្ចេកភាគទី ៥ បព្វៈ ១៦១ ទំព័រ ១២៦ ។

សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ចតូហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។ អជានវិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ អជានវិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណប្បច្ចយា

បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្ដាអធិករណ៍ទាំង ៤ ជាអធិករណ៍អ្វី ។ បណ្ដាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្ដាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្ដាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ សង្គ្រោះដោយកងនៃអាបត្តិ ៤ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្តមិនបានតាំងឡើងអំពីវាចាឡើយ ។ បណ្ដាអធិករណ៍ទាំង ៤ អាបត្តិទាំងនោះ ជាអាបត្តាធិករណ៍ ។ បណ្ដាសមថៈទាំង ៧ អាបត្តិទាំងនោះ រម្ងាប់ដោយសមណាថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខា-វិន័យនិងតិណវត្ថារកៈក៏មាន ។ បេ ។ ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក ។ ភិក្ខុត្រូវអាបត្តិទុក្កដ ១ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក

២០៧



ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ការណាប្បច្ចយា ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។ សា អាបត្តិ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជតិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ សា អាបត្តិ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជតិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ឯ-កេន អាបត្តិក្ខន្ធេន សង្គហិតា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ចាតិ ។

សមុច្ចយវារំ និដ្ឋិតំ អដ្ឋមំ ។

អដ្ឋ បច្ចយវារា និដ្ឋិតា ។

មហាវិភង្គេ សោឡស មហាវារា និដ្ឋិតា ។

ភិក្ខុត្រូវអាបត្តិ ១ នេះឯង ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក ។ បណ្តាវិបត្តិទាំង ៤ អាបត្តិនោះ រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ ជាអធិករណ៍អ្វី ។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិនោះ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ សង្គ្រោះដោយកងនៃអាបត្តិ ១ គឺកងនៃអាបត្តិទុក្កដ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។ បណ្តាអធិករណ៍ទាំង ៤ ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន ។

ចប់ សមុច្ចយវារៈ ទី ៨ ។

ចប់ បច្ចយវារៈទាំង ៨ ។

ចប់ មហាវារៈ ១៦ ក្នុងមហាវិភង្គ ។

# ភិក្ខុនីវិភង្គេ សោឡស មហាវារា

[៤១១] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ភិក្ខុនីនំ បញ្ចមំ បារាជិកំ កត្ថ បញ្ញត្តំ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តិ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តិ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ ចតុន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នំ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោ កឹ តត្ថ បាតិមោក្ខំ កឹ តត្ថ អធិបាតិមោក្ខំ កា វិបត្តិ កា សម្បត្តិ កា បដិបត្តិ ។

# ភិក្ខុនីវិភង្គ មហាវារៈ ១៦

[៥១១] បញ្ចមបារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្ត សិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្ត ដល់ពួកភិក្ខុនី បញ្ចមបារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ព្រោះរឿងដូចម្ដេច ។ ក្នុងសិក្ខាបទនោះ មាន បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តិ សា-ធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តិ ឯកតោបញ្ញត្តិ ឧភតោបញ្ញត្តិដែរឬ ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង ៤ សិក្ខាបទនោះ ចាត់ចូលក្នុងឧទ្ទេសណា រាប់ បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទីប៉ុន្មាន ។ បណ្ដា វិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី ។ បណ្ដាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិ នោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្ដាអធិករណ៍ទាំង ៤ អាបត្តិ នោះ ជាអធិករណ៍អ្វី ។ បណ្ដាសមថៈទាំង ៧ អាបត្តិនោះ រម្ងាប់ដោយ សមថៈប៉ុន្មាន ។ អ្វីដែលហៅថា វិន័យក្នុងសិក្ខាបទនោះ អ្វីដែលហៅ ថា អភិវិន័យក្នុងសិក្ខាបទនោះ អ្វីដែលហៅថា បាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីដែលហៅថា អធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីដែលហៅថា វិបត្តិ អ្វី ដែលហៅថា សម្បត្តិ អ្វីដែលហៅថា បដិបត្តិ (ក្នុងសិក្ខាបទនោះ) ។

កតិ អត្ថវសេ បដិច្ច ភគវតា ភិក្ខុនីនំ បឋមំ បារា-ជិកំ បញ្ញត្តំ ។ កា សិក្ខន្តិ ។ កា សិក្ខិតសិក្ខា ។ កត្ថ ឋិតំ ។ កា ធារេន្តិ ។ កស្ស វចនំ ។ កេ-នាភតន្តិ ។

[៤១២] យន្តេន ភគវតា ជានតា បស្សតា អរ-ហតា សម្មាសម្ពុទ្ធេន ភិក្ខុនីនំ បឋមំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សុន្ទរីនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សុន្ទរី-នន្ទា ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថប្បញ្ញត្តិ សាធារណប្បញ្ញត្តិ

បញ្ចមបារាជិកសិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី ព្រោះអាស្រ័យអំណាចនៃប្រយោជន៍ប៉ុន្មាន ។ ស្រីពួកណាសិក្សា ។ ស្រីពួកណា ដែលឈ្មោះថា មានសិក្ខាសិក្សាស្រេចហើយ ។ សិក្ខាបទនោះ ឋិតនៅក្នុងពួកស្រីណា ។ ពួកស្រីណាទ្រទ្រង់ ។ សិក្ខាបទនោះ ជាពាក្យរបស់បុគ្គលណា ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។

[៥១២] បញ្ចមបារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី បញ្ចមបារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងសុន្ទរីនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលសុន្ទរីនន្ទាភិក្ខុនីជាស្រីមានតម្រេកដោយរាគៈ ក៏ត្រេកអរនឹងការចាប់ពាល់កាយនៃបុរសបុគ្គល ដែលមានតម្រេកដោយរាគៈ (ដូច្នោះដែរ) ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិដែរឬ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ

អសាធារណបញ្ញត្តីតិ ។ អសាធារណបញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ ចតុន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ទុតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ បារាជិកាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតីតិ ។ ទ្វីហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច បដិញ្ញាតករណេន ច ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោតិ ។ បញ្ញត្តិ វិនយោ វិភត្តិ អភិវិនយោ ។ កឹ តត្ថ បាតិមោក្ខំ កឹ តត្ថ អធិបាតិមោក្ខន្តិ ។ បញ្ញត្តិ បាតិមោក្ខំ វិភត្តិ អធិបា-

ឬជាអសាធារណបញ្ញត្តិ ។ ជាអសាធារណបញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង ៤ សិក្ខាបទនោះ តើចាត់ចូលក្នុងឧទ្ទេសអ្វី រាប់បញ្ចូលក្នុងឧទ្ទេសអ្វី ។ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន ។ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទី ២ ។ បណ្ដាវិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី ។ ជាសីលវិបត្តិ ។ បណ្ដាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី ។ ជាកងនៃអាបត្តិបារាជិក ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។ បណ្ដាអធិករណ៍ទាំង ៤ អាបត្តិនោះជាអធិករណ៍អ្វី ។ ជាអាបត្តាធិករណ៍ ។ បណ្ដាសមថៈទាំង ៧ អាបត្តិនោះ រម្ងាប់ដោយសមថៈប៉ុន្មាន ។ រម្ងាប់ដោយសមថៈ ២ គឺដោយសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ ។ អ្វីហៅថា វិន័យក្នុងសិក្ខាបទនោះ អ្វីហៅថា អភិវិន័យក្នុងសិក្ខាបទនោះ ។ បញ្ញត្តិហៅថា វិន័យ ការចែកបទមាតិកាហៅថា អភិវិន័យ ។ អ្វីហៅថា បាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីហៅថា អធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ ។ បញ្ញត្តិហៅថា បាតិមោក្ខៈ ការចែកបទមាតិកាហៅថា

តិមោក្ខំ ។ កា វិបត្តីតិ ។ អសំវរោ វិបត្តិ ។ កា សម្បត្តីតិ ។ សំវរោ សម្បត្តិ ។ កា បដិបត្តីតិ ។ ន ឯវរូបំ ករិស្សាមីតិ យាវជីវំ អាចាណកោដិកំ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ កតិ អត្ថវសេ បដិច្ច ភគវតា ភិក្ខុនីនំ បឋមំ ចារាជិកំ បញ្ញត្តន្តិ ។ ទស អត្ថវសេ បដិច្ច ភគវតា ភិក្ខុនីនំ បឋមំ ចារាជិកំ បញ្ញត្តំ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ ភិក្ខុនីនំ និគ្គហាយ បេសលានំ ភិក្ខុនីនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ កា សិក្ខន្តីតិ ។ សេក្ខា ច បុថុជ្ជនកល្យា-

អធិប្បាតិមោក្ខ ។ អ្វីហៅថា វិបត្តិ ។ ការមិនសង្រួមហៅថា វិបត្តិ ។ អ្វីហៅថា សម្បត្តិ ។ ការសង្រួមហៅថា សម្បត្តិ ។ អ្វីហៅថា បដិបត្តិ ។ ភិក្ខុនីសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដល់អស់ជីវិត មានជីវិតជាទីបំផុត ដោយគិតថា អញនឹងមិនធ្វើអំពើយ៉ាងនេះ (ហៅថា បដិបត្តិ) ។ បញ្ចមបារាជិកសិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី ព្រោះអាស្រ័យអំណាចនៃប្រយោជន៍ប៉ុន្មាន ។ បញ្ចមបារាជិកសិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី ព្រោះអាស្រ័យអំណាចនៃប្រយោជន៍ទាំង ១០ យ៉ាង គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ១ ដើម្បីការសង្កត់សង្កិនពួកភិក្ខុនីដែលមិនមានខ្មាស ១ ដើម្បីការនៅជាសុខ ស្រួលដល់ពួកភិក្ខុនី ដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរាំងអាសវធម៌ទាំងឡាយដែលមានក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយដែលមានក្នុងបរលោក ១ ដើម្បីញុំាងពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាច្រើនឡើង ១ ដើម្បីញុំាងព្រះសទ្ធម្មឲ្យតាំងនៅមាំ ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។ ស្រីពួកណាសិក្សា (ក្នុងសិក្ខាបទនោះ) ។ ពួកស្រីដែលនៅជាសេក្ខបុគ្គល និងពួកស្រីដែលជ្រះថ្លាក្នុងកុសលធម៌តែជាបុថុជ្ជន

ណិកា ច សិក្ខន្តិ ។ កា សិក្ខិតសិក្ខាតិ ។ អរហន្តិយោ សិក្ខិតសិក្ខា ។ កត្ថ ឋិតន្តិ ។ សិក្ខាកាមាសុ ឋិតំ ។ កា ធារេន្តីតិ ។ យាសំ វត្តតិ តា ធារេន្តិ ។ កស្ស វចនន្តិ ។ ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ កេនាភដន្តិ ។ បរម្បរាភដំ ។

ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលិបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ[១] ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ
។ បេ ។
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

១ ជម្ពូសិរិវ្ហយេតិបិ បាឋោ ទិស្សតិ ។

វមែងសិក្សាក្នុងសិក្ខាបទនោះ ។ ពួកស្រីណាឈ្មោះថា មានសិក្ខាសិក្សាហើយ ។ ពួកភិក្ខុនីដែលជាព្រះអរហន្តឈ្មោះថា មានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះ ឋិតនៅក្នុងពួកស្រីណា ។ ឋិតនៅក្នុងពួកភិក្ខុនីដែលមានសេចក្តីប្រាថ្នាក្នុងសិក្ខា ។ ពួកភិក្ខុនីណាទ្រទ្រង់ ។ សិក្ខាបទនោះ ប្រព្រឹត្តទៅក្នុងពួកភិក្ខុនីណា ពួកភិក្ខុនីនោះ តែងទ្រទ្រង់ (នូវសិក្ខាបទនោះ) ។ សិក្ខាបទនោះ ជាពាក្យរបស់បុគ្គលណា ។ ជាពាក្យរបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។ (ព្រះថេរៈទាំងឡាយដូចមាននាមខាងក្រោមនេះ) នាំ ត ៗ គ្នាមក ។

គឺព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១ ព្រះមោគ្គលិបុត្តជាគម្រប់ ៥ អង្គ ១ ឯព្រះថេរៈទាំងនេះ ឋិតនៅក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី ។ តអំពីនោះមក មានព្រះថេរៈទាំងឡាយគឺព្រះថេរៈឈ្មោះមហិន្ទ ១ ឥដ្ដិយៈ ១ ឧត្តិយៈ ១ សម្ពលៈ ១

ៗ បេ ៗ

ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន ចេះដឹងព្រះវិន័យ ឈ្លាសក្នុងមគ្គ បានប្រកាសនូវព្រះវិនយបិដក ទុកក្នុងតម្ពបណ្ណិទ្វីប គឺកោះលង្កា ។

២១៣

ភិក្ខុនីវិភង្គេ សោឡស មហាវារា អដ្ឋ បារាជិកា

[៤១៣] យេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ភិក្ខុនីនំ ឆដ្ឋំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី ជានំ បារាជិកំ ធម្មំ អជ្ឈាបន្នំ ភិក្ខុនឹ នេវ អត្តនា បដិចោទេសិ ន គណស្ស អារោចេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤១៤] ភិក្ខុនីនំ សត្តមំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ អនុវត្តិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

[៥១៣] ឆដ្ឋបារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្តដល់ភិក្ខុនីទាំងឡាយ ឆដ្ឋបារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុនីឈ្មោះថុល្លនន្ទា ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងថុល្លនន្ទាភិក្ខុនីដឹងហើយមិនចោទភិក្ខុនី ដែលត្រូវអាបត្តិបារាជិកដោយខ្លួនឯង ទាំងមិនបានប្រាប់ដល់គណៈ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត ។

[៥១៤] សត្តមបារាជិកសិក្ខាបទសម្រាប់ភិក្ខុនីទាំងឡាយ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី ប្រព្រឹត្តតាមភិក្ខុឈ្មោះអរិដ្ឋៈ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ) ។

[៤១៥] ភិក្ខុនីនំ អដ្ឋមំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អដ្ឋមំ វត្ថុំ បរិបូរេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

អដ្ឋ បារាជិកា និដ្ឋិតា ។

## តស្សុទ្ទានំ

[៤១៦] មេថុនាទិន្នាទានញ្ច

មនុស្សវិគ្គហុត្តរិ

កាយសំសគ្គំ ឆាទេតិ

ឧក្ខិត្តា អដ្ឋវត្ថុកា

បញ្ញាបេសិ មហាវីរោ

ឆេជ្ជវត្ថុ អសំសយាតិ ។

[៥១៥] អដ្ឋមបារាជិកសិក្ខាបទសម្រាប់ភិក្ខុនីទាំងឡាយ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនីបំពេញវត្ថុគម្រប់ ៨ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ) ។

ចប់ បារាជិក ៨ ។

# ឧទ្ទាននៃបារាជិកសិក្ខាបទនោះដូច្នេះ

[៥១៦] រឿងភិក្ខុនីសេពមេថុនធម្ម ១ ភិក្ខុនីលួចទ្រព្យគេ ១ ភិក្ខុនីសម្លាប់មនុស្ស ១ ភិក្ខុនីពោលអួតឧត្តរិមនុស្សធម្ម ១ ភិក្ខុនីត្រេកអរនឹងកាយសំសគ្គៈ ១ ភិក្ខុនីបិទបាំងទោសរបស់ភិក្ខុនីផងគ្នា ១ ភិក្ខុនីប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្ត ១ ភិក្ខុនីបំពេញវត្ថុទាំង ៨ មានត្រេកអរនឹងចាប់ដៃនៃបុរសជាដើម[១] ១ ព្រះពុទ្ធជាមហាវីរៈ (មានព្យាយាមធំ) ទ្រង់បញ្ញត្តបារាជិកទាំង ៨ ហៅថា ឆេជ្ជវត្ថុ គឺវត្ថុដាច់ចាកភាវៈជាភិក្ខុនី ដោយឥតសង្ស័យ ។

---

១ មើលភិក្ខុនីវិភង្គបច្ចេកភាគទី ៥ តាំងពីបព្វៈ ២៦ ទំព័រ ៣០ ដល់បព្វៈ ២៩ ទំព័រ ៣៤ ។

ភិក្ខុនីវិភង្គេ សោឡស មហាវារា ទស សង្ឃាទិសេសា

[៤១៧] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧស្សុយវាទិកាយ[1] ភិក្ខុនិយា អដ្ដំ ករោន្តិយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ បេ ។ កោជាភជន្តិ ។

[៤១៨] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧស្សុយវាទិកាយ ភិក្ខុនិយា អដ្ដំ ករោន្តិយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី ឧស្សុយវាទិកា វិហរិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នបញ្ញត្តីតិ ។ ឯកា បញ្ញត្តិ អនុប្បញ្ញត្តិ

១ ឱ. ម. ឧស្សយវាទិកាយ ។

[៥១៧] សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្តដល់ភិក្ខុនី ដែលពោលពាក្យដោយសេចក្តីច្រណែន បានធ្វើនូវដំណើរកើតក្តី សង្ឃាទិសេសសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ព្រោះរឿងដូចម្តេច ។ បេ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។

[៥១៨] សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្តដល់ភិក្ខុនី ដែលពោលពាក្យដោយសេចក្តីច្រណែន បានធ្វើនូវដំណើរកើតក្តី សង្ឃាទិសេសសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីប្រព្រឹត្តពោលពាក្យដោយសេចក្តីច្រណែន (ប្តឹងផ្តល់) ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិដែរឬ ។ ក្នុងសិក្ខាបទនោះ មានតែបញ្ញត្តិ ១ ឯអនុប្បញ្ញត្តិ

អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថប្បញ្ញត្តិ បទេស-ប្បញ្ញត្តីតិ ។ សព្វត្ថប្បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសា-ធារណប្បញ្ញត្តីតិ ។ អសាធារណប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ ចតុន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ តតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិ-ក្ខន្ធោតិ ។ សង្ឃាទិសេសាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិ-សមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។ កោ-ធាភជន្តិ ។ បរម្បាភជំ ។ បេ ។

និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៤ សិក្ខាបទនោះ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៣ ។ បណ្តាវិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី ។ ជាសីលវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី ។ ជាកងនៃអាបត្តិសង្ឃាទិសេស ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ តាំងឡើងដោយសមុដ្ឋាន ២ គឺតាំងឡើងអំពីកាយនិងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។ បេ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។ ព្រះថេរៈទាំងឡាយបាននាំត ៗ គ្នាមក ។ បេ ។

[៤១៩] ចោរី វុដ្ឋាបេន្តិយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី ចោរឹ វុដ្ឋាបេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៦៣៦] *ភិក្ខុនីសួរប្រស្នានឹងភិក្ខុ ដែលខ្លួនមិនបានសូមឱកាស (ជាមុន) ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប សួរប្រស្នានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស (ជាមុន) ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងបទសោធម្មសិក្ខាបទ) ។*

[៦៣៧] *ភិក្ខុនីមិនមានសំពត់ចោមពុង ចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុនីមួយរូប មិនមានសំពត់ចោមពុងចូលទៅកាន់ស្រុក ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន ។*

ចប់ ឆត្តុបាហនវគ្គ ទី ៩ ។

ចប់ ពួកខុទ្ទកសិក្ខាបទ មានចំនួន ៩ វគ្គ តែប៉ុណ្ណោះ ។

# តស្សុទ្ទានំ

[៦៣៨] លសុណំ សំហារេ លោមំ
តលមជ្ជញ្ច សុទ្ធិកំ
កុញ្ជន្តាមកជញ្ញានំ
ទ្វេ វិឃាសេន ឧស្សជា
អន្ធការេ បដិច្ឆន្នេ
អជ្ឈោកាសេ រថិកាយ ច
បុរេ បច្ឆា វិកាលេ ច
ឧត្តហិ និរយេ រជិ
ឧក្កោដកា វិសិព្វេត្វា
បញ្ចាហិកំ សង្កមនីយំ
គណំ វគ្គសមណំ
ឧព្វលំ កាបិនេន ច

# ឧទ្ទានគឺបញ្ជីរឿងនៃខុទ្ទកសិក្ខាបទនោះដូច្នេះ

[៦៣៨] រឿងភិក្ខុនីឲ្យគេដកខ្ទឹម ១ ភិក្ខុនីដករោមក្នុងទីចង្អៀត ១ ភិក្ខុនីប្រហារផ្ទៃនិមិត្ត ១ ភិក្ខុនីធ្វើរូបអង្គជាត ១ ភិក្ខុនីលាងនិមិត្ត ១ ភិក្ខុនីបម្រើភិក្ខុកំពុងឆាន់ ១ ភិក្ខុនីសូមស្រូវស្រស់ ១ ភិក្ខុនីចោលរបស់ដែលសល់មានពីររឿង ១ ភិក្ខុនីទៅមើលរបាំ ១ ភិក្ខុនីទៅជាមួយនឹងបុរសក្នុងទីងងឹត ១ ភិក្ខុនីទៅជាមួយនឹងបុរសក្នុងទីកំបាំង ១ ភិក្ខុនីនៅជាមួយនឹងបុរសក្នុងទីវាល ១ ភិក្ខុនីនៅជាមួយនឹងបុរសក្នុងច្រកផ្លូវ ១ ភិក្ខុនីចូលទៅកាន់ត្រកូលក្នុងវេលាមុនភត្ត ១ ក្រោយភត្ត ១ ក្នុងវេលាវិកាល ១ ភិក្ខុនីពោលទោសគេ ដោយសេចក្តីប្រកាន់អាក្រក់ ១ ភិក្ខុនីប្រទេចផ្តាសាដោយនរក ១ ភិក្ខុនីវាយខ្លួនឯងហើយយំ ១ ភិក្ខុនីមានកាយអាក្រាតងូតទឹក ១ ភិក្ខុនីរុះចីវរ ១ ភិក្ខុនីញ៉ាំងវារៈនៃសង្ឃាដីឲ្យកន្លងហួស ៥ ថ្ងៃ ១ ភិក្ខុនីប្រើសង្កមនីយចីវរ ១ ភិក្ខុនីធ្វើចីវរលាភរបស់គណៈឲ្យខូច ១ ភិក្ខុនីឃាត់ការចែកចីវរ ១ ភិក្ខុនីឲ្យសមណចីវរ ដល់គ្រហស្ថជាដើម ១ ភិក្ខុនីញ៉ាំងសម័យចីវរកាលឲ្យកន្លងទៅដោយចង់បានចីវរទុព្វលភាព ១ ភិក្ខុនីឃាត់ការដកកឋិន ១

ភិក្ខុនីវិភង្គេ សោឡស មហាវារា បាចិត្តិយេ ឧទ្ទានគាថា

ឯកមញ្ចត្ថរណោន[១]
សញ្ចិច្ច សហជីវិនី
ទត្វា សំសដ្ឋអន្តោ ច
តិរោ វស្សំ ន បក្កមេ
រាជា អាសន្ទិ សុត្តញ្ច
តិហី រូបសមេន ច
ទទេ ចីវរាវសថំ
បរិយាបុណាញ្ច វាចយេ
អារាមក្កោសចណ្ឌី ច
កុញ្ជេយ្យ កុលមច្ឆរី
វសេ បវារណោវាទា

១ ឱ. ម. ឯកមញ្ចត្ថរណេន ច ។

ភិក្ខុនីដេកលើគ្រែមួយជាមួយគ្នា ១ ភិក្ខុនីដេកលើកម្រាលមួយជាមួយគ្នា ១ ភិក្ខុនីក្លែងធ្វើសេចក្តីអផ្សុកដល់ភិក្ខុនីផងគ្នា ១ ភិក្ខុនីមិនបម្រើកូនសិស្សដែលមានជំងឺ ១ ភិក្ខុនីឲ្យលំនៅដល់ភិក្ខុនីផងគ្នា ១ ភិក្ខុនីនៅច្រឡូកច្រឡំ ដោយគ្រហស្ថ ១ ភិក្ខុនីដើរទៅខាងក្នុងដែន ១ ដើរទៅខាងក្រៅដែន ១ ភិក្ខុនីដើរទៅកាន់ចារិកខាងក្នុងវស្សា ១ ភិក្ខុនីចេញវស្សាហើយមិនទៅកាន់ចារិក ១ ភិក្ខុនីទៅមើលព្រះរាជដំណាក់ ១ ភិក្ខុនីប្រើប្រាស់អាសន្ទិ ១ ភិក្ខុនីកាវសូត្រ ឬអំបោះ ១ ភិក្ខុនីបម្រើគ្រហស្ថ ១ ភិក្ខុនីមិនរម្ងាប់អធិករណ៍ ១ ភិក្ខុនីឲ្យខាទនីយ-ភោជនីយៈដល់គ្រហស្ថជាដើម ១ ភិក្ខុនីមិនលះអាវសថចីវរ ១ ភិក្ខុនីមិនលះផ្ទះសំណាក់ ១ ភិក្ខុនីរៀនតិរច្ឆានវិជ្ជា ១ ភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា ១ ភិក្ខុនីចូលទៅកាន់អារាមដែលមានភិក្ខុដោយមិនបានប្រាប់ជាមុន ១ ភិក្ខុនីជេរភិក្ខុ ១ ភិក្ខុនីគម្រាមគណៈភិក្ខុនីដោយចិត្តកំណាច ១ ភិក្ខុនីហាមភោជនហើយឆាន់ភោជនឯទៀត ១ ភិក្ខុនីកំណាញ់ត្រកូល ១ ភិក្ខុនីនៅចាំវស្សាក្នុងអាវាសដែលមិនមានភិក្ខុនី ១ ភិក្ខុនីនៅចាំវស្សាហើយមិនបវារណាក្នុងឧភតោសង្ឃ ១ ភិក្ខុនីមិនទៅទទួលឱវាទ ១

ទ្វេ ជម្មា បសាខេន ច

គព្ភិនី ធាយន្តី ឆជម្មេ

អសម្មតូនទ្វាទស

បរិបុណ្ណាញ្ញ សង្ឃេន

សហាវុដ្ឋាបនេន ច

កុមារី ទ្វេ ច សង្ឃេន

ទ្វាទសាសម្មតេន ច

អលំ សចេ[១] ទ្វេ វស្សំ

១ ឱ. ម. សចេ ច ។

ភិក្ខុនីមិនប្រាថ្នាធម៌ ២ ប្រការ គឺសួរឧបោសថ ទាំងចូលទៅស្តាប់ឱវាទ ១ ភិក្ខុនីដោះបួស ឬដំបៅក្នុងបសាខប្រទេស ១ ភិក្ខុនីបំបួសស្ត្រីមានគភ៌ ១ បំបួសស្ត្រីមានកូននៅបៅ ១ បំបួសសិក្ខមានាដែលមិនទាន់បានសិក្សាសិក្ខា ក្នុងធម៌ ៦ ប្រការ ១ បំបួសសិក្ខាមានាដែលសង្ឃមិនបានសន្មត ១ បំបួសស្ត្រីជាគិហិគតា ដែលមានអាយុមិនទាន់គ្រប់ ១២ ឆ្នាំ ១ បំបួសស្ត្រីជាគិហិគតា ដែលមានអាយុគ្រប់ ១២ ឆ្នាំហើយ តែមិនបានសិក្សាសិក្ខាគ្រប់ ២ ឆ្នាំ ១ បំបួសស្ត្រីជាគិហិគតា ដែលសង្ឃមិនបានសន្មត ១ បំបួសកូនសិស្សហើយមិនបានអនុគ្រោះ ១ ភិក្ខុនីមិនបម្រើបវត្តិនី ១ ភិក្ខុនីមិនគ្រប់គ្រងកូនសិស្ស ១ ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតាមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ ១ ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតា ដែលមិនទាន់បានសិក្សាសិក្ខាគ្រប់ ២ ឆ្នាំ ១ ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតាដែលសង្ឃមិនបានសន្មត ១ ភិក្ខុនីមានវស្សាមិនគ្រប់ ១២ ហើយបំបួសគេ ១ ភិក្ខុនីដែលសង្ឃមិនបានសន្មត ហើយបំបួសគេ ១ ភិក្ខុនីដែលសង្ឃឃាត់មិនឲ្យបំបួសគេ ១ ភិក្ខុនីនិយាយនឹងសិក្ខមានាថា បើនាងឲ្យចីវរយើង ៗ នឹងបំបួសនាង ១ ភិក្ខុនីនិយាយនឹងសិក្ខមានាថា បើនាងបម្រើយើងគ្រប់ ២ ឆ្នាំ

ភិក្ខុនីវិភង្គេ សោឡស មហាវារា បាចិត្តិយេ ឧទ្ទានគាថា

សំសដ្ឋា សាមិកេន ច
ចារិកាសិកានុវស្សំ
ទុវេ វុដ្ឋាបនេន ច
ឆត្តុយានេន សង្ឃាណិ
ឥត្ថាលង្ការវណ្ណកេ
បិញ្ញាកា ភិក្ខុនី ចេវ
សិក្ខា ច សាមណេរិកា
គិហី ភិក្ខុស្ស បុរតោ
អនោកាសំ សង្កច្ចិកាតិ ។

តេសំ វគ្គានំ ឧទ្ទានំ

[៦៣៩] លសុណាន្ធការា ឆ្នាំ
តុវដ្ដា ចិត្តាគារកា
អារាមំ គព្ភិនី ចេវ
កុមារី ឆត្តុចាហនាតិ ។

យើងនឹងបំបួសនាង ១ ភិក្ខុនីបំបួសសិក្ខមានាដែលនៅច្រឡូកច្រឡំដោយបុរស ១ បំបួសស្ត្រីដែលប្តីមិនបានអនុញ្ញាត ១ បំបួសសិក្ខមានាដោយឲ្យឆន្ទៈឈ្មោះបារិវាសិក ១ បំបួសគេរាល់ឆ្នាំ ១ បំបួសស្ត្រី ២ នាក់ក្នុងមួយឆ្នាំ ១ ភិក្ខុនីមិនមានជំងឺប្រើប្រាស់ឆត្រ ១ ទៅដោយយាន ១ ភិក្ខុនីប្រើប្រាស់ខ្សែក្រវាត់ ១ ប្រើប្រាស់គ្រឿងប្រដាប់ស្ត្រី ១ ងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាប ១ ងូតទឹកដោយគ្រឿងអប់និងម្សៅ ១ ភិក្ខុនីប្រើភិក្ខុនីផងគ្នា ឲ្យគក់ រឹតច្របាច់ ១ ឲ្យសិក្ខមានាគក់រឹតច្របាច់ ១ ឲ្យសាមណេរីគក់ រឹតច្របាច់ ១ ឲ្យស្ត្រីគ្រហស្ថគក់ រឹតច្របាច់ ១ ភិក្ខុនីអង្គុយលើអាសនៈពីមុខភិក្ខុ ១ ភិក្ខុនីសួរប្រស្នានឹងភិក្ខុ ដែលខ្លួនមិនបានសូមឱកាសជាមុន ១ ភិក្ខុនីមិនមានសំពត់ចោមពុងចូលទៅកាន់ស្រុក ១ ។

## ឧទ្ទាននៃវគ្គទាំង ៩ នោះដូច្នេះ

[៦៣៩] លសុណវគ្គ ១ អន្ធការវគ្គ ១ នហានវគ្គ ១ តុវដ្ដវគ្គ ១ ចិត្តាគារវគ្គ ១ អារាមវគ្គ ១ គព្ភិនីវគ្គ ១ កុមារីភូតវគ្គ ១ ឆត្តុបាហនវគ្គ ១ ។

[៦៤០] សប្បឹ វិញ្ញាបេត្វា កុញ្ជន្តិយា ចាជិនេស-និយំ កាត្វ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខុនិយោ សប្បឹ វិញ្ញាបេត្វា កុញ្ជឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញ-ត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៦៤១] តេលំ វិញ្ញាបេត្វា កុញ្ជន្តិយា ចាជិនេស-និយំ កាត្វ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខុនិយោ តេលំ វិញ្ញាបេត្វា កុញ្ជឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៦៤២] មធុំ វិញ្ញាបេត្វា កុញ្ជន្តិយា ចាជិនេសនិយំ កាត្វ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។

[៦៤០] ភិក្ខុនីសូមទឹកដោះរាវមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយាភិក្ខុនីសូមទឹកដោះរាវមកឆាន់ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៤ ។

[៦៤១] ភិក្ខុនីសូមប្រេងមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយាភិក្ខុនីសូមប្រេងមកឆាន់ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៤ ។

[៦៤២] ភិក្ខុនីសូមទឹកឃ្មុំមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងរ៉ាវដូចម្តេច ។

ឆព្វគ្គិយា ភិក្ខុនិយោ មធុំ វិញ្ញាបេត្វា ភុញ្ជិំសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៦៤៣] ផាណិតំ វិញ្ញាបេត្វា ភុញ្ជន្តិយា ចាដិទេសនីយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខុនិយោ ផាណិតំ វិញ្ញាបេត្វា ភុញ្ជិំសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្ប-ញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៦៤៤] មច្ឆំ វិញ្ញាបេត្វា ភុញ្ជន្តិយា ចាដិទេសនី-យំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភា-តិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខុនិយោ មច្ឆំ វិញ្ញាបេត្វា ភុញ្ជិំសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី សូមទឹកឃ្មុំមកឆាន់ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៤ ។

[៦៤៣] ភិក្ខុនីសូមទឹកអំពៅមកឆាន់ ត្រូវអាបត្តិបាដិសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី បានសូមទឹកអំពៅមកឆាន់ ។ សិក្ខា-បទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៤ ។

[៦៤៤] ភិក្ខុនីសូមត្រីមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី សូមត្រីមកឆាន់ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៤ ។

[៦៤៥] មំសំ វិញ្ញាបេត្វា កុញ្ចន្តិយា ចាដិទេស-
នីយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ
អារព្ភាតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ
វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខុនិយោ មំសំ វិញ្ញាបេត្វា
កុញ្ចឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្ប-
ញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ
សមុដ្ឋាតិ ។

[៦៤៦] ខីរំ វិញ្ញាបេត្វា កុញ្ចន្តិយា ចាដិទេសនីយំ
កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។
ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។
ឆព្វគ្គិយា ភិក្ខុនិយោ ខីរំ វិញ្ញាបេត្វា កុញ្ចឹសុ តស្មឹ
វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ
អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៦៤៧] ទធឹ វិញ្ញាបេត្វា កុញ្ចន្តិយា ចាដិទេសនីយំ
កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។
ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិ-
យា ភិក្ខុនិយោ ទធឹ វិញ្ញាបេត្វា កុញ្ចឹសុ តស្មឹ វត្ថុស្មឹ ។

[៦៤៥] ភិក្ខុនីសូមសាច់មកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី សូមសាច់មកឆាន់ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៤ ។

[៦៤៦] ភិក្ខុនីសូមទឹកដោះស្រស់មកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី សូមទឹកដោះស្រស់មកឆាន់ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៤ ។

[៦៤៧] ភិក្ខុនីសូមទឹកដោះជូរមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី សូមទឹកដោះជូរមកឆាន់ ។

ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

អដ្ឋ បាដិទេសនីយា និដ្ឋិតា ។

## តស្សុទ្ទានំ

[៦៤៨] សប្បិ តេលំ មធុញ្ចេវ
ផាណិតំ មច្ឆមេវ ច
មំសំ ខីរំ ទធិញ្ចាបិ
វិញ្ញាបេត្វាន ភិក្ខុនី
បាដិទេសនីយា អដ្ឋ
សយម្ពុទ្ធេន ទេសិតាតិ ។

យេ សិក្ខាបទា ភិក្ខុវិភង្គេ វិត្ថារិតា តេ សង្ខិបិត្វា ភិក្ខុនីវិភង្គេ ។

កត្ថប្បញ្ញត្តិវារំ និដ្ឋិតំ បឋមំ ។

សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយអំពីវាចានិងចិត្តក៏មាន ។

ចប់ បាដិទេសនីយៈទាំង ៨ ។

# ឧទ្ទានគឺបញ្ជីរឿងនៃបាដិទេសនីយៈនោះដូច្នេះ

[៦៤៨] រឿងភិក្ខុនីសូមទឹកដោះរាវ ១ ប្រេង ១ ទឹកឃ្មុំ ១ ទឹកអំពៅ ១ ត្រី ១ សាច់ ១ ទឹកដោះស្រស់ ១ ទឹកដោះជូរ ១ បាដិទេសនីយៈទាំង ៨ ព្រះសយម្ភូទ្រង់សម្តែងហើយយ៉ាងនេះ ។

សិក្ខាបទទាំងឡាយណា ដែលយើងឲ្យពិស្តារហើយ ក្នុងភិក្ខុវិភង្គ សិក្ខាបទទាំងនោះ យើងសម្តែងដោយសង្ខេប ក្នុងភិក្ខុនីវិភង្គ ។

ចប់ កត្ថប្បញ្ញត្តិវារៈ ជាដំបូង ។

[៦៤៩] អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គ-លស្ស កាយសំសគ្គំ សាទិយន្តី កតិ អាបត្តិយោ អា-បជ្ជតិ ។ អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ អធក្ខកំ ឧព្ភជានុមណ្ឌលំ គហណំ សាទិយតិ អាបជ្ជតិ បារាជិកស្ស ឧព្ភក្ខកំ អធោជានុមណ្ឌលំ គហណំ សាទិយតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធំ គហណំ សាទិយតិ អាបត្តិ ទុក្កដស្ស អវស្សុតា ភិក្ខុនី អវស្សុ-តស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តី ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

[៦៥០] វជ្ជប្បដិច្ឆាទិកា ភិក្ខុនី វជ្ជំ បដិច្ឆាទេន្តី កតិ អាបត្តិយោ អាបជ្ជតិ ។ វជ្ជប្បដិច្ឆាទិកា ភិក្ខុនី វជ្ជំ បដិច្ឆាទេន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ ជានំ បារាជិកំ ធម្មំ បដិច្ឆាទេតិ អាបត្តិ បារាជិកស្ស វេមតិ-កា បដិច្ឆាទេតិ អាបត្តិ ថុល្លច្ចយស្ស អាចារវិបត្តឹ បដិច្ឆាទេតិ អាបត្តិ ទុក្កដស្ស វជ្ជប្បដិច្ឆាទិកា ភិក្ខុនី វជ្ជំ បដិច្ឆាទេន្តី ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

[៦៤៩] ភិក្ខុនីមានតម្រេកត្រេកអរនឹងកាយសំសគ្គៈ របស់បុរសបុគ្គល ដែលមានតម្រេកដែរ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុនីមានតម្រេកត្រេកអរនឹងកាយសំសគ្គៈរបស់បុរសបុគ្គល ដែលមានតម្រេកដែរ ត្រូវអាបត្តិ ៣ គឺត្រេកអរនឹងការចាប់ពាល់សរីរប្រទេស ខាងក្រោមដងកាំបិតចុះមក ខាងលើមណ្ឌលនៃជង្គង់ឡើងទៅ ត្រូវអាបត្តិបារាជិក ត្រេកអរនឹងការចាប់ពាល់សរីរប្រទេស ខាងលើដងកាំបិតឡើងទៅ ខាងក្រោមមណ្ឌលនៃជង្គង់ចុះមក ត្រូវអាបត្តិថុល្លច្ច័យ ត្រេកអរនឹងការចាប់ពាល់វត្ថុដែលជាប់ដោយកាយ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមានតម្រេកត្រេកអរនឹងកាយសំសគ្គៈរបស់បុរសបុគ្គល ដែលមានតម្រេកដែរ ត្រូវអាបត្តិ ៣ នេះឯង ។

[៦៥០] ភិក្ខុនីជាអ្នកបិទបាំងទោស កាលបើបិទបាំងទោសគេ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុនីជាអ្នកបិទបាំងទោស កាលបើបិទបាំងទោសគេ ត្រូវអាបត្តិ ៣ គឺភិក្ខុនីដឹងហើយបិទបាំងអាបត្តិបារាជិក (របស់គេ) ត្រូវអាបត្តិបារាជិក ភិក្ខុនីសង្ស័យហើយបិទបាំង ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុនីបិទបាំងអាចារវិបត្តិ ត្រូវអាបត្តិទុក្កដ ភិក្ខុនីបិទបាំងទោស កាលបើបិទបាំងទោសគេ ត្រូវអាបត្តិ ៣ នេះឯង ។

[៦៤១] ឧក្ខិត្តានុវត្តិកា ភិក្ខុនី យាវតតិយំ សមនុ-
ភាសនាយ នប្បដិនិស្សជ្ជន្តី កតិ អាបត្តិយោ អាបជ្ជ-
តិ ។ ឧក្ខិត្តានុវត្តិកា ភិក្ខុនី យាវតតិយំ សមនុភាស-
នាយ នប្បដិនិស្សជ្ជន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ
ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវា-
ចាបរិយោសានេ អាបត្តិ បារាជិកស្ស ឧក្ខិត្តានុវត្តិកា
ភិក្ខុនី យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តី
ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

[៦៤២] អដ្ឋមំ វត្ថុំ បរិបូរេន្តី កតិ អាបត្តិយោ អាបជ្ជតិ ។
អដ្ឋមំ វត្ថុំ បរិបូរេន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ បុរិសេន
ឥត្ថន្នាមំ គច្ឆំ គច្ឆាតិ វុត្តា គច្ឆតិ អាបត្តិ ទុក្កដស្ស

[៦៩១] ភិក្ខុនីប្រព្រឹត្តតាមភិក្ខុនី ដែលសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុនីប្រព្រឹត្តតាមភិក្ខុនី ដែលសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ ៣ គឺត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចា[១] ចប់ ត្រូវអាបត្តិបារាជិក ភិក្ខុនីប្រព្រឹត្តតាមភិក្ខុនីដែលសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ ៣ នេះឯង ។

[៦៩២] ភិក្ខុនីបំពេញវត្ថុទី ៨[២] ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុនីបំពេញវត្ថុទី ៨ ត្រូវអាបត្តិ ៣ គឺភិក្ខុនីដែលបុរសនិយាយថា លោកចូរទៅកាន់បន្ទប់ឈ្មោះនេះ ហើយទៅ ត្រូវអាបត្តិទុក្កដ គ្រាន់តែបុរស

---

១ កម្មវាចានេះហៅថា ញត្តិចតុត្ថកម្មវាចា កម្មវាចាមានញត្តិជាគម្រប់ ៤ គឺមានញត្តិម្តងជាមុន ហើយមានកម្មវាចា ៣ ដងជាខាងក្រោយ ។ ក្នុងខណៈចប់ញត្តិ ត្រូវទុក្កដ ចប់កម្មវាចាទី ១ ត្រូវថុល្លច្ច័យ ចប់ទី ២ ត្រូវថុល្លច្ច័យ ចប់ទី ៣ ត្រូវបារាជិក ។ ២ ក្នុងសិក្ខាបទនេះ មានវត្ថុ ៨ យ៉ាង គឺភិក្ខុនីត្រេកអរនឹងបុរសចាប់ដៃខ្លួន ១ ចាប់ដោយសង្ឃដី ១ ឋិតនៅជាមួយបុរស ១ និយាយជាមួយនឹងបុរស ១ ទៅកាន់ទីសង្កេត ១ ត្រេកអរនឹងបុរសដើរចូលមកជិត ១ ចូលទៅកាន់ទីកំបាំង ១ បន្ទន់កាយទៅដើម្បីសេពអសទ្ធម្ម ១ ។

បុរិសស្ស ហត្ថបាសំ ឱក្កន្តមត្តេ អាបត្តិ ថុល្លច្ចយស្ស អដ្ឋមំ វត្ថុំ បរិបូរេតិ អាបត្តិ បារាជិកស្ស អដ្ឋមំ វត្ថុំ បរិបូរេន្តី ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

បារាជិកា និដ្ឋិតា ។

[៦៩៣] ឧស្សយវាទិកា[១] ភិក្ខុនី អដ្ដំ ករោន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ ឯកស្ស អារោចេតិ អាបត្តិ ទុក្កដស្ស ទុតិយស្ស អារោចេតិ អាបត្តិ ថុល្លច្ចយស្ស អដ្ដបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៦៩៤] ចោរី វុដ្ឋាបេន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៦៩៥] ឯកា គាមន្តរំ គច្ឆន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ គច្ឆតិ អាបត្តិ ទុក្កដស្ស បឋមំ បាទំ បរិក្ខេបំ អតិក្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ សង្ឃាទិសេសស្ស ។

១ ឱ. ម. ឧស្សយវាទិកា ។

ដើរចូលទៅដល់ហត្ថបាស ត្រូវអាបត្តិថុល្លច្ច័យ លុះធ្វើវត្ថុទី ៨ ឲ្យពេញ (បន្ទន់កាយទៅដើម្បីសេពអសទ្ធម្ម) ត្រូវអាបត្តិបារាជិក ភិក្ខុនីបំពេញវត្ថុទី ៨ ត្រូវអាបត្តិ ៣ នេះឯង ។

ចប់ បារាជិក ។

[៦៥៣] ភិក្ខុនីជាអ្នកទាស់ទែង ដោយសេចក្តីច្រណែន កាលដែលធ្វើនូវដំណើរកើតក្តី ត្រូវអាបត្តិ ៣ គឺភិក្ខុនីប្រាប់ពាក្យជនម្នាង (ដល់ចៅក្រម) ត្រូវអាបត្តិទុក្កដ ប្រាប់ពាក្យរបស់ជនជាគម្រប់ពីរ (ដល់ចៅក្រម) ត្រូវអាបត្តិថុល្លច្ច័យ លុះសម្រេចដំណើរក្តីហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[៦៥៤] ភិក្ខុនីបំបួសចោរស្រី ត្រូវអាបត្តិ ៣ គឺ ត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ ត្រូវអាបត្តិសង្ឃាទិសេស ។

[៦៥៥] ភិក្ខុនីទៅកាន់ចន្លោះស្រុក តែម្នាក់ឯង ត្រូវអាបត្តិ ៣ គឺកំពុងទៅដើរត្រូវអាបត្តិទុក្កដ ឈានជំហានទីមួយ ចូលទៅក្នុងរបងស្រុក ត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានទីពីរ ចូលទៅក្នុងរបងស្រុក ត្រូវអាបត្តិសង្ឃាទិសេស ។

[៦៤៦] សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនឹ ធម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារេន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៦៤៧] អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គ-លស្ស ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ថុល្ល-ច្ចយស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ សង្ឃាទិ-សេសស្ស ឧទកទន្តបោណំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

[៦៤៨] កិន្តេ អយ្យេ ឯសោ បុរិសបុគ្គលោ ក-រិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អន-វស្សុតា ឥង្ឃយ្យេ យន្តេ ឯសោ បុរិសបុគ្គលោ ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា បដិគ្គ-ហេត្វា ខាទ វា ភុញ្ជ វាតិ ឧយ្យោជេន្តី តិស្សោ អាបត្តិ-

[៦៥៦] ភិក្ខុនីមិនបានប្រាប់ការកសង្ឃ មិនបានដឹងឆន្ទៈរបស់គណៈ ហើយធ្វើឱសារណកម្ម ចំពោះភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នា លើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ត្រូវអាបត្តិ ៣ គឺត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[៦៥៧] ភិក្ខុនីមានតម្រេក ហើយទទួលខាទនីយៈ ឬភោជនីយៈ ដោយដៃរបស់ខ្លួន អំពីដៃបុរសបុគ្គលដែលមានតម្រេកដែរមកឆាន់ ត្រូវអាបត្តិ ៣ គឺទទួលដោយគិតថា អញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិថុល្លច្ច័យ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ៗ វារៈដែលលេបចូលទៅ គ្រាន់តែទទួលទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។

[៦៥៨] ភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នាថា នែនាងជាម្ចាស់ បុរសបុគ្គលនេះ ទោះមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នែនាងជាម្ចាស់ ណ្ហើយចុះ កាលណាបើនាងមិនមានតម្រេកទេ បើបុរសបុគ្គលនោះឲ្យវត្ថុណា ទោះខាទនីយៈក្តី ភោជនីយៈក្តីដល់នាង ចូរនាងទទួលវត្ថុនោះដោយដៃរបស់ខ្លួនហើយទំពាស៊ី ឬបរិភោគចុះ ដូច្នេះ ត្រូវអាបត្តិ ៣

យោ អាបជ្ជតិ តស្សា វចនេន ខាទិស្សាមិ ភុញ្ជិស្សា-
មីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ
អជ្ឈោហារេ អាបត្តិ ថុល្លច្ចយស្ស ភោជនបរិយោសានេ
អាបត្តិ សង្ឃាទិសេសស្ស ។

[៦៥៩] កុបិតា ភិក្ខុនី យាវតតិយំ សមនុភាស-
នាយ នប្បដិនិស្សជ្ជន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ
ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្ម-
វាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៦៦០] កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុ-
បិតា ភិក្ខុនី យាវតតិយំ សមនុភាសនាយ នប្បដិ-
និស្សជ្ជន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ
ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ
អាបត្តិ សង្ឃាទិសេសស្ស ។

[៦៦១] សំសដ្ឋា ភិក្ខុនិយោ យាវតតិយំ សមនុភា-
សនាយ នប្បដិនិស្សជ្ជន្តិយោ តិស្សោ អាបត្តិយោ អា-
បជ្ជន្តិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា
កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

គឺទទួលដោយគិតថា អញនឹងទំពាស៊ី ឬបរិភោគ តាមពាក្យភិក្ខុនីដែលបញ្ជូននោះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិថុល្លច្ច័យគ្រប់ ៗ វារៈ ដែលលេបចូលទៅ លុះសម្រេចការបរិភោគហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[៦៥៩] ភិក្ខុនីក្រោធខឹង កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ ៣ គឺត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[៦៦០] ភិក្ខុនីដែលសង្ឃឲ្យចាញ់គេ ក្នុងអធិករណ៍ណានីមួយ ហើយក្រោធខឹង កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ ៣ គឺត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[៦៦១] ភិក្ខុនីទាំងឡាយ ដែលនៅច្រឡូកច្រឡំ កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ ៣ គឺត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

ភិក្ខុនីវិភង្គេ សោឡស មហាវារា និស្សគ្គិយា បាចិត្តិយា

[៦៦២] សំសដ្ឋាវយ្យេ តុម្ហ វិហរថ មា តុម្ហ ឆាឆា វិហរិត្ថាតិ ឧយ្យោជេន្តី យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

សង្ឃាទិសេសា និដ្ឋិតា ។

[៦៦៣] បត្តសន្និចយំ ករោន្តី ឯកំ អាបត្តឹ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។

[៦៦៤] អកាលចីវរំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ភាជាបេតិ បយោគេ ទុក្កដំ ភាជាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៦៥] ភិក្ខុនិយា សទ្ធឹ ចីវរំ បរិវត្តេត្វា អច្ឆិន្ទន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ អច្ឆិន្ទតិ បយោគេ ទុក្កដំ អច្ឆិន្នេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៦២] ភិក្ខុនីបញ្ជូន (ភិក្ខុនីផងគ្នា) ថា នែនាងជាម្ចាស់ ចូរនាងទាំងឡាយនៅច្រឡូកច្រឡំចុះ នាងទាំងឡាយ កុំនៅទីទៃពីគ្នាឡើយ កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ ៣ គឺត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

ចប់ សង្ឃាទិសេស ។

[៦៦៣] ភិក្ខុនីធ្វើការសន្សំបាត្រទុក ត្រូវអាបត្តិ ១ គឺនិស្សគ្គិយ-បាចិត្តិយៈ ។

[៦៦៤] ភិក្ខុនីអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរ ហើយឲ្យគេចែក ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេចែក ឲ្យគេចែករួចហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៦៥] ភិក្ខុនីបានប្តូរចីវរនឹងភិក្ខុនីផងគ្នា ហើយដណ្តើមយកវិញ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដណ្តើម លុះដណ្តើមបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៦៦] អញ្ញំ វិញ្ញាបេត្វា អញ្ញំ វិញ្ញាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វិញ្ញាបេតិ បយោគេ ទុក្កដំ វិញ្ញាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៦៧] អញ្ញំ ចេតាបេត្វា អញ្ញំ ចេតាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៦៨] អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន អញ្ញំ ចេតាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៦៩] អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន សញ្ញាចិកេន អញ្ញំ ចេតាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៧០] អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន អញ្ញំ ចេតាបេន្តី ទ្វេ អាបត្តិយោ

[៦៦៦] ភិក្ខុនី សូមវត្ថុដទៃហើយ ត្រឡប់ជាសូមវត្ថុឯទៀតវិញ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសូម លុះសូមបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៦៧] ភិក្ខុនី ឲ្យគេទិញវត្ថុដទៃហើយ ត្រឡប់ជាឲ្យទិញវត្ថុឯទៀតវិញ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេទិញ លុះឲ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៦៨] ភិក្ខុនី ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខាររបស់សង្ឃ ដែលគេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេទិញ លុះឲ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៦៩] ភិក្ខុនី ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខាររបស់សង្ឃ ដែលគេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត និងដោយវត្ថុដែលសូមគេបានមកដោយខ្លួនឯង ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេទិញ លុះឲ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៧០] ភិក្ខុនី ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខាររបស់គណៈ ដែលគេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត ត្រូវអាបត្តិ ២

អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៧១] អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន សញ្ញាចិកេន អញ្ញំ ចេតាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៧២] អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន បុគ្គលិកេន សញ្ញាចិកេន អញ្ញំ ចេតាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[៦៧៣] អតិរេកចតុក្កំសបរមំ គរុបាវុរណំ ចេតាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេទិញ លុះឲ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៧១] ភិក្ខុនី ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខាររបស់គណៈ ដែលគេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត និងដោយវត្ថុដែលសូមគេបានមកដោយខ្លួនឯង ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេទិញ លុះឲ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៧២] ភិក្ខុនី ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខាររបស់បុគ្គល ដែលគេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត និងដោយវត្ថុដែលសូមគេបានមកដោយខ្លួនឯង ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេទិញ លុះឲ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៧៣] ភិក្ខុនី ឲ្យគេទិញសំពត់ដណ្តប់ មានសាច់ក្រាស់ មានតម្លៃច្រើនជាង ១៦ កហាបណៈឡើងទៅ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេទិញ លុះឲ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

[៦៧៤] អតិរេកឱ្សតេយ្យកំសបរមំ លហុចាបុ-រណំ ចេតាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ ចាចិត្តិយំ ។

និស្សគ្គិយា បាចិត្តិយា និដ្ឋិតា ។

[៦៧៥] លសុណំ ខាទន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ខាទិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោ-ហារេ អជ្ឈោហារេ អាបត្តិ ចាចិត្តិយស្ស ។

[៦៧៦] សម្ពាធេ លោមំ សំហរាបេន្តី ទ្វេ អាបត្តិ-យោ អាបជ្ជតិ សំហរាបេតិ បយោគេ ទុក្កដំ សំហ-រាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៦៧៧] តលឃាតកំ ករោន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ករោតិ បយោគេ ទុក្កដំ កតេ អាបត្តិ ចាចិត្តិយស្ស ។

[៦៧៨] ជតុមដ្ឋកំ អាទិយន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ អាទិយតិ បយោគេ ទុក្កដំ អាទិន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៦៧៤] ភិក្ខុនី ឲ្យគេទិញសំពត់ដណ្តប់ មានសាច់ស្តើង មានតម្លៃច្រើនជាង ១០ កហាបណៈឡើងទៅ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេទិញ លុះឲ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។

ចប់ និស្សគ្គិយបាចិត្តិយៈ ។

[៦៧៥] ភិក្ខុនីឆាន់ខ្ទឹម ត្រូវអាបត្តិ ២ គឺ ទទួលដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៦៧៦] ភិក្ខុនីឲ្យគេដករោមក្នុងទីចង្អៀត ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេដក លុះឲ្យគេដករួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៧៧] ភិក្ខុនីធ្វើការប្រហារផ្ទៃនិមិត្ត ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ លុះធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៧៨] ភិក្ខុនីកាន់យករូបអង្គជាត ដែលធ្វើដោយជ័រឈើ ឬកាកល័ក្តជ័រលើង ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកាន់យក លុះកាន់យករួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៧៩] អតិរេកទ្វង្គុលបព្វបរមំ ឧទកសុទ្ធិកំ អាទិយន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ អាទិយតិ បយោគេ ទុក្កដំ អាទិន្នេ បាចិត្តិយស្ស ។

[៦៨០] ភិក្ខុស្ស ភុញ្ជន្តស្ស[១] បានីយេន វា វិធូបនេន វា ឧបតិដ្ឋន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ហត្ថបាសំ វិជហិត្វា តិដ្ឋតិ អាបត្តិ ទុក្កដស្ស ។

[៦៨១] អាមកធញ្ញំ វិញ្ញាបេត្វា ភុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៦៨២] ឧច្ចារំ វា បស្សាវំ វា ខេឡំ វា សង្ការំ វា វិឃាសំ វា តិរោកុឌ្ឌេ ឆឌ្ឌេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ឆឌ្ឌេតិ បយោគេ ទុក្កដំ ឆឌ្ឌិតេ អាបត្តិ បាចិត្តិយស្ស ។

[៦៨៣] ឧច្ចារំ វា បស្សាវំ វា ខេឡំ វា សង្ការំ វា វិឃាសំ វា ហរិតេ ឆឌ្ឌេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ឆឌ្ឌេតិ បយោគេ ទុក្កដំ ឆឌ្ឌិតេ អាបត្តិ បាចិត្តិយស្ស ។

---

១ ភុញ្ជមានស្សាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[៦៧៩] ភិក្ខុនីកាន់យកការជម្រះនិមិត្ត ដោយទឹកជ្រៅហួសកំណាត់ ២ ថ្នាំងម្រាមដៃទៅ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលជម្រះ លុះកាន់យកការជម្រះរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៨០] ភិក្ខុកំពុងឆាន់ ភិក្ខុនីទៅបម្រើដោយទឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិ ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅដាច់ពីហត្ថបាស ត្រូវអាបត្តិទុក្កដ ។

[៦៨១] ភិក្ខុនីសូមស្រូវស្រស់មកឆាន់ ត្រូវអាបត្តិ ២ គឺទទួលដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៦៨២] ភិក្ខុនីចោលឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី សម្រាមក្តី របស់សំណល់ក្តី ខាងក្រៅជញ្ជាំង ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលចោល លុះចោលរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៨៣] ភិក្ខុនីចោលឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី សម្រាមក្តី របស់សំណល់ក្តី លើឈើ ឬស្មៅស្រស់ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលចោល លុះចោលរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៨៤] ឆត្តំ វា គីតំ វា វាទិតំ វា ឆស្សុជាយ កច្ឆន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ កច្ឆតិ អាបត្តិ ទុក្កដស្ស យត្ថ ឋិតា បស្សតិ វា សុណាតិ វា អាបត្តិ បាចិត្តិយស្ស ។

លសុណវគ្គោ បឋមោ ។

[៦៨៥] រត្តន្ធការេ អប្បទីបេ បុរិសេន សទ្ធឹ ឯកោនេកា សន្តិដ្ឋន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ហត្ថបាសំ វិជហិត្វា តិដ្ឋតិ អាបត្តិ ទុក្កដស្ស ។

[៦៨៦] បដិច្ឆន្នេ ឱកាសេ បុរិសេន សទ្ធឹ ឯកោនេកា សន្តិដ្ឋន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ហត្ថបាសំ វិជហិត្វា តិដ្ឋតិ អាបត្តិ ទុក្កដស្ស ។

[៦៨៧] អជ្ឈោកាសេ បុរិសេន សទ្ធឹ ឯកោនេកា សន្តិដ្ឋន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ហត្ថបាសំ វិជហិត្វា តិដ្ឋតិ អាបត្តិ ទុក្កដស្ស ។

[៦៨៤] ភិក្ខុនីទៅមើលរាំក្តី ស្តាប់ច្រៀងក្តី ភ្លេងប្រគំក្តី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដើរទៅ លុះទៅឈរមើល ឬស្តាប់ត្រង់ទីណា ត្រូវអាបត្តិបាចិត្តិយៈ ត្រង់ទីនោះ ។

ចប់ លសុណវគ្គ ទី ១ ។

[៦៨៥] ភិក្ខុនីឋិតនៅតែម្នាក់ឯង ជាមួយនឹងបុរសម្នាក់ ក្នុងវេលាយប់ងងឹតឥតមានប្រទីប ត្រូវអាបត្តិ ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅក្រៅពីហត្ថបាស ត្រូវអាបត្តិទុក្កដ ។

[៦៨៦] ភិក្ខុនីឋិតនៅតែម្នាក់ឯង ជាមួយនឹងបុរសម្នាក់ ក្នុងទីឱកាសដ៏កំបាំង ត្រូវអាបត្តិ ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅក្រៅពីហត្ថបាស ត្រូវអាបត្តិទុក្កដ ។

[៦៨៧] ភិក្ខុនីឋិតនៅតែម្នាក់ឯង ជាមួយនឹងបុរសម្នាក់ ក្នុងទីវាលត្រូវអាបត្តិ ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅក្រៅពីហត្ថបាស ត្រូវអាបត្តិទុក្កដ ។

[៦៨៨] វេថិយាយ វា ព្យូហេ វា សិង្ឃាតកេ វា បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ហត្ថបាសំ វិជហិត្វា តិដ្ឋតិ អាបត្តិ ទុក្កដស្ស ។

[៦៨៩] បុរេភត្តំ កុលានិ ឧបសង្កមិត្វា អាសនេ និសីទិត្វា សាមិកេ អនាបុច្ឆា បក្កមន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ អនោវស្សកំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

[៦៩០] បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា អាសនេ និសីទន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ និសីទតិ បយោគេ ទុក្កដំ និសិន្នេ អាបត្តិ បាចិត្តិយស្ស ។

[៦៩១] វិកាលេ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ អភិនិសីទតិ បយោគេ ទុក្កដំ អភិនិសិន្នេ អាបត្តិ បាចិត្តិយស្ស ។

[៦៨៨] ភិក្ខុនីឋិតនៅតែម្នាក់ឯង ជាមួយនឹងបុរសម្នាក់ ក្នុងច្រកហ្វេតក្តី ច្រកទាល់ក្តី ផ្លូវបែកក្តី ត្រូវអាបត្តិ ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅក្រៅពីហត្ថបាស ត្រូវអាបត្តិទុក្កដ ។

[៦៨៩] ភិក្ខុនីចូលទៅកាន់ត្រកូល ក្នុងវេលាមុនភត្ត ហើយអង្គុយលើអាសនៈមិនបានប្រាប់ម្ចាស់គេ ស្រាប់តែចៀសចេញទៅ ត្រូវអាបត្តិ ២ គឺឈានជំហានទីមួយចូលទៅ ក្នុងទីដែលភ្លៀងធ្លាក់មិនត្រូវ ត្រូវអាបត្តិទុក្កដ ឈានជំហានទីពីរចូលទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៩០] ភិក្ខុនីចូលទៅកាន់ត្រកូល ក្នុងវេលាក្រោយភត្តមិនបានប្រាប់ម្ចាស់គេ ហើយស្រាប់តែអង្គុយលើអាសនៈ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលអង្គុយ លុះអង្គុយស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៩១] ភិក្ខុនីចូលទៅកាន់ត្រកូលក្នុងវេលាវិកាល ហើយមិនបានប្រាប់ម្ចាស់គេស្រាប់តែក្រាលឯងក្តី ប្រើអ្នកដទៃឲ្យក្រាលក្តី នូវកម្រាលសម្រាប់ដេក ហើយអង្គុយសង្កត់លើ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលអង្គុយ លុះអង្គុយស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៩២] ឧក្កុដិតេន ឧបជារិតេន បរំ ឧជ្ឈាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧជ្ឈាបេតិ បយោគេ ទុក្កដំ ឧជ្ឈាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៦៩៣] អត្តានំ វា បរំ វា និរយេន វា ព្រហ្ម-ចរិយេន វា អភិសបន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អភិសបតិ បយោគេ ទុក្កដំ អភិសបិតេ អាបត្តិ បាចិត្តិយស្ស ។

[៦៩៤] អត្តានំ វធិត្វា វធិត្វា រោទន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វធតិ រោទតិ អាបត្តិ បាចិត្តិយស្ស វធតិ ន រោទតិ អាបត្តិ ទុក្កដស្ស ។

វត្ថុនូកាវវគ្គោ ទុតិយោ ។

[៦៩៥] នគ្គា នហាយន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ នហាយតិ បយោគេ ទុក្កដំ នហានបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៦៩៦] បមាណាតិក្កន្តំ ឧទកសាដិកំ ការា-បេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៦៩២] ភិក្ខុនីពោលទោសភិក្ខុនីឯទៀត ដោយការប្រកាន់ខុស ទាំងពិចារណាខុស ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលពោលទោស លុះពោលទោសរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៩៣] ភិក្ខុនីប្រទេចផ្តាសាខ្លួនឯង ឬឧបសម្បន្នដទៃ ដោយពាក្យថា នរកក្តី ដោយពាក្យថា ព្រហ្មចរិយៈក្តី ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រទេច លុះប្រទេចរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៩៤] ភិក្ខុនីវាយខ្លួនឯងរឿយ ៗ ហើយយំ ត្រូវអាបត្តិ ២ គឺវាយហើយយំផង ត្រូវអាបត្តិបាចិត្តិយៈ គ្រាន់តែវាយមិនយំ ត្រូវអាបត្តិទុក្កដ ។

ចប់ រត្តន្ធការវគ្គ ទី ២ ។

[៦៩៥] ភិក្ខុនីមានកាយអាក្រាតងូតទឹក ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលងូតទឹក លុះងូតស្រេចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៩៦] ភិក្ខុនីឲ្យគេធ្វើសំពត់ងូតទឹកកន្លងហួសខ្នាត ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យធ្វើ លុះឲ្យធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៦៩៧] ភិក្ខុនិយា ចីវរំ វិសិព្វេត្វា វា វិសិព្វាបេត្វា វា នេវ សិព្វេន្តី ន សិព្វាបនាយ ឧស្សុក្កំ ករោន្តី ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៦៩៨] បញ្ចាហិកំ សង្ឃាដិចារំ អតិក្កាមេន្តី ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៦៩៩] ចីវរសង្កមនីយំ ធារេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ធារេតិ បយោគេ ទុក្កដំ ធារិតេ អាបត្តិ បាចិត្តិយស្ស ។

[៧០០] គណស្ស ចីវរលាភំ អន្តរាយំ ករោន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ករោតិ បយោគេ ទុក្កដំ កតេ អាបត្តិ បាចិត្តិយស្ស ។

[៧០១] ធម្មិកំ ចីវរវិភង្គំ បដិពាហន្តី ទ្វេ អាបត្តិ-យោ អាបជ្ជតិ បដិពាហតិ បយោគេ ទុក្កដំ បដិពា-ហិតេ អាបត្តិ បាចិត្តិយស្ស ។

[៦៩៧] ភិក្ខុនីរុះខ្លួនឯង ឬប្រើគេឲ្យរុះនូវចីវររបស់ភិក្ខុនីផងគ្នា ហើយមិនដេរវិញ ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយឲ្យគេដេរឲ្យវិញ ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៦៩៨] ភិក្ខុនីញ៉ាំងវារៈនៃសង្ឃាដិ (ប្រើផ្លាស់ប្តូរនឹងឧត្តរាសង្គៈ) ឲ្យកន្លងហួស ៥ ថ្ងៃទៅ ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៦៩៩] ភិក្ខុនីប្រើប្រាស់សង្កមនីយចីវរ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើប្រាស់ លុះប្រើប្រាស់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧០០] ភិក្ខុនីធ្វើចីវរលាភរបស់គណៈឲ្យខូចទៅ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ លុះធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧០១] ភិក្ខុនីឃាត់ការចែកចីវរ ដែលប្រកបដោយធម៌ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឃាត់ លុះឃាត់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧០២] អាគារិកស្ស វា បរិព្វាជកស្ស វា បរិព្វាជិកាយ វា សមណចីវរំ ទេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ទេតិ បយោគេ ទុក្កដំ ទិន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៧០៣] ទុព្វលចីវរប្បច្ចាសាយ ចីវរកាលសមយំ អតិក្កាមេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ អតិក្កាមេតិ បយោគេ ទុក្កដំ អតិក្កាមិតេ អាបត្តិ ចាចិត្តិយស្ស ។

[៧០៤] ធម្មិកំ កឋិនុទ្ធារំ បដិពាហន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បដិពាហតិ បយោគេ ទុក្កដំ បដិពាហិតេ អាបត្តិ ចាចិត្តិយស្ស ។

នហានវគ្គោ តតិយោ ។

[៧០៥] ទ្វេ ភិក្ខុនិយោ ឯកមញ្ចេ តុវដ្ដេន្តិយោ ទ្វេ អាបត្តិយោ អាបជ្ជន្តិ និបជ្ជន្តិ បយោគេ ទុក្កដំ និបន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៧០៦] ទ្វេ ភិក្ខុនិយោ ឯកត្ថរណចាបុរណា តុវដ្ដេន្តិយោ ទ្វេ អាបត្តិយោ អាបជ្ជន្តិ និបជ្ជន្តិ បយោគេ ទុក្កដំ និបន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៧០២] ភិក្ខុនីឲ្យចីវររបស់សមណៈដល់គ្រហស្ថក្តី ដល់បរិព្វាជកក្តី ដល់បរិព្វាជិកាក្តី ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យ លុះឲ្យរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧០៣] ភិក្ខុនីញ៉ាំងសម័យនៃចីវរកាល ឲ្យកន្លងហួសទៅដោយចង់បានចីវរដ៏ទុព្វភាព ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យកន្លង លុះឲ្យកន្លងហួសទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧០៤] ភិក្ខុនីឃាត់ការដកកឋិន ដែលប្រកបដោយធម៌ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឃាត់ លុះឃាត់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ នហានវគ្គ ទី ៣ ។

[៧០៥] ភិក្ខុនីពីររូបដេកលើគ្រែតែមួយ ជាមួយគ្នា ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដេក លុះដេកស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧០៦] ភិក្ខុនីពីររូបមានកម្រាលនិងសំពត់ដណ្តប់តែមួយ ដេកជាមួយគ្នា ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុប្រយោគដែលរៀបនឹងដេក លុះដេកស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

ភិក្ខុនីវិភង្គេ សោឡស មហាវារា បាចិត្តិយេ តុវដ្ដវគ្គោ

[៧០៧] ភិក្ខុនិយោ សញ្ចិច្ច អផាសុំ ករោន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ករោតិ បយោគេ ទុក្កដំ កតេ អាបត្តិ ចាចិត្តិយស្ស ។

[៧០៨] ទុក្ខិតំ សហជីវិនឹ នេវ ឧបដ្ឋេន្តី ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករោន្តី ឯកំ អាបត្តឹ អា-
បជ្ជតិ ចាចិត្តិយំ ។

[៧០៩] ភិក្ខុនិយា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ និកឌ្ឍតិ បយោគេ ទុក្កដំ និក្កឌ្ឍិតេ អាបត្តិ ចាចិត្តិយស្ស ។

[៧១០] សំសដ្ឋា ភិក្ខុនី យាវតតិយំ សមនុភា-
សនាយ នប្បដិនិស្សជ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ កម្មវាចាបរិយោសានេ អាបត្តិ ចា-
ចិត្តិយស្ស ។

[៧១១] អន្តោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បដិបជ្ជតិ បយោគេ ទុក្កដំ បដិបន្នេ អាបត្តិ ចាចិត្តិ-
យស្ស ។

[៧០៧] ភិក្ខុនីក្លែងធ្វើសេចក្តីអផ្សុកដល់ភិក្ខុនីផងគ្នា ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ លុះធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧០៨] ភិក្ខុនីមិនបម្រើ ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយឲ្យគេបម្រុងនឹងបម្រើ នូវកូនសិស្សដែលមានជំងឺ ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៧០៩] ភិក្ខុនីឲ្យលំនៅដល់ភិក្ខុនីផងគ្នា ហើយស្រាប់តែក្រោធអាក់អន់ចិត្ត បណ្តេញភិក្ខុនីនោះចេញ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលបណ្តេញ លុះបណ្តេញចេញរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧១០] ភិក្ខុនីនៅច្រឡូកច្រឡំ កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧១១] ភិក្ខុនីមិនមានពួកឈ្មួញជាគ្នា ទៅកាន់ទីចារិកខាងក្នុងដែនដែលគេសន្មតថា ប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដើរ លុះដើរហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧១២] តិរោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បដិបជ្ជតិ បយោគេ ទុក្កដំ បដិបន្នេ អាបត្តិ ចាចិត្តិ-យស្ស ។

[៧១៣] អន្តោវស្សំ ចារិកំ ចរន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បដិបជ្ជតិ បយោគេ ទុក្កដំ បដិបន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៧១៤] វស្សំ វុត្ថា ភិក្ខុនី ចារិកំ ន បក្កមន្តី ឯកំ អាបត្តឹ អាបជ្ជតិ ចាចិត្តិយំ ។

តុវដ្ដវគ្គោ ចតុត្ថោ ។

[៧១៥] រាជាគារំ វា ចិត្តាគារំ វា អារាមំ វា ឧយ្យានំ វា បោក្ខរណឹ វា ទស្សនាយ គច្ឆន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ គច្ឆតិ បយោគេ ទុក្កដំ[១] យត្ថ ឋិតា បស្សតិ អាបត្តិ ចាចិត្តិយស្ស ។

---

១ ឱ. ម. គច្ឆតិ អាបត្តិ ទុក្កដស្ស ។

[៧១២] ភិក្ខុនីមិនមានពួកឈ្មួញជាគ្នា ដើរទៅកាន់ទីចារិកខាងក្រៅដែន ដែលគេសន្មតថា ប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដើរ លុះដើរទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧១៣] ភិក្ខុនីទៅកាន់ទីចារិកខាងក្នុងវស្សា ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដើរ លុះដើរទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧១៤] ភិក្ខុនីនៅចាំវស្សារួចហើយ មិនចៀសចេញទៅកាន់ទីចារិក ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

ចប់ តុវដ្តវគ្គៈ ទី ៤ ។

[៧១៥] ភិក្ខុនីដើរទៅ ដើម្បីមើលដំណាក់សម្រាប់ក្រសាលរបស់ព្រះរាជាក្តី រោងដ៏វិចិត្រក្តី សួនក្តី ឧទ្យានក្តី ស្រះបោក្ខរណីក្តី ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងដើរទៅ ត្រូវអាបត្តិទុក្កដ ឈរមើលក្នុងទីណា ត្រូវអាបត្តិបាចិត្តិយៈក្នុងទីនោះ ។

[៧១៦] អាសន្ទឹ វា បល្លង្កំ វា បរិភុញ្ជន្តី ទ្វេ អាបត្តិ-យោ អាបជ្ជតិ បរិភុញ្ជតិ បយោគេ ទុក្កដំ បរិភុត្តេ អាបត្តិ បាចិត្តិយស្ស ។

[៧១៧] សុត្តំ កន្តន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ កន្ត-តិ បយោគេ ទុក្កដំ ឧជ្ជវុជ្ជវេ អាបត្តិ បាចិត្តិយស្ស ។

[៧១៨] គិហិវេយ្យាវច្ចំ ករោន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ករោតិ បយោគេ ទុក្កដំ កតេ អាបត្តិ បាចិត្តិយស្ស ។

[៧១៩] ភិក្ខុនិយា ឯហាយ្យេ ឥមំ អធិករណំ វូបសមេហីតិ វុច្ចមានា សាធូតិ បដិស្សុណិត្វា នេវ វូបសមេន្តី ន វូបសមាយ ឧស្សុក្កំ ករោន្តី ឯកំ អា-បត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៧២០] អាគារិកស្ស វា(១) បរិព្វាជកស្ស វា បរិព្វាជិកាយ វា សហត្ថា ខាទនីយំ វា ភោជនីយំ វា ទេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ទេតិ បយោគេ ទុក្កដំ ទិន្នេ អាបត្តិ បាចិត្តិយស្ស ។

---

១ អាគារិកស្ស វា អចេលកស្ស វាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[៧១៦] ភិក្ខុនីប្រើប្រាស់គ្រែអាសន្ទិក្តី បល្ល័ង្កក្តី ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងប្រើប្រាស់ ត្រូវអាបត្តិទុក្កដ លុះប្រើប្រាស់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧១៧] ភិក្ខុនីការអំបោះ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងការ ត្រូវអាបត្តិទុក្កដ ក្នុងវារៈដែលបង្វិល ១ ជុំ ៗ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧១៨] ភិក្ខុនីធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងធ្វើ ត្រូវអាបត្តិទុក្កដ លុះធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧១៩] ភិក្ខុនីកាលបើភិក្ខុនីផងគ្នានិយាយថា នែនាងជាម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះ ដូច្នេះ បានទទួលពាក្យថា សាធុហើយ បែរជាមិនរម្ងាប់ ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យរម្ងាប់វិញ ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៧២០] ភិក្ខុនីឲ្យខាទនីយៈ ឬភោជនីយាហារដល់គ្រហស្ថក្តី បរិព្វាជកក្តី បរិព្វាជិកាក្តី ដោយដៃខ្លួនឯង ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យ ត្រូវអាបត្តិទុក្កដ លុះឲ្យរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧២១] អាវសថចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បរិភុញ្ជតិ បយោគេ ទុក្កដំ បរិភុត្តេ អាបត្តិ បាចិត្តិយស្ស ។

[៧២២] អាវសថំ អនិស្សជ្ជិត្វា ចារិកំ បក្កមន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ បរិក្ខេបំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

[៧២៣] តិរច្ឆានវិជ្ជំ បរិយាបុណន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បរិយាបុណាតិ បយោគេ ទុក្កដំ បទេ បទេ អាបត្តិ បាចិត្តិយស្ស ។

[៧២៤] តិរច្ឆានវិជ្ជំ វាចេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វាចេតិ បយោគេ ទុក្កដំ បទេ បទេ អាបត្តិ បាចិត្តិយស្ស ។

ចិត្តាគារវគ្គោ បញ្ចមោ ។

[៧២១] ភិក្ខុនីមិនប្រគល់អាវសថចីវរហើយប្រើប្រាស់ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងប្រើប្រាស់ ត្រូវអាបត្តិទុក្កដ លុះប្រើប្រាស់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧២២] ភិក្ខុនី មិនទាន់ប្រគល់ផ្ទះសំណាក់ហើយចៀសចេញទៅកាន់ចារិក ត្រូវអាបត្តិ ២ គឺឈានជំហានជាបឋម កន្លងរបងផ្ទះសំណាក់ទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានជាគម្រប់ពីរកន្លងទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧២៣] ភិក្ខុនីរៀនតិរច្ឆានវិជ្ជា ត្រូវអាបត្តិ ២ គឺត្រូវក្នុងប្រយោគដែលកំពុងរៀន ត្រូវអាបត្តិទុក្កដ (លុះរៀនហើយ) ត្រូវអាបត្តិបាចិត្តិយៈ រាល់ ៗ បទ ។

[៧២៤] ភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងបង្រៀន ត្រូវអាបត្តិទុក្កដ (លុះបង្រៀនហើយ) ត្រូវអាបត្តិបាចិត្តិយៈរាល់ ៗ បទ ។

ចប់ ចិត្តាគារវគ្គ ជាគម្រប់ ៥ ។

[៧២៥] ជានំ សភិក្ខុកំ អារាមំ អនាបុច្ឆា បវិសន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ បរិក្ខេបំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

[៧២៦] ភិក្ខុំ អក្កោសន្តី បរិភាសន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ អក្កោសតិ បយោគេ ទុក្កដំ អក្កោសិតេ អាបត្តិ បាចិត្តិយស្ស ។

[៧២៧] ចណ្ឌីកតា គណំ បរិភាសន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បរិភាសតិ បយោគេ ទុក្កដំ បរិភាសិតេ អាបត្តិ បាចិត្តិយស្ស ។

[៧២៨] និមន្តិតា វា បវារិតា វា ខាទនីយំ វា ភោជនីយំ វា ភុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៧២៩] កុលំ មច្ឆរាយន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ មច្ឆរាយតិ បយោគេ ទុក្កដំ មច្ឆរិតេ អាបត្តិ បាចិត្តិយស្ស ។

[៧២៥] ភិក្ខុនីកាលដឹងហើយចូលទៅកាន់អារាម ដែលមានភិក្ខុ ដោយមិនបានប្រាប់ (ជាមុន) ត្រូវអាបត្តិ ២ គឺឈានជំហានជាបឋម កន្ទ្រង់របង់អារាមទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានជាគម្រប់ពីរកន្ទ្រង់ទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧២៦] ភិក្ខុនីជេរប្រទេចភិក្ខុ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងជេរ ត្រូវអាបត្តិទុក្កដ លុះជេររួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧២៧] ភិក្ខុនីប្រទេចផ្តាសាគណភិក្ខុនី ដោយកំណាច ត្រូវ អាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងផ្តាសា ត្រូវអាបត្តិទុក្កដ លុះផ្តាសា រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧២៨] ភិក្ខុនីដែលគេនិមន្តហើយក្តី ហាមភោជនហើយក្តី បែរជា ទៅឆាន់ខាទនីយភោជនីយាហារ (ក្នុងទីដទៃ) ត្រូវអាបត្តិ ២ គឺកំពុង ទទួលដោយគិតថា អាត្មាអញនឹងទំពាស៊ី និងបរិភោគ ដូច្នេះ ត្រូវអាបត្តិ ទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៧២៩] ភិក្ខុនីកំណាញ់ត្រកូល ត្រូវអាបត្តិ ២ គឺកំពុងប្រព្រឹត្ត កំណាញ់ ត្រូវអាបត្តិទុក្កដ លុះប្រព្រឹត្តកំណាញ់ហើយ ត្រូវអាបត្តិ បាចិត្តិយៈ ។

[៧៣០] អភិក្ខុកេ អាវាសេ វស្សំ វសន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វស្សំ វសិស្សាមីតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ អាបត្តិ ទុក្កដស្ស សហ អរុណុគ្គមនា អាបត្តិ បាចិត្តិយស្ស ។

[៧៣១] វស្សំ វុត្ថា ភិក្ខុនី ឧភតោសង្ឃេ តីហិ ឋានេហិ នប្បវារេន្តី ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៧៣២] ឱវាទាយ វា សំវាសាយ វា ន គច្ឆន្តី ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៧៣៣] ឧបោសថម្បិ ន បុច្ឆន្តី ឱវាទម្បិ ន យាចន្តី ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៧៣៤] បសាខេ ជាតំ គណ្ឌំ វា រុហិតំ វា[១] អនបលោកេត្វា សង្ឃំ វា គណំ វា បុរិសេន សទ្ធឹ ឯកេនេកា ភេទាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ភេទាបេតិ បយោគេ ទុក្កដំ ភិន្នេ អាបត្តិ បាចិត្តិយស្ស ។

អារាមវគ្គោ ឆដ្ឋោ ។

១ គណ្ឌំ វា បិលកំ វា រុធិរំ វាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ម. រុធិតំ ។

[៧៣០] ភិក្ខុនីនៅចាំវស្សា ក្នុងអាវាសមិនមានភិក្ខុ ត្រូវអាបត្តិ ២ គឺកំពុងក្រាលសេនាសនៈដោយបំណងថា អាត្មាអញនឹងនៅចាំវស្សាដូច្នេះ ហើយក៏តម្កល់ទឹកឆាន់ ទឹកប្រើប្រាស បោសបរិវេណ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ព្រមគ្នានឹងអរុណរះឡើង ។

[៧៣១] ភិក្ខុនីនៅចាំវស្សារួចហើយ មិនបានបវារណានឹងឧភតោសង្ឃ ដោយស្ថាន ៣ យ៉ាង ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៧៣២] ភិក្ខុនីមិនទៅ ដើម្បីទទួលឱវាទក្តី ដើម្បីនៅរួបរួមគ្នាក្តី ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៧៣៣] ភិក្ខុនីមិនសួរឧបោសថផង មិនសូមឱវាទផង ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៧៣៤] ភិក្ខុនីមិនបានប្រាប់សង្ឃឬគណៈ (ហើយនៅតែ) ម្នាក់នឹងម្នាក់ជាមួយនឹងបុរស ឲ្យគេទំលាយពកក្តី របួសក្តី ដែលកើតត្រង់កាយ ខាងក្រោម[១] ត្រូវអាបត្តិ ២ គឺ ក្នុងប្រយោគដែលកំពុងឲ្យគេទំលាយ ត្រូវអាបត្តិទុក្កដ លុះទំលាយរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ អារាមវគ្គ ជាគម្រប់ ៦ ។

---

១ សរីរប្រទេសខាងក្រោមតាំងពីផ្ចិតទៅទល់ត្រឹមក្បាលជង្គង់ ។

[៧៣៥] គព្ភិនឹ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៣៦] បាយន្តឹ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៣៧] ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ សិក្ខមានំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៣៨] ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សិក្ខមានំ សង្ឃេន អសម្មតំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៣៩] ឩនទ្វាទសវស្សំ គិហិគតំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៣៥] ភិក្ខុនីឲ្យឧបសម្បទា ដល់ស្ត្រីមានគភ៌ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៣៦] ភិក្ខុនីឲ្យឧបសម្បទាដល់ស្ត្រីមេដោះ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៣៧] ភិក្ខុនីឲ្យឧបសម្បទា ដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ ប្រការអស់ ២ វស្សា ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៣៨] ភិក្ខុនីឲ្យឧបសម្បទា ដល់សិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌ ៦ ប្រការអស់ ២ វស្សា ដែលសង្ឃមិនបានសន្មតឲ្យ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៣៩] ភិក្ខុនីឲ្យឧបសម្បទា ដល់ស្ត្រីគ្រហស្ថ មានវស្សាមិនគ្រប់ ១២ ឆ្នាំ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៤០] បរិបុណ្ណកាឋិនសវស្សំ តិហិកតំ ទ្វេ វស្សានិ ឆសុ ជម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៤១] បរិបុណ្ណកាឋិនសវស្សំ តិហិកតំ ទ្វេ វស្សានិ ឆសុ ជម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋា-បេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៤២] សហជីវិនឹ វុដ្ឋាបេត្វា ទ្វេ វស្សានិ នេវ អនុគ្គណ្ហន្តី ជានុគ្គហាបេន្តី ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៧៤៣] វុដ្ឋាបិតំ បវត្តិនឹ ទ្វេ វស្សានិ ជានុពន្ធន្តី ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៧៤៤] សហជីវិនឹ វុដ្ឋាបេត្វា នេវ វូបកាសេន្តី ន វូបកាសាបេន្តី ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

គព្ភិនីវគ្គោ សត្តមោ ។

[៧៤០] ភិក្ខុនីឲ្យឧបសម្បទា ដល់ស្ត្រីគ្រហស្ថមានវស្សាគ្រប់ ១២ ឆ្នាំ ដែលមិនទាន់បានសិក្សាសិក្ខាក្នុងធម៌ ៦ ប្រការអស់ ២ វស្សា ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៤១] ភិក្ខុនីឲ្យឧបសម្បទា ដល់ស្ត្រីគ្រហស្ថមានវស្សាគ្រប់ ១២ ឆ្នាំហើយបានសិក្សាសិក្ខាក្នុងធម៌ ៦ ប្រការអស់ ២ វស្សាហើយ តែសង្ឃមិនទាន់បានសម្មតឲ្យ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៤២] ភិក្ខុនីឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី (កូនសិស្ស) ហើយមិនបង្រៀនដោយខ្លួនឯង ឬមិនឲ្យគេបង្រៀនអស់ ២ វស្សា ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៧៤៣] ភិក្ខុនីមិនតាមបម្រើភិក្ខុនីជាបវត្តិនីដែលបំបួស (ខ្លួន) អស់ ២ វស្សា ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៧៤៤] ភិក្ខុនីឲ្យឧបសម្បទា ដល់សិក្ខមានាជាសហជីវិនី ហើយមិននាំយកទៅខ្លួនឯង ឬមិនឲ្យគេនាំយកទៅ ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

ចប់ គព្ភិនីវគ្គ ជាគម្រប់ ៧ ។

[៧៤៥] ឩនវីសតិវស្សំ កុមារីភូតំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៤៦] បរិបុណ្ណវីសតិវស្សំ កុមារីភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៤៧] បរិបុណ្ណវីសតិវស្សំ កុមារីភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៤៨] ឩនទ្វាទសវស្សា វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៤៥] ភិក្ខុនីឲ្យឧបសម្បទា ដល់កុមារីមានវស្សា មិនគ្រប់ ២០ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៤៦] ភិក្ខុនីឲ្យឧបសម្បទា ដល់កុមារីមានឆ្នាំពេញ ២០ ហើយ តែមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ ប្រការអស់ ២ វស្សា ត្រូវអាបត្តិ ២ គឺ ក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទា រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៤៧] ភិក្ខុនីឲ្យឧបសម្បទា ដល់កុមារីមានឆ្នាំពេញ ២០ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ ប្រការអស់ ២ ឆ្នាំ ដែលសង្ឃបានសន្មតឲ្យ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៤៨] ភិក្ខុនីមានវស្សាមិនទាន់គ្រប់ ១២ ហើយឲ្យឧបសម្បទា (គេ) ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៤៩] បរិបុណ្ណភាជនសរស្សា សង្ឃេន អសម្មតា វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៧៥០] អលង្ការ តេ អយ្យេ វុដ្ឋាបិតេជាតិ វុច្ចមានា សាធូតិ បដិស្សុណិត្វា បច្ឆា ទីយនជម្មំ អាបជ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ទីយតិ បយោគេ ទុក្កដំ ទីយិតេ អាបត្តិ ចាចិត្តិយស្ស ។

[៧៥១] សិក្ខមានំ សចេ មេ ត្វំ អយ្យេ ចីវរំ ទស្ស-សិ ឯវាហន្តំ វុដ្ឋាបេស្សាមីតិ វត្វា នេវ វុដ្ឋាបេន្តី ន វុដ្ឋា-បនាយ ឧស្សុក្កំ ករោន្តី ឯកំ អាបត្តឹ អាបជ្ជតិ ចាចិត្តិយំ ។

[៧៥២] សិក្ខមានំ សចេ មំ ត្វំ អយ្យេ ទ្វេ វស្សានិ អនុពន្ធិស្សសិ ឯវាហន្តំ វុដ្ឋាបេស្សាមីតិ វត្វា នេវ វុដ្ឋា-បេន្តី ន វុដ្ឋាបនាយ ឧស្សុក្កំ ករោន្តី ឯកំ អាបត្តឹ អាបជ្ជតិ ចាចិត្តិយំ ។

[៧៤៩] ភិក្ខុនីមានវស្សាមិនគ្រប់ ១២ ហើយ តែសង្ឃមិនទាន់បានសន្មតឲ្យ ហើយឲ្យឧបសម្បទា (គេ) ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៥០] ភិក្ខុនី កាលដែលសង្ឃ និយាយថា នែលោកម្ចាស់ លោកមិនគួរឲ្យឧបសម្បទានៅឡើយទេដូច្នេះ ក៏ទទួលថា សាធុហើយ គ្រាក្រោយ ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងតិះដៀល ត្រូវអាបត្តិទុក្កដ លុះតិះដៀលហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៥១] ភិក្ខុនីនិយាយនឹងសិក្ខមានាថា នែនាង បើនាងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទា (ដល់មកខាងក្រោយ) ក៏មិនឲ្យ (សិក្ខមានានោះ) បានឧបសម្បទា ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យបានឧបសម្បទា ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

[៧៥២] ភិក្ខុនីនិយាយ នឹងសិក្ខមានាថា នែនាង បើនាងតាមបម្រើយើងអស់ ២ ឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទា (ដល់មកខាងក្រោយ) ក៏មិនឲ្យឧបសម្បទា មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីឲ្យបានឧបសម្បទា ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ ។

៣០៧



[៧៨៣] បុរិសសំសដ្ឋំ កុមារកសំសដ្ឋំ ចណ្ឌឹ សោកាវស្សំ សិក្ខមានំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៧៨៤] មាតាបិតូហិ វា សាមិកេន វា អននុញ្ញាតំ សិក្ខមានំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៧៨៥] ចារិវាសិកច្ឆន្ទទានេន សិក្ខមានំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៧៨៦] អនុវស្សំ វុដ្ឋាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៧៥៣] ភិក្ខុនីឲ្យឧបសម្បទា ដល់សិក្ខមានាដែលនៅប្រឡូកប្រឡំដោយបុរស ដែលនៅប្រឡូកប្រឡំដោយក្មេងប្រុស ជាស្រីកាច បណ្តាលឲ្យកើតសេចក្តីសោក ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៥៤] ភិក្ខុនីឲ្យឧបសម្បទា ដល់សិក្ខមានាដែលមាតាបិតាក្តី ស្វាមីក្តី មិនទាន់បានអនុញ្ញាតឲ្យ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៥៥] ភិក្ខុនីឲ្យឧបសម្បទា ដល់សិក្ខមានា ដោយឲ្យឆន្ទៈឈ្មោះបារិវាសិកៈ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៥៦] ភិក្ខុនីឲ្យឧបសម្បទារាល់ឆ្នាំ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៥៧] ឯកាំ វស្សំ ទេ្វ វុដ្ឋាបេន្តី ទេ្វ អាបត្តិយោ អាបជ្ជតិ វុដ្ឋាបេតិ បយោគេ ទុក្កដំ វុដ្ឋាបិតេ អាបត្តិ បាចិត្តិយស្ស ។

កុមារីភូតវគ្គោ អដ្ឋមោ ។

[៧៥៨] ឆត្តុបាហនំ ធារេន្តី អាបត្តិយោ អាបជ្ជតិ ធារេតិ បយោគេ ទុក្កដំ ធារិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៥៩] យានេន យាយន្តី ទេ្វ អាបត្តិយោ អាបជ្ជតិ យាយតិ បយោគេ ទុក្កដំ យាយិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៦០] សង្ឃាណឹ ធារេន្តី ទេ្វ អាបត្តិយោ អាបជ្ជតិ ធារេតិ បយោគេ ទុក្កដំ ធារិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៦១] ឥត្ថាលង្ការំ ធារេន្តី ទេ្វ អាបត្តិយោ អាបជ្ជតិ ធារេតិ បយោគេ ទុក្កដំ ធារិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៦២] គន្ធវណ្ណកេន នហាយន្តី ទេ្វ អាបត្តិយោ អាបជ្ជតិ នហាយតិ បយោគេ ទុក្កដំ នហានបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៧៥៧] ភិក្ខុនីឲ្យឧបសម្បទា ដល់ស្រ្តីពីររូបក្នុង ១ ឆ្នាំ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលកំពុងឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឲ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ កុមារីភូតវគ្គ ជាគម្រប់ ៨ ។

[៧៥៨] ភិក្ខុនី (មិនឈឺ) បាំងឆត្រ ពាក់ស្បែកជើង ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងបាំង កំពុងពាក់ ត្រូវអាបត្តិទុក្កដ លុះបាំងពាក់ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៥៩] ភិក្ខុនី (មិនឈឺ) ទៅដោយយាន ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលរៀបនឹងទៅ ត្រូវអាបត្តិទុក្កដ លុះទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៦០] ភិក្ខុនីក្រវាត់ខ្សែក្រវាត់ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងក្រវាត់ ត្រូវអាបត្តិទុក្កដ លុះក្រវាត់រួច ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៦១] ភិក្ខុនីទ្រទ្រង់គ្រឿងអលង្ការរបស់ស្រ្តី[១] ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងទ្រទ្រង់ ត្រូវអាបត្តិទុក្កដ លុះទ្រទ្រង់រួច ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៦២] ភិក្ខុនី ងូតទឹក ដោយគ្រឿងក្រអូប និងគ្រឿងលាប ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងងូត ត្រូវអាបត្តិទុក្កដ លុះងូត ត្រូវអាបត្តិបាចិត្តិយៈ ។

---

១ អលង្ការរបស់ស្រ្តីមានឈ្នួត ខ្សែកខ្សែដៃ កងជើង ខ្សែចង្កេះជាដើម ។

[៧៦៣] ភាសិតកេន បិញ្ញាកេន(១) ឧហាយន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ឧហាយតិ បយោគេ ទុក្កដំ ឧហានបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៧៦៤] ភិក្ខុនិយោ ឧម្មទ្ទាបេន្តី បរិមទ្ទាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ឧម្មទ្ទាបេតិ បយោគេ ទុក្កដំ ឧម្មទ្ទិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៦៥] សិក្ខមានាយ ឧម្មទ្ទាបេន្តី បរិមទ្ទាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ឧម្មទ្ទាបេតិ បយោគេ ទុក្កដំ ឧម្មទ្ទិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៦៦] សាមណេរិយា ឧម្មទ្ទាបេន្តី បរិមទ្ទាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ឧម្មទ្ទាបេតិ បយោគេ ទុក្កដំ ឧម្មទ្ទិតេ អាបជ្ជតិ បាចិត្តិយស្ស ។ គិហិនិយា ឧម្មទ្ទាបេន្តី បរិមទ្ទាបេន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ឧម្មទ្ទាបេតិ បយោគេ ទុក្កដំ ឧម្មទ្ទិតេ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុស្ស បុរតោ អនាបុច្ឆា អាសនេ និសីទន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ និសីទតិ បយោគេ ទុក្កដំ និសិន្នេ អាបត្តិ បាចិត្តិយស្ស ។

---

១ វិញ្ញាតកេនាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[៧៦៣] ភិក្ខុនី ផ្ញូតទឹក ដោយគ្រឿងអប់និងគ្រឿងលំអិត ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងផ្ញូត ត្រូវអាបត្តិទុក្កដ លុះផ្ញូតស្រេចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៦៤] ភិក្ខុនីឲ្យភិក្ខុនីផងគ្នាគក់ រឹតប្រាច់ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលរៀបនឹងគក់រឹត ត្រូវអាបត្តិទុក្កដ លុះបានគក់រឹត ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៦៥] ភិក្ខុនីឲ្យសិក្ខមានា គក់ រឹតប្រាច់ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគ ដែលរៀបនឹងគក់ រឹត ត្រូវអាបត្តិទុក្កដ លុះបានគក់រឹត ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៦៦] ភិក្ខុនីឲ្យសាមណេរី គក់ រឹតប្រាច់ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលរៀបនឹងគក់រឹត ត្រូវអាបត្តិទុក្កដ លុះបានគក់រឹត ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុនីឲ្យស្ត្រីជាគ្រហស្ថគក់រឹត ប្រាច់ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលរៀបនឹងគក់រឹត ត្រូវអាបត្តិទុក្កដ លុះបានបានគក់រឹត ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុនីមិនប្រាប់ ហើយអង្គុយលើអាសនៈខាងមុខភិក្ខុ ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលរៀបអង្គុយ ត្រូវអាបត្តិទុក្កដ លុះអង្គុយស៊ប់ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៦៧] អជោកាសកតំ ភិក្ខុំ បញ្ហំ បុច្ឆន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ បុច្ឆតិ បយោគេ ទុក្កដំ បុច្ឆិតេ អាបត្តិ បាចិត្តិយស្ស ។

[៧៦៨] អសង្កច្ចិកា គាមំ បវិសន្តី ទ្វេ អាបត្តិ-យោ អាបជ្ជតិ បឋមំ បាទំ បរិក្ខេបំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

ឆត្តុបាហនវគ្គោ នវមោ ។

នវ វគ្គា ខុទ្ទកា និដ្ឋិតា[១] ។

[៧៦៩] សប្បឹ វិញ្ញាបេត្វា ភុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

[៧៧០] តេលំ វិញ្ញាបេត្វា ភុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

---

១ ឱ. ម. ខុទ្ទកំ និដ្ឋិតំ ។

[៧៦៧] ភិក្ខុនីសួរប្រស្នានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស ត្រូវអាបត្តិ ២ គឺក្នុងប្រយោគដែលកំពុងសួរ ត្រូវអាបត្តិទុក្កដ លុះសួររួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៧៦៨] ភិក្ខុនីគ្មានសំពត់ចោមពុង ចូលទៅកាន់ស្រុក ត្រូវអាបត្តិ ២ គឺឈានជំហានជាបឋម កន្លងរបងស្រុកទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានជាគម្រប់ពីរកន្លងទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ ឆត្តុបាហានវគ្គ ជាគម្រប់ ៩ ។

ចប់ ខុទ្ទកវគ្គ ទាំង ៩ ។

[៧៦៩] ភិក្ខុនី (មិនឈឺ) សូមទឹកដោះរាវយកមកឆាន់ ត្រូវអាបត្តិ ២ គឺកំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៧៧០] ភិក្ខុនី (មិនឈឺ) សូមប្រេងគេយកមកឆាន់ ត្រូវអាបត្តិ ២ គឺកំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

ភិក្ខុនីវិភង្គេ សោឡស មហាវារា អដ្ឋ បាដិទេសនីយា

[៧៧១] មធុំ វិញ្ញាបេត្វា ភុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

[៧៧២] ផាណិតំ វិញ្ញាបេត្វា ភុញ្ជន្តី ទ្វេ អាបត្តិ-យោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេស-នីយស្ស ។

[៧៧៣] មច្ឆំ វិញ្ញាបេត្វា ភុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

[៧៧៤] មំសំ វិញ្ញាបេត្វា ភុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

[៧៧១] ភិក្ខុនី (មិនឈឺ) សូមទឹកឃ្មុំគេយកមកឆាន់ ត្រូវអាបត្តិ ២ គឺកំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៧៧២] ភិក្ខុនី (មិនឈឺ) សូមស្ករអំពៅគេយកមកឆាន់ ត្រូវអាបត្តិ ២ គឺកំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលឆាន់ហើយ) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៧៧៣] ភិក្ខុនី (មិនឈឺ) សូមត្រីគេយកមកឆាន់ ត្រូវអាបត្តិ ២ គឺកំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៧៧៤] ភិក្ខុនី (មិនឈឺ) សូមសាច់អំពីគេយកមកឆាន់ ត្រូវអាបត្តិ ២ គឺកំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៧៧៥] ចីវរំ វិញ្ញាបេត្វា កុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ កុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

[៧៧៦] ទធឹ វិញ្ញាបេត្វា កុញ្ជន្តី ទ្វេ អាបត្តិយោ អាបជ្ជតិ កុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

អដ្ឋ បាដិទេសនីយា និដ្ឋិតា ។

កតាបត្តិវារំ និដ្ឋិតំ ទុតិយំ ។

[៧៧៧] អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ បេ ។

[៧៧៥] ភិក្ខុនី (មិនឈឺ) សូមទឹកដោះស្រស់អំពីគេយកមកឆាន់ ត្រូវអាបត្តិ ២ គឺកំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៧៧៦] ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរអំពីគេយកមកឆាន់ ត្រូវអាបត្តិ ២ គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

ចប់ បាដិទេសនីយៈ ទី ៨ ។

ចប់ កតាបត្តិវារៈ ជាគម្រប់ ២ ។

[៧៧៧] ពួកអាបត្តិរបស់ភិក្ខុនី ដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្ដាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្ដាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។

ភិក្ខុនីវិភង្គេ សោឡស មហាវារា សង្គហវារំ

[៧៧៨] ឧជឹ វិញ្ញាបេត្វា កុញ្ជន្តិយា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ ឧជឹ វិញ្ញាបេ-ត្វា កុញ្ជន្តិយា អាបត្តិយោ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជន្តិ អាចារវិបត្តឹ ។

វិបត្តិវារំ និដ្ឋិតំ តតិយំ ។

[៧៧៩] អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិ-សបុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គ-ហិតា ។ អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិ-សបុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ តីហិ អាបត្តិក្ខន្ធេហិ សង្គ-ហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា ថុល្លច្ច-យាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ បេ ។

[៧៨០] ឧជឹ វិញ្ញាបេត្វា កុញ្ជន្តិយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គ-

[៧៧៨] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះអំពីគេយកមកឆាន់ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរអំពីគេយកមកឆាន់ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺ អាចារវិបត្តិ ។

ចប់ វិបត្តិវារៈ ជាគម្រប់ ៣ ។

[៧៧៩] ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្រ្គោះដោយកងនៃអាបត្តិប៉ុន្មាន ។ ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្រ្គោះដោយកងនៃអាបត្តិ ៣ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បេ ។

[៧៨០] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរអំពីគេយកមកឆាន់ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្រ្គោះដោយកងនៃអាបត្តិ

ហិតា ។ ឧជឹ វិញ្ញាបេត្វា កុញ្ជន្តិយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ ទ្វីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថាដិទេសនីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។

សង្គហាវារំ និដ្ឋិតំ ចតុត្ថំ ។

[៧៨១] អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិស-បុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋ-ហន្តិ ។ អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិស-បុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋ-ហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ បេ ។

[៧៨២] ឧជឹ វិញ្ញាបេត្វា កុញ្ជន្តិយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ ស-មុដ្ឋហន្តិ ។ ឧជឹ វិញ្ញាបេត្វា កុញ្ជន្តិយា អាបត្តិយោ

ប៉ុន្មាន ។ ពួកអាបត្តិរបស់ភិក្ខុនី ដែលសូមទឹកដោះជូរអំពីគេយកមកឆាន់ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។

ចប់ សង្គហវារៈ ជាគម្រប់ ៤ ។

[៧៨១] ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បេ ។

[៧៨២] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្តា

ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋាហន្តិ សិយា កាយតោ សមុដ្ឋាហន្តិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋាហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាហន្តិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាហន្តិ ។

សមុដ្ឋានវារំ និដ្ឋិតំ បញ្ចមំ ។

[៧៨៣] អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ បេ ។

[៧៨៤] ឆដ្ឋី វិញ្ញាបេត្វា ភុញ្ជន្តិយា អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ ឆដ្ឋី វិញ្ញាបេត្វា ភុញ្ជន្តិយា អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។

អធិករណវារំ និដ្ឋិតំ ឆដ្ឋំ ។

សមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងអំពីសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយ វាចា និងចិត្តក៏មាន ។

ចប់ សមុដ្ឋានវារៈគម្រប់ ៥ ។

[៧៨៣] ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈដែរ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈដែរ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។ បេ ។

[៧៨៤] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។

ចប់ អធិករណវារៈ ជាគម្រប់ ៦ ។

[៧៨៥] អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តិយា អាបត្តិយោ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។

[៧៨៦] ឧជ្ឈិ វិញ្ញាបេត្វា ភុញ្ជន្តិយា អាបត្តិយោ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ ឧជ្ឈិ វិញ្ញាបេត្វា ភុញ្ជន្តិយា អាបត្តិយោ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមថវារំ និដ្ឋិតំ សត្តមំ ។

[៧៨៥] ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈដែរ បណ្តាសមថៈទាំង ៧ រំងាប់ដោយសមថៈប៉ុន្មាន ។ ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយ របស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈដែរ បណ្តាសមថៈទាំង ៧ តែងរំងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។ បេ ។

[៧៨៦] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្តាសមថៈទាំង ៧ រំងាប់ដោយសមថៈប៉ុន្មាន ។ ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្តាសមថៈទាំង ៧ តែងរំងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

ចប់ សមថវារៈ ជាគម្រប់ ៧ ។

៣១៧

ភិក្ខុនីវិភង្គេ សោឡស មហាវារា សមុច្ចយវារំ

[៧៨៧] អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តី កតិ អាបត្តិយោ អាបជ្ជតិ ។ អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តី តិស្សោ អាបត្តិយោ អាបជ្ជតិ អធក្ខកំ ឧព្ភជានុមណ្ឌលំ គហណំ សាទិយតិ អាបត្តិ បារាជិកស្ស ឧព្ភក្ខកំ អធោជានុមណ្ឌលំ គហណំ សាទិយតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធំ គហណំ សាទិយតិ អាបត្តិ ទុក្កដស្ស អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយន្តី ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា

[៧៨៧] ភិក្ខុនីមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ ត្រូវអាបត្តិ ៣ គឺត្រេកអរនឹងការចាប់ពាល់នូវ (សរីរប្រទេស) ពីខាងក្រោមដងកាំបិតចុះមកដល់ខាងលើមណ្ឌលជង្គង់ ត្រូវអាបត្តិបារាជិក ត្រេកអរនឹងការចាប់ពាល់នូវ (សរីរប្រទេស) ពីខាងលើដងកាំបិត និងខាងក្រោមនៃមណ្ឌលជង្គង់ ត្រូវអាបត្តិថុល្លច្ច័យ ត្រេកអរនឹងការចាប់ពាល់នូវវត្ថុជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ ត្រូវអាបត្តិទាំង ៣ នេះ ។ បណ្ដាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្ដាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្ដាអធិករណ៍ ៤ ចាត់ជាអធិករណ៍ណា ។ បណ្ដាសមថៈ ៧ រំងាប់ដោយសមថៈប៉ុន្មាន ។ បណ្ដាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន

អាចារវិបត្តី ។ សត្តន្នំ អាបត្តិក្ខន្ធានំ តីហិ អាបត្តិ-ក្ខន្ធេហិ សង្គហិតា សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេ-ន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។

[៧៨៨] ឧជ្ឈាបេន្តោ កុញ្ចន្តី កតិ អាបត្តិ-យោ អាបជ្ជតិ ។ ឧជ្ឈាបេន្តោ កុញ្ចន្តី ទ្វេ អា-បត្តិយោ អាបជ្ជតិ កុញ្ចិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ថាជិនេ-សជីយស្ស ឧជ្ឈាបេន្តោ កុញ្ចន្តី ឥមា ទ្វេ អា-បត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិ-

អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកង នៃអាបត្តិ ៣ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើង ដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ឡើយ ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។ បេ ។

[៧៨៨] ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ត្រូវ អាបត្តិប៉ុន្មាន ។ ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ត្រូវ អាបត្តិ ២ គឺកំពុងទទួលប្រគេនដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលឆាន់ហើយ) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ត្រូវអាបត្តិទាំងពីរនេះ ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកង នៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើយដោយ

សមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជន្តិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ទ្វីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថាជិនេសជីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមុច្ចយវារំ និដ្ឋិតំ អដ្ឋមំ ។

សមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

ចប់ សមុច្ចយវារៈ ជាគម្រប់ ៨ ។

[៧៨៩] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន កាយសំសគ្គំ សាទិយនប្បច្ចយា បារាជិកំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សុន្ទរីនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សុន្ទរីនន្ទា ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នបញ្ញត្តីតិ ។ ឯកា បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នបញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេសបញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណបញ្ញត្តិ អសាធារណបញ្ញត្តីតិ ។ អសាធារណបញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ ចតុន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ទុតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ បារាជិកា-

[៧៨៩] បារាជិកណា ដែលព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ (នូវកាលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍) ព្រោះបច្ច័យនៃសេចក្ដីត្រេកអរនឹងការប៉ះពាល់កាយ (របស់បុរសបុគ្គល) បារាជិកនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងសុន្ទរីនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលសុន្ទរីនន្ទា-ភិក្ខុនីមានចិត្តជោកដោយរាគៈ ត្រេកអរនឹងប៉ះពាល់កាយ របស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈដែរ ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិដែរឬ ។ មានតែបញ្ញត្តិ ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិមិនមានក្នុងសិក្ខាបទនោះទេ ។ (សិក្ខាបទនោះ) ជាសព្វ-ត្ថបញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថបញ្ញត្តិ ។ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង ៤ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ចាត់ចូលក្នុងនិទា-នុទ្ទេស រាប់បញ្ចូលក្នុងនិទានុទ្ទេស ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទីប៉ុន្មាន ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ២ ។ បណ្ដាវិបត្តិ ៤ ជាវិបត្តិអ្វី ។ ជាសីល-វិបត្តិ ។ បណ្ដាកងនៃអាបត្តិទាំង ៧ ជាកងនៃអាបត្តិអ្វី ។ ជាកងនៃអាបត្តិ

បត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។ កោធាភជន្តិ ។ បរម្បរាភជំ ។ បេ ។

[៧៩០] វជ្ជប្បដិច្ឆាទនប្បច្ចយា ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី ជានំ ចារាជិកំ ធម្មំ អជ្ឈាបន្នំ ភិក្ខុនឹ នេវ អត្តនា បដិចោទេសិ ន គណស្ស អារោចេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

[៧៩១] យាវតតិយំ សមនុភាសនាយ នប្បដិ-និស្សជ្ជនប្បច្ចយា ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ អនុវត្តិ តស្មឹ វត្ថុស្មឹ ។

បារាជិក ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ប៉ុន្មាន ។ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។ បេ ។ លោកណាបាននាំមក ។ ព្រះថេរៈទាំងឡាយនាំត ៗ គ្នាមក ។ បេ ។

[៧៩០] អាបត្តិបារាជិក ព្រោះបច្ច័យនៃការបិទបាំងទោស ព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីដឹងថា ភិក្ខុនីផងគ្នាត្រូវអាបត្តិបារាជិកហើយ មិនចោទដោយខ្លួនឯង ទាំងមិនបានប្រាប់ដល់គណភិក្ខុនី ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេប) ។

[៧៩១] អាបត្តិបារាជិក ព្រោះបច្ច័យនៃការមិនលះបង់ (នូវទិដ្ឋិ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្ម ចប់ជាគម្រប់បីដង ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីប្រព្រឹត្តតាមអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ដែលសង្ឃបានព្រមព្រៀងគ្នាលើកវត្ត ។

ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

[៧៩២] អដ្ឋមំ វត្ថុំ បរិបូរណាប្បច្ចយា ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្ព-គ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្ពគ្គិយា ភិក្ខុនិយោ អដ្ឋមំ វត្ថុំ បរិបូរេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

បារាជិកា និដ្ឋិតា ។

[៧៩៣] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧស្សយវាទិកាយ ភិក្ខុ-និយា អដ្ដករណាប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។

(សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេប) ។

[៧៩២] អាបត្តិបារាជិក ព្រោះបច្ច័យនៃការបំពេញវត្ថុជាគម្រប់ ៨[១] ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនីបំពេញវត្ថុជាគម្រប់ ៨ ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេប) ។

ចប់ បារាជិក ។

[៧៩៣] សង្ឃាទិសេសណា ដែលព្រះមានព្រះភាគជាអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ (នូវកាលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍) ព្រោះបច្ច័យនៃកិរិយាធ្វើដំណើរក្តី របស់ភិក្ខុនីជាអ្នកប្តឹងផ្តល់ សង្ឃាទិសេសនោះ ព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។

១ វត្ថុទាំង ៨ គឺ ១ ត្រេកអរនឹងការចាប់ដៃរបស់បុរសបុគ្គល ២ ត្រេកអរនឹងការចាប់ជាយសង្ឃាដីរបស់បុរសបុគ្គល ៣ ឈរជាមួយនឹងបុរសបុគ្គល ៤ ចរចាជាមួយបុរសបុគ្គល ៥ ទៅកាន់ទីសង្កេត ៦ ត្រេកអរនឹងបុរសដើរចូលមកជិត ៧ ចូលទៅកាន់ទីកំបាំង ៨ បង្អោនកាយទៅ ដើម្បីសេពនូវអសទ្ធម្ម (ភិក្ខុនីវិភង្គ) ។

ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី ឧស្សយវាទិកា វិហរិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នបញ្ញត្តីតិ ។ ឯកា បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នបញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេសបញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណបញ្ញត្តិ អសាធារណបញ្ញត្តីតិ ។ អសាធារណបញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ ចតុន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ តតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ សង្ឃាទិសេសាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។ កោណាភជន្តិ ។ បរម្បាភជំ ។

ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីជាអ្នកប្តឹងផ្តល់ ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ ដែរឬ ។ មានតែបញ្ញត្តិ ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ ។ (សិក្ខាបទនោះ) ជាសព្វត្ថបញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ ជាសាធារណ-ប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ ជាឯក-តោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុ-ទ្ទេសទាំង ៤ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ចាត់ចូលក្នុងនិទានុទ្ទេស រាប់បញ្ចូលក្នុងនិទានុទ្ទេស ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៣ ។ បណ្តាវិបត្តិទាំង ៤ ចាត់ជាវិបត្តិអ្វី ។ ចាត់ជាសីលវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ ចាត់ជាកងនៃអាបត្តិណា ។ ចាត់ជាកងនៃអាបត្តិសង្ឃាទិសេស ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ តាំងឡើងដោយសមុដ្ឋាន ២ គឺតាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយអំពីវាចានិងចិត្តក៏មាន ។ បេ ។ (សិក្ខាបទនោះ) លោកណាបាននាំមក ។ ព្រះថេរៈទាំងឡាយនាំត ៗ គ្នាមក ។

[៧៩៨] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចោរី វុដ្ឋាបនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី ចោរឹ វុដ្ឋាបេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៧៩៩] ឯកាយ[១] គាមន្តរំ គមនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អញ្ញតរំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អញ្ញតរា ភិក្ខុនី ឯកា គាមន្តរំ គច្ឆិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ តិស្សោ អនុប្បញ្ញត្តិយោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (បឋមបារាជិកោ) ។

១ ម. ឯកា គាមន្តរំ ។

[៧៩៤] សង្ឃាទិសេសណា ដែលព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធអង្គនោះទ្រង់ជ្រាបច្បាស់ (នូវកាលគួរបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍) ព្រោះបច្ច័យនៃកិរិយាបំបួសស្ត្រីចោរ សង្ឃាទិសេសនោះព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីបំបួសស្ត្រីចោរ ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ២ គឺតាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន ។

[៧៩៥] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីដើរទៅកាន់ចន្លោះស្រុកម្នាក់ឯង ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុនី ១ រូប ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលភិក្ខុនី ១ រូបដើរទៅកាន់ចន្លោះស្រុកម្នាក់ឯង ។ (សិក្ខាបទនោះ) មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ៣ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងបឋមបារាជិក) ។

[៧៩៦] សមន្តេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនី ជម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារណប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី សមន្តេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនឹ ជម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

[៧៩៧] អវស្សុតាយ ភិក្ខុនិយា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ សុន្ទរីនន្ទំ ភិក្ខុនឹ ។ កិស្មឹ វត្ថុស្មិន្តិ ។

[៧៩៦] សង្ឃាទិសេសរបស់ភិក្ខុនី ដែលមិនបានប្រាប់ការកសង្ឃ ទាំងមិនដឹងសេចក្ដីប្រាថ្នារបស់គណៈ ហើយសូត្រហៅភិក្ខុនី ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ឲ្យចូលមកកាន់ពួក ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីមិនបានប្រាប់ការកសង្ឃ ទាំងមិនដឹងសេចក្ដីប្រាថ្នារបស់គណៈ ហើយសូត្រហៅភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា (ឲ្យចូលមកកាន់ពួក) ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេប) ។

[៧៩៧] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនី មានចិត្តជោកដោយរាគៈ ទទួលខាទនីយភោជនីយាហារ អំពីដៃបុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ ដោយដៃខ្លួនឯងហើយឆាន់ ព្រះសម្មាសម្ពុទ្ធបញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងសុន្ទរីនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្ដេច ។

សុទ្ធវីតិក្កមា ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គ-លស្ស ហត្ថតោ អាមិសំ បដិគ្គហេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (បឋមបារាជិកេ) ។

[៧៩៨] កិន្តេ អយ្យេ ឯសោ បុរិសបុគ្គលោ ករិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អនវស្សុតា ឥង្ឃយ្យេ យន្តេ ឯសោ បុរិសបុគ្គលោ ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា បដិគ្គហេត្វា ខាទ វា ភុញ្ជ វាតិ ឧយ្យោជនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញ-ត្តោ ។ កំ អារព្ភាតិ ។ អញ្ញតរំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អញ្ញតរា ភិក្ខុនី កិន្តេ អយ្យេ ឯសោ បុរិសបុគ្គលោ ករិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អនវស្សុតា ឥង្ឃយ្យេ យន្តេ ឯសោ បុរិ-សបុគ្គលោ ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ

ព្រោះរឿងដែលសុន្ទរីនន្ទាភិក្ខុនី មានចិត្តជោកដោយរាគៈ ទទួលអាមិសៈអំពីដៃបុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ) ។

[៧៩៨] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នៃនាង បុរសបុគ្គលនេះ មានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នៃនាង ណ្ហើយចុះ កាលណាបើនាងមិនមានតម្រេកហើយ បើបុរសបុគ្គលនេះ ឲ្យវត្ថុណាជាខាទនីយៈក្តី ជាភោជនីយៈក្តី ដល់នាង នាងចូរទទួលវត្ថុនោះ ដោយដៃរបស់ខ្លួនហើយទំពាស៊ី ឬបរិ-ភោគចុះ ដូច្នេះ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុនី ១ រូប ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលភិក្ខុនី ១ រូប បញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នៃនាង បុរសបុគ្គលនោះ មានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នៃនាង ណ្ហើយចុះ កាលណាបើនាងមិនមានតម្រេកហើយ បើបុរសបុគ្គលនោះឲ្យវត្ថុណាជាខាទនីយៈក្តី ជាភោជនីយៈក្តី

សហត្ថា បដិក្កហេត្វា ខាទេ វា ភុញ្ជេ វាតិ ឧយ្យោជេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋា-នានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៧៩៩] កុបិតាយ ភិក្ខុនិយា យាវតតិយំ សម-នុភាសនាយ នប្បដិនិស្សជ្ជន្តប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អា-រព្ភាតិ ។ ចណ្ឌកាលឹ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ចណ្ឌកាលី ភិក្ខុនី កុបិតា អនត្តមនា ឯវំ អវច ពុទ្ធំ បច្ចាចិក្ខាមិ ធម្មំ បច្ចាចិក្ខាមិ សង្ឃំ បច្ចាចិក្ខាមិ សិក្ខំ បច្ចាចិក្ខាមីតិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

[៨០០] កិស្មិញ្ចិ(?)ទេវ អធិករណេ បច្ចាកតាយ កុបិតាយ ភិក្ខុនិយា យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តប្បច្ចយា សង្ឃាទិសេសោ កត្ថ

ដល់នាង នាងចូរទទួលយកវត្ថុនោះដោយដៃរបស់ខ្លួន ហើយទំពាស៊ី ឬ បរិភោគចុះ ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ៣ ។

[៧៩៩] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីក្រោធខឹង (នឹងភិក្ខុនីផងគ្នា) កាលបើសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់ ៣ ដងហើយ នៅតែមិនលះបង់ (នូវអំពើនោះចេញ) ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលចណ្ឌកាលីភិក្ខុនីខឹងអន់ចិត្ត ក៏ពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខាបទ ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ) ។

[៨០០] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីដែលសង្ឃធ្វើឲ្យចាញ់ព្រោះអធិករណ៍អ្វីនីមួយហើយខឹង កាលបើសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់ ៣ ដង ហើយនៅតែមិនលះបង់ (នូវអំពើនោះ) ចេញ

បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ ចណ្ឌកាលឹ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ចណ្ឌកាលី ភិក្ខុនី កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ អវច ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ទោសគាមិនិយោ ច ភិក្ខុនិយោ មោហគាមិនិយោ ច ភិក្ខុនិយោ ភយគាមិនិយោ ច ភិក្ខុនិយោតិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

[៨០១] សំសដ្ឋានំ ភិក្ខុនីនំ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តិយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ សម្ពហុលា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខុនិយោ សំសដ្ឋា វិហរឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។

ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងចណ្ឌកាលីភិក្ខុនីដែលសង្ឃឲ្យចាញ់ ព្រោះអធិករណ៍អ្វីនីមួយ ហើយខឹងអាក់អន់ចិត្តបាននិយាយយ៉ាងនេះថា ភិក្ខុនីទាំងឡាយ លុះដោយសេចក្តីស្រឡាញ់ផង ភិក្ខុនីទាំងឡាយ លុះដោយសេចក្តីខឹងផង ភិក្ខុនីទាំងឡាយ លុះដោយសេចក្តីល្ងង់ផង ភិក្ខុនីទាំងឡាយ លុះដោយសេចក្តីខ្លាចផង ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ) ។

[៨០១] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីទាំងឡាយ នៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) សង្ឃបានសូត្រសមនុភាសនកម្មចប់ ជាគម្រប់ ៣ ដងហើយនៅតែមិនលះបង់ (នូវអំពើនោះ) ចេញ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប នៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ) ។

[៨០២] សំសដ្ឋា វយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថាតិ ឧយ្យោជេន្តិយា យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ ថុល្លនន្ទំ ភិក្ខុនឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ថុល្លនន្ទា ភិក្ខុនី សំសដ្ឋា វយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថាតិ ឧយ្យោជេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ (ធុរនិក្ខេបេ) ។ បេ ។

[៨០៣] ទធឹ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា បាដិទេសនីយំ កត្ថ បញ្ញត្តន្តិ ។ សាវត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខុនិយោ ទធឹ វិញ្ញាបេត្វា ភុញ្ជឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ

[៨០២] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នៃលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅប្រឡូកប្រឡំ (ដោយគ្រហស្ថ) ចុះ កុំនៅបែកខ្ញែកគ្នាឡើយ សង្ឃបានសូត្រសមនុភាសនកម្មចប់ជា គម្រប់ ៣ ដងហើយ នៅតែមិនលះបង់ (នូវអំពើនោះ) ចេញ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នាដោយពាក្យថា នៃលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅប្រឡូកប្រឡំ (ដោយគ្រហស្ថ) ចុះ កុំនៅបែកខ្ញែកគ្នាឡើយ ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ) ។ បេ ។

[៨០៣] បាដិទេសនីយៈ ព្រោះបច្ច័យនៃភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ។ (សិក្ខាបទនោះ) មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើង

សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ[១] ។

កត្ថបញ្ញត្តិវារំ និដ្ឋិតំ បឋមំ ។

[៨០៤] កាយសំសគ្គំ សាទិយនប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ កាយសំសគ្គំ សាទិយនប្បច្ចយា បញ្ច អាបត្តិយោ អាបជ្ជតិ អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គលស្ស អធក្ខកំ ឧព្ភជានុមណ្ឌលំ គហណំ សាទិយតិ អាបត្តិ បារាជិកស្ស ភិក្ខុ កាយេន កាយំ អាមសតិ អាបត្តិ សង្ឃាទិសេសស្ស កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស អង្គុលិប្បតោទកេ បាចិត្តិយំ កាយសំសគ្គំ សាទិយនប្បច្ចយា ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។

---

១ ឱ. ម. បោត្ថកេសុ សិយា កាយតោ ។ ល ។ ចិត្តតោ ច សមុដ្ឋាតីតិ ន ទិស្សតិ ។

ដោយសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន ។

ចប់ កត្ថបញ្ញត្តិវារៈ ជាបឋម ។

[៨០៤] ភិក្ខុ ឬភិក្ខុនីត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាត្រេកអរនឹងការចាប់ពាល់កាយ (របស់បុរសបុគ្គល) ។ ត្រូវអាបត្តិ ៥ ព្រោះបច្ច័យនៃកិរិយាត្រេកអរ នឹងការប៉ះពាល់កាយ គឺភិក្ខុនីមានតម្រេកត្រេកអរនឹងការចាប់ពាល់ (នូវសរីរប្រទេស) របស់បុរសបុគ្គលដែលមានតម្រេកដែរ តាំងពីខាងក្រោមដងកាំបិតចុះមកដល់មណ្ឌលជង្គង់ ខាងលើត្រូវអាបត្តិបារាជិក ភិក្ខុចាប់ពាល់កាយ (ស្រី) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិសង្ឃាទិសេស ចាប់ពាល់វត្ថុដែលជាប់នឹងកាយ (ស្រី) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ ចាប់ពាល់វត្ថុដែលជាប់ដោយកាយ (ស្រី) ដោយវត្ថុដែលជាប់នឹងកាយ (ខ្លួន) ត្រូវអាបត្តិទុក្កដ ចាក់ក្រឡេកភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុនិងភិក្ខុនីត្រូវអាបត្តិ ៥ នេះ ព្រោះបច្ច័យនៃកិរិយាត្រេកអរនឹងការប៉ះពាល់កាយ ។

[៨០៥] វជ្ជំ បដិច្ឆាទនប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ វជ្ជំ បដិច្ឆាទនប្បច្ចយា ចតស្សោ អាបត្តិយោ អាបជ្ជតិ ភិក្ខុនី ជានំ បារាជិកំ ធម្មំ អជ្ឈាបន្នំ បដិច្ឆាទេតិ អាបត្តិ បារាជិកស្ស វេមតិកា បដិច្ឆាទេតិ អាបត្តិ ថុល្លច្ចយស្ស ភិក្ខុ សង្ឃាទិសេសំ បដិច្ឆាទេតិ អាបត្តិ បាចិត្តិយស្ស អាចារវិបត្តឹ បដិច្ឆាទេតិ អាបត្តិ ទុក្កដស្ស វជ្ជំ បដិច្ឆាទនប្បច្ចយា ឥមា ចតស្សោ អាបត្តិយោ អាបជ្ជតិ ។

[៨០៦] យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា បញ្ច អាបត្តិយោ អាបជ្ជតិ ឧក្ខិត្តានុវត្តិកា ភិក្ខុនី យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ បារាជិកស្ស ភេទានុវត្តិកា ភិក្ខុនី យាវតតិយំ

[៨០៥] ភិក្ខុ ឬភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាបិទបាំងទោស ។ ត្រូវអាបត្តិ ៤ យ៉ាង ព្រោះបច្ច័យនៃកិរិយាបិទបាំងទោស គឺភិក្ខុនីដឹងថា ភិក្ខុនីផងគ្នាត្រូវអាបត្តិបារាជិកហើយបិទបាំងទុក ត្រូវអាបត្តិបារាជិក ភិក្ខុនីមានសេចក្តីសង្ស័យហើយបិទបាំងទុក ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុបិទបាំងអាបត្តិសង្ឃាទិសេស (របស់ភិក្ខុផងគ្នា) ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុបិទបាំងអាចារវិបត្តិ ត្រូវអាបត្តិទុក្កដ ភិក្ខុនិងភិក្ខុនី ត្រូវអាបត្តិទាំង ៤ នេះ ព្រោះបច្ច័យនៃកិរិយាបិទបាំងទោសទុក ។

[៨០៦] ភិក្ខុនិងភិក្ខុនីត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាមិនលះបង់ (អំពើនោះ ៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសកម្មចប់ជាគម្រប់ ៣ ដង ។ ត្រូវអាបត្តិ ៥ យ៉ាង ព្រោះបច្ច័យនៃកិរិយាមិនលះបង់ (នូវអំពើនោះ ៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគម្រប់ ៣ ដង ឧក្ខិត្តានុវត្តិកាភិក្ខុនី[១] មិនលះ (អំពើនោះ ៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគម្រប់ ៣ ដង កាលចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាស្រេច ត្រូវអាបត្តិបារាជិក ភេទានុវត្តិកាភិក្ខុនី[២] មិនលះ (អំពើនោះ ៗ)

---

១ ភិក្ខុនីអ្នកប្រព្រឹត្តតាមភិក្ខុ ភិក្ខុនីដែលសង្ឃលើកវត្តហើយ ។ ២ ភិក្ខុនីអ្នកប្រព្រឹត្តតាមភិក្ខុ ភិក្ខុនីអ្នកបំបែកសង្ឃ ។

សមនុភាសនាយ នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិ-សេសស្ស ។ ចាបិកាយ ទិដ្ឋិយា យាវតតិយំ សម-នុភាសនាយ នប្បដិនិស្សជ្ជតិ អាបត្តិ បាចិត្តិយស្ស យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។

[៨០៧] អដ្ឋមំ វត្ថុំ បរិបូរណប្បច្ចយា កតិ អា-បត្តិយោ អាបជ្ជតិ ។ អដ្ឋមំ វត្ថុំ បរិបូរណប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ បុរិសេន ឥត្ថន្នាមំ អា-គច្ឆាតិ វុត្តា គច្ឆតិ អាបត្តិ ទុក្កដស្ស បុរិសស្ស ហត្ថបាសំ ឱក្កន្តមត្តេ អាបត្តិ ថុល្លច្ចយស្ស អដ្ឋមំ វត្ថុំ បរិបូរេតិ អាបត្តិ បារាជិកស្ស អដ្ឋមំ វត្ថុំ បរិ-បូរណប្បច្ចយា ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

បារាជិកា និដ្ឋិតា ។

[៨០៨] ឧស្សយវាទិកា[១] ភិក្ខុនី អដ្ដករណប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ឯកស្ស អារោចេតិ អាបត្តិ ទុក្កដស្ស ទុតិយស្ស អារោចេតិ អាបត្តិ ថុល្លច្ចយស្ស អដ្ដបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

១ ឱ. ម. ឧស្សយវាទិកា ។

ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់គម្រប់ ៣ ដងហើយ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមិនលះទិដ្ឋិដ៏លាមក ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់ ៣ ដង ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុនិងភិក្ខុនី ត្រូវអាបត្តិទាំង ៥ នេះ ព្រោះបច្ច័យនៃកិរិយាមិនលះបង់ (អំពើនោះ ៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគម្រប់ ៣ ដង ។

[៨០៧] ភិក្ខុនីត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាបំពេញវត្ថុជាគម្រប់ ៨ ។ ត្រូវអាបត្តិ ៣ យ៉ាង ព្រោះបច្ច័យនៃកិរិយាបំពេញវត្ថុជាគម្រប់ ៨ គឺភិក្ខុនី កាលបើបុរសនិយាយថា នាងចូរមកកាន់ទីឈ្មោះនេះ ហើយដើរទៅត្រូវអាបត្តិទុក្កដ លុះដើរចូលទៅកាន់ហត្ថបាសរបស់បុរស ត្រូវអាបត្តិថុល្លច្ច័យ បំពេញវត្ថុជាគម្រប់ ៨ ឲ្យពេញ ត្រូវអាបត្តិបារាជិក ភិក្ខុនីត្រូវអាបត្តិទាំង ៣ នេះ ព្រោះបច្ច័យនៃកិរិយាបំពេញវត្ថុជាគម្រប់ ៨ ។

ចប់ បារាជិក ។

[៨០៨] ភិក្ខុនីជាអ្នកប្តឹងផ្តល់ ត្រូវអាបត្តិ ៣ យ៉ាង ព្រោះបច្ច័យនៃកិរិយាបង្កដំណើរក្តី គឺនិយាយប្រាប់ដល់បុគ្គលម្នាក់ ត្រូវអាបត្តិទុក្កដ និយាយប្រាប់ដល់បុគ្គលជាគម្រប់ពីរ ត្រូវអាបត្តិថុល្លច្ច័យ លុះសម្រេចដំណើរក្តី ត្រូវអាបត្តិសង្ឃាទិសេស ។

៣៣៣

ភិក្ខុនីវិភង្គេ សោឡស មហាវារា សង្ឃាទិសេសា

[៨០៩] ចោរី វុដ្ឋាបនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៨១០] ឯកា គាមន្តរំ គមនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ គច្ឆតិ អាបត្តិ ទុក្កដស្ស បឋមំ ចាទំ បរិក្ខេបំ អតិក្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ទុតិយំ ចាទំ អតិក្កាមេតិ អាបត្តិ សង្ឃាទិសេសស្ស ។

[៨១១] សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនឹ ធម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារណប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៨០៩] ភិក្ខុនីត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាបំបួសស្រីចោរ គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨១០] ភិក្ខុនីត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាដើរទៅកាន់ចន្លោះស្រុកតែម្នាក់ឯង គឺដើរទៅត្រូវអាបត្តិទុក្កដ ឈានជំហានជាបឋមកន្ទង់របងស្រុកទៅ ត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានជាគម្រប់ពីរកន្ទង់ទៅ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨១១] ភិក្ខុនីត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាមិនប្រាប់ការកសង្ឃ ទាំងមិនដឹងសេចក្តីប្រាថ្នារបស់គណៈ ហើយសូត្រហៅភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្ត តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា (ឲ្យចូលមកកាន់ពួក) គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨១២] អវស្សុតា ភិក្ខុនី អវស្សុតស្ស បុរិសបុគ្គ-លស្ស ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា កុញ្ជនប្បច្ចយា តិស្សោ អាបត្តិយោ អា-បជ្ជតិ ខាទិស្សាមិ កុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ថុល្លច្ចយស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ សង្ឃា-ទិសេសស្ស ឧទកាទន្តបោណំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

[៨១៣] ភិន្ទេ អយ្យេ ឯសោ បុរិសបុគ្គលោ កា-រិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អន-វស្សុតា ឥង្ឃយ្យេ យន្តេ ឯសោ បុរិសបុគ្គលោ ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា បដិគ្គ-ហេត្វា ខាទ វា កុញ្ជ វាតិ ឧយ្យោជនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ តស្សា វចនេន ខាទិស្សាមិ កុញ្ជិ-ស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ថុល្លច្ចយស្ស ភោជនបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៨១២] ភិក្ខុនីមានតម្រេកត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាទទួលខាទនីយៈ ឬភោជនីយាហារ អំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃរបស់ខ្លួនហើយបរិភោគ គឺកំពុងទទួលដោយគិតថា អាត្មាអញនឹងទំពាស៊ី នឹងឆាន់ ត្រូវអាបត្តិថុល្លច្ច័យ (លុះទទួលហើយបរិភោគ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ៗ វារៈដែលលេបចូលទៅ លុះទទួលទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។

[៨១៣] ភិក្ខុនីត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាបញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នែនាង បុរសបុគ្គលនោះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នែនាង ណ្ហើយចុះ កាលណាបើនាងមិនមានតម្រេកទេ បុរសបុគ្គលនោះ ឲ្យវត្ថុណាជាខាទនីយៈក្តី ជាភោជនីយៈក្តី ដល់នាង ក៏នាងចូរទទួលវត្ថុនោះ ដោយដៃរបស់ខ្លួនហើយទំពាស៊ី ឬបរិភោគចុះ ដូច្នេះ គឺកំពុងទទួលដោយគិតថា អាត្មាអញនឹងទំពាស៊ីនឹងឆាន់ តាមពាក្យរបស់ភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិថុល្លច្ច័យគ្រប់ ៗ វារៈដែលលេបចូលទៅ លុះឆាន់រួចហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨១៤] កុបិតា ភិក្ខុនី យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៨១៥] កតិស្មិញ្ចេវ អធិករណោ បច្ចាកតា កុបិតា[១] ភិក្ខុនី យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៨១៦] សំសដ្ឋា ភិក្ខុនី យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[៨១៧] សំសដ្ឋា វយ្យេ[២] តុម្ហេ វិហរថ មា តុម្ហេ នានា វិហរត្ថាតិ ឧយ្យោជេន្តី យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនប្បច្ចយា តិស្សោ អាបត្តិយោ

---
១ ឱ. ម. កុបិតាតិ ន ទិស្សតិ ។ ២ ឱ. ម. វ អយ្យេ ។

[៨១៤] ភិក្ខុនីក្រោធខឹង ត្រូវអាបត្តិ ៣ ព្រោះបច្ច័យដែលខ្លួនមិនលះ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្ម ចប់ជាគម្រប់ ៣ ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨១៥] ភិក្ខុនីដែលសង្ឃឲ្យចាញ់ ព្រោះអធិករណ៍អ្វីនីមួយហើយក្រោធខឹង ត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាមិនលះ (អំពើនោះ ៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគម្រប់ ៣ ដងគឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨១៦] ភិក្ខុនីនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាមិនលះ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគម្រប់ ៣ ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨១៧] ភិក្ខុនីបញ្ចួនភិក្ខុនីផងគ្នា ដោយពាក្យថា នៃលោកម្ចាស់ទាំងឡាយ ចូរលោកម្ចាស់ទាំងឡាយនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ កុំនៅបែកខ្ញែកពីគ្នាឡើយ ដូច្នេះ ត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃ

អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្ល-
ច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេ-
សស្ស ។

សង្ឃាទិសេសា និដ្ឋិតា[១] ។

។ បេ ។

[៨១៨] ឆដ្ឋី វិញ្ញាបេត្វា កុញ្ជរប្បច្ចយា កតិ
អាបត្តិយោ អាបជ្ជតិ ។ ឆដ្ឋី វិញ្ញាបេត្វា កុញ្ជរប្បច្ចយា
ទ្វេ អាបត្តិយោ អាបជ្ជតិ កុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ
អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ
បាចិត្តិយស្ស ឆដ្ឋី វិញ្ញាបេត្វា កុញ្ជរប្បច្ចយា
ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។

កតិអាបត្តិវារំ និដ្ឋិតំ ទុតិយំ ។

[៨១៩] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិ-
យោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ កាយ-
សំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ចតុន្នំ វិបត្តីនំ

១ ឱ. ម. ទសសង្ឃាទិសេសា និដ្ឋិតា ។

កិរិយាមិនលះ (អំពើនោះ ៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្ម ចប់ជាគម្រប់ ៣ ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃា-ទិសេស ។

ចប់ សង្ឃាទិសេស ។

។ បេ ។

[៨១៨] ភិក្ខុនីត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ ។ ភិក្ខុនីត្រូវអាបត្តិ ២ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ គឺកំពុងទទួលដោយគិតថា អាត្មាអញនឹងឆាន់ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុនីត្រូវអាបត្តិ ២ នេះ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ ។

ចប់ កតិអាបត្តិវារៈ ជាគម្រប់ ២ ។

[៨១៩] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាវិបត្តិ

ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចា-
រវិបត្តឹ ។ បេ ។ ឥធំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិ-
យោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ ឥធំ
វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ចតុន្នំ វិបត្តីនំ
ឯកំ វិបត្តឹ ភជន្តិ អាចារវិបត្តឹ ។

វិបត្តិវារំ និដ្ឋិតំ តតិយំ ។

[៨២០] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិ-
យោ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ
សង្គហិតា ។ កាយសំសគ្គំ សាទិយនប្បច្ចយា អា-
បត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ បញ្ចហិ អាបត្តិក្ខន្ធេ-
ហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា
សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន
សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេ-
ន ។ បេ ។ ឥធំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ
សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គ-
ហិតា ។ ឥធំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ

ទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមនូវទឹកដោះជូរ យកមកឆាន់ បណ្ដាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្ដាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។

ចប់ វិបត្តិវារៈ ជាគម្រប់ ៣ ។

[៨២០] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្ដីត្រេកអរនឹងការប៉ះពាល់កាយ បណ្ដាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្ដីត្រេកអរនឹងការប៉ះពាល់កាយ បណ្ដាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្ដាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរ

សត្តន្នំ អាបត្តិក្ខន្ធានំ ទ្វីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថាដិទេសនីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។

សង្គហវារំ និដ្ឋិតំ ចតុត្ថំ ។

[៨២១] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ បេ ។ ឧជ្ជិ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ឧជ្ជិ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច

យកមកឆាន់ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។

ចប់ សង្គហវារៈ ជាគម្រប់ ៨ ។

[៨២១] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរ នឹងការប៉ះពាល់កាយ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ អាបត្តិទាំង-ឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយមិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយវាចា

សមុដ្ឋហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។

សមុដ្ឋានវារំ និដ្ឋិតំ បញ្ចមំ ។

[៨២២] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ បេ ។ ឧព្ភិ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ ឧព្ភិ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។

អធិករណវារំ និដ្ឋិតំ ឆដ្ឋំ ។

[៨២៣] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ សត្តន្នំ

មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន ។

ចប់ សមុដ្ឋានវារៈ ជាគម្រប់ ៥ ។

[៨២២] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។

ចប់ អធិករណវារៈ ជាគម្រប់ ៦ ។

[៨២៣] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តា

សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិន-យេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិន-យេន ច តិណវត្ថារកេន ច ។ បេ ។ ឧជឹ វិញ្ញាបេត្វា កុញ្ចនប្បច្ចយា អាបត្តិយោ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ ឧជឹ វិញ្ញាបេត្វា កុញ្ចនប្បច្ចយា អាបត្តិយោ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមថវារំ និដ្ឋិតំ សត្តមំ ។

[៨២៤] កាយសំសគ្គំ សាទិយនប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ កាយសំសគ្គំ សាទិយនប្បច្ច-យា បញ្ច អាបត្តិយោ អាបជ្ជតិ អវស្សុតា ភិក្ខុនី អវ-ស្សុតស្ស បុរិសបុគ្គលស្ស អធក្ខកំ ឧព្ភជានុមណ្ឌលំ គហណំ សាទិយតិ អាបត្តិ បារាជិកស្ស ភិក្ខុ កាយេន កាយំ អាមសតិ អាបត្តិ សង្ឃាទិសេសស្ស

សមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិង បដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ ពួកអាបត្តិ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

ចប់ សមថវារៈ ជាគម្រប់ ៧ ។

[៨២៤] ភិក្ខុ ឬភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃសេចក្តីត្រេកអរនិងការប៉ះពាល់កាយ ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ ៥ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនិងការប៉ះពាល់កាយ គឺភិក្ខុនីមានតម្រេកត្រេកអរនិងការចាប់ពាល់ (នូវសរីរប្រទេស) របស់បុរសបុគ្គលដែលមានតម្រេកដែរ តាំងពីខាងក្រោមដងកាំបិតចុះមក ដល់ខាងលើមណ្ឌលជង្គង់ ត្រូវអាបត្តិបារាជិក ភិក្ខុចាប់ពាល់កាយ (ស្ត្រី) ដោយកាយរបស់ (ខ្លួន) ត្រូវអាបត្តិ

កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស អង្គុលិបតោទកេ បាចិត្តិយំ កាយសំសគ្គំ សាទិយនប្បច្ចយា ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ បញ្ចហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ ចតុន្នំ អធិករណានំ

សង្ឃាទិសេស ភិក្ខុចាប់ពាល់វត្ថុដែលជាប់នឹងកាយ (ស្ត្រី) ដោយកាយរបស់ (ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុចាប់ពាល់វត្ថុដែលជាប់នឹងកាយ (ស្ត្រី) ដោយវត្ថុដែលជាប់នឹងកាយ (ខ្លួន) ត្រូវអាបត្តិទុក្កដ ភិក្ខុចាក់ក្រឡេកភិក្ខុផងគ្នា ដោយម្រាមដៃ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុឬភិក្ខុនីត្រូវអាបត្តិទាំង ៥ នេះ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនិងការប៉ះពាល់កាយ ។ ពួកអាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ អាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បណ្តាអធិករណ៍ទាំង ៤

អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។

[៨២៨] ឧជឹ វិញ្ញាបេត្វា កុញ្ជរប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ ឧជឹ វិញ្ញាបេត្វា កុញ្ជរប្បច្ចយា ទ្វេ អាបត្តិយោ អាបជ្ជតិ កុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ឧជឹ វិញ្ញាបេត្វា កុញ្ជរប្បច្ចយា ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ

ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។ បេ ។

[៨២៥] ភិក្ខុនីត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ ។ ភិក្ខុនីត្រូវអាបត្តិ ២ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ គឺកំពុងទទួលប្រគេនដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុនីត្រូវអាបត្តិទាំង ២ នេះ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ ។ អាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ រម្ងាប់

៣៤៣



កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជន្តិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ទ្វីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ចាតិ ។

សមុច្ចយវារំ និដ្ឋិតំ អដ្ឋមំ ។

អដ្ឋ បច្ចយវារា និដ្ឋិតា ។

ភិក្ខុនីវិភង្គេ សោឡស មហាវារា និដ្ឋិតា ។

ដោយសមថៈប៉ុន្មាន ។ ពួកអាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។ បណ្តាអាបត្តិទាំង ៧ កង លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា និងមិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយអំពីចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចា និងចិត្តក៏មាន ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

ចប់ សមុច្ចយវារៈជាគម្រប់ ៨ ។

ចប់ បច្ចយវារៈទាំង ៨ ។

ចប់ មហាវារៈ ១៦ ក្នុងភិក្ខុនីវិភង្គ ។

# សមុដ្ឋានសីសសង្ខេបំ

[៨២៦] អនិច្ចា សព្វសង្ខារា[១]

ទុក្ខានត្តា ច សង្ខតា

និព្វានញ្ចេវ បណ្ណត្តិ

អនត្តា ឥតិ និច្ឆយា ។

ពុទ្ធចន្ទេ អនុប្បន្នេ

ពុទ្ធាទិច្ចេ អនុគ្គតេ

តេសំ សភាគធម្មានំ

នាមមត្តំ ន ញាយតិ[២] ។

---

១ ឱ. ម. សព្វេ សង្ខារា ។ ២ ឱ. ម. ន នាយតិ ។

# សមុដ្ឋានសីសសង្ខេប

[៨២៦] *សង្ខារទាំងពួងទាំងឡាយ ដែលបច្ច័យតាក់តែង ហើយ ជារបស់មិនទៀងផង ជាទុក្ខផង ជាអនត្តាផង ។ និព្វាន និងបញ្ញត្តិ ក៏លោកវិនិច្ឆ័យថា ជាអនត្តាធម៌ដែរ*[១] *កាលព្រះពុទ្ធដូចជាព្រះចន្ទមិនទាន់កើតឡើង កាលព្រះពុទ្ធដូចជាព្រះអាទិត្យមិនទាន់បានត្រាស់នៅឡើយ នាមបញ្ញត្តិរបស់សភាគធម៌*[២] *ទាំងឡាយនោះ ក៏មិនមានអ្នកណាអាចដឹងបាន ។*

---

១ អត្តា ប្រែថា ខ្លួន ថា ចិត្ត ឬថា សភាវៈតែងប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន ។ អនត្តា ប្រែថា សភាវៈមិនមែនខ្លួន មិនមែនចិត្ត មិនប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន ។ យើងបានពិនិត្យមើលត្រង់បទដែលថា អនត្តានោះច្រើនគម្ពីរបានចូលចិត្តដោយច្បាស់លាស់ថា ធម៌ទាំងអស់គឺ អាយតនៈ ១២ ឬ ខន្ធ ៥ ប្រការសុទ្ធតែជាអនត្តាគ្រប់ចំណែក សូម្បីព្រះនិព្វានដែលជាធម៌យ៉ាងឯក ក៏គង់បានឈ្មោះថាជា អនត្តា ដែរ តែធម៌ទាំងអស់ក្រៅចាកព្រះនិព្វាននោះ នៅមានខន្ធ ៥ ជាហេតុ ជាបច្ច័យឲ្យកើតទៀត ព្រោះធម៌ទាំងនោះ ជាសសង្ខារនៅឡើយ ។ ឯព្រះនិព្វានជាអនត្តាដែរ ជាធម៌មិនមានហេតុ មិនមានបច្ច័យ ជាកម្លាំងឲ្យកើតឡើយ ។ ព្រោះព្រះនិព្វាននេះ ជាវិសង្ខារទៅហើយ ព្រះនិព្វាននោះ ពិតមែនតែជាគុណជាតិមិនត្រូវកើតទៀត តែមិនមែនជាឋានសូន្យទទេនោះទេ គឺព្រះនិព្វាននៅមានអាយតនៈមួយ ឬមានហេតុម្យ៉ាង គឺអរហត្តផលញ្ញាណនោះឯង សមដូចពុទ្ធភាសិតថា អត្ថិ ភិក្ខវេ តទាយតនំ ។ ២ សំដៅយកសង្ខតធម៌គឺមានបច្ច័យប្រជុំតាក់តែងបាន ជាធម៌មានចំណែកស្មើដោយអាការមានមិនទៀងជាដើម ។

ទុក្ករំ  វីរិជំ  កត្វា
បូរយិត្វាន  ធារមី
ឧបជ្ជន្តិ  មហាវីរា
ចក្ខុភូតា  សព្រហ្មកេ
តេ  ទេសយន្តិ  សទ្ធម្មំ
ទុក្ខហានឹ  សុខាវហំ  ។
អង្គីរសោ  សក្យមុនិ
សព្វភូតានុកម្បកោ
សព្វសត្តុត្តមោ  សីហោ
បិដកេ  តីណិ  ទេសយិ
សុត្តន្តំ  អភិជម្មញ្ច[១]
វិនយញ្ច  មហាគុណំ  ។
ឯវំ  នីយតិ  សទ្ធម្មោ
វិនយោ  យទិ  តិដ្ឋតិ
ឧភតោ  ច  វិភង្គានិ
ខន្ធកា  យា  ច  មាតិកា

១ ឱ. ម. សុត្តន្តមភិធម្មញ្ច ។

សមុដ្ឋានសីសសង្ខេប សមុដ្ឋានកថា

ព្រះសម្មាសម្ពុទ្ធទាំងឡាយ ជាមហាវីរៈ ទ្រង់ធ្វើនូវទុក្ករកិរិយាមានប្រការផ្សេង ៗ បានបំពេញនូវបារមីទាំងឡាយ ព្រះអង្គមានចក្ខុកើតហើយ បានត្រាស់ដឹងឡើង ព្រះអង្គទ្រង់សម្តែង នូវព្រះសទ្ធម្មដែលសម្រាប់បំផ្លាញ នូវកងទុក្ខហើយនាំមកនូវសេចក្តីសុខ ចំពោះសត្វលោកព្រមទាំងព្រហ្ម-លោក ។ ព្រះអង្គីរសសម្មាសម្ពុទ្ធ ជាសក្យមុនី ព្រះអង្គមានសេចក្តីអនុគ្រោះសព្វសត្វ ឧត្តមជាងសព្វសត្វ ជាសីហៈ (របស់នរជន) ទ្រង់សម្តែងនូវពុទ្ធវចនៈទាំង ៣ ក្នុងបិដកគឺព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ដែលជាពាក្យមានគុណធំ ។ បើព្រះវិន័យ ឋិតនៅហើយ ព្រះសទ្ធម្មក៏ប្រព្រឹត្តទៅបាន យ៉ាងនេះ ឧភតោវិភង្គ ខន្ធកវិន័យ និងមាតិកា ដែល

មាលា សុត្តកុណោនេវ

បរិវារេ គន្ថិតា ។

តស្សេវ បរិវារស្ស

សមុដ្ឋានំ និយតោ កតំ

សម្ភេទនិទានញ្ចញ្ញំ

សុត្តេ ទិស្សន្តិ ឧបរិ

តស្មា សិក្ខេ បរិវារំ

ធម្មកាមោ សុបេសលោតិ ។

វិភង្គេ ទ្វីសុ បញ្ញត្តំ

ឧទ្ទិសន្តិ ឧបោសថេ

បវក្ខាមិ សមុដ្ឋានំ

យថាញាយំ សុណាថ មេ ។

ចាភជិកំ យំ បឋមំ

ទុតិយញ្ច តតោ បរំ

សញ្ចរិត្តានុភាសញ្ច

អតិរេកញ្ច ចីវរំ

លោមានិ បទសោធម្មោ

សង្គីតិកាចារ្យចងក្រងហើយ ដោយបរិវារៈ បីដូចជាកម្រងផ្កា ដែលគេក្រង ដោយចេសនុ៎ះឯង ។ សមុដ្ឋាននៃបរិវារៈនុ៎ះឯង ជាសមុដ្ឋានដែលអ្នកប្រាជ្ញធ្វើឲ្យទៀងទាត់ គឺធ្វើមិនឲ្យលាយច្រឡំ ដោយសមុដ្ឋានឯទៀត សម្ភេទផង និទានផង សមុដ្ឋានដទៃផង មានប្រាកដមកក្នុងសូត្រ ដូចសម្តែងមកហើយខាងដើម ព្រោះហេតុនោះ ភិក្ខុដែលមានសីលជាទីស្រឡាញ់ ជាអ្នកប្រាថ្នាធម៌ គប្បីសិក្សានូវបរិវារៈ (ទៀតចុះ) ។ សិក្ខាបទណា ដែលទ្រង់បញ្ញត្តហើយក្នុងវិភង្គទាំងពីរ ដែលពួកភិក្ខុ និងភិក្ខុនីតែងសម្តែងគ្រប់ថ្ងៃឧបោសថ ខ្ញុំនឹងពោលនូវសមុដ្ឋាន (នៃសិក្ខាបទនោះ) តាមសមគួរដល់សេចក្តីចេះដឹង អ្នកទាំងឡាយចូរប្រុងស្តាប់ពាក្យរបស់ខ្ញុំ ។ សិក្ខាបទទាំងឡាយ ១៣ គឺបឋមបារាជិកសិក្ខាបទ ១ ទុតិយបារាជិកសិក្ខាបទ ១ តទៅមុខទៀត គឺសញ្ចរិត្តសិក្ខាបទ ១ សមនុភាសនសិក្ខាបទ ១ អតិរេកចីវរសិក្ខាបទ ១ ឯឡកលោមសិក្ខាបទ ១ បទសោធម្មសិក្ខាបទ ១

៣៤៧

សមុដ្ឋានសីសសង្ខេបំ បឋមបារាជិកសមុដ្ឋានំ

ភូតសំវិធានេន ច
ថេយ្យទេសនចោរិញ្ច
អននុញ្ញាយ តេរស ។
តេរសេតេ សមុដ្ឋាន-
នយា វិញ្ញូហិ ចិន្តិតា
ឯកេកស្មឹ សមុដ្ឋានេ
សទិសា ឥធ ទិស្សរេ
[៨២៧] មេថុនំ សុក្កសំសគ្គោ
អនិយតា បឋមិកា
បុព្វបរិចាចិតា
រហោ ភិក្ខុនិយា សហ
សភោជនេ រហោ ទ្វេ ច
អង្គុលិ ឧទកេ ហាសំ
បហារេ ឧគ្គិរេ ចេវ
តេបញ្ញាសា ច សេក្ខិយា
អធក្ខគាមាវស្សុតា[១]

១ ឱ. អធក្ខកំ គាមាវស្សុតា ។

ភូតារោចនសិក្ខាបទ ១ សំវិធានសិក្ខាបទ ១ ថេយ្យសត្ថ-សិក្ខាបទ ១ ធម្មទេសនាសិក្ខាបទ ១ ចោរីវុដ្ឋាបនសិក្ខាបទ ១ អននុញ្ញាតសិក្ខាបទ ១ ។ សិក្ខាបទទាំង ១៣ នេះ មាន ន័យរបស់សមុដ្ឋាន ដែលអ្នកប្រាជ្ញទាំងឡាយ បានគិតហើយ ថា ក្នុងសមុដ្ឋាននៃសិក្ខាបទមួយ ៗ ក្នុងវិភង្គទាំងពីរនេះ មាន សមុដ្ឋានប្រហែល ៗ គ្នាទាំងអស់ ។

[៨២៧] មេថុនសិក្ខាបទ ១ សុក្កវិស្សដ្ឋិសិក្ខាបទ ១ កាយ-សំសគ្គសិក្ខាបទ ១ បឋមានីយតសិក្ខាបទ ១ បុព្វូបគត-សិក្ខាបទ[១] ១ បរិបាចិតសិក្ខាបទ ១ រហោនិសជ្ជសិក្ខា-បទ[២] ១ សភោជនសិក្ខាបទ ១ រហោនិសជ្ជសិក្ខាបទ[៣] ទាំង ២ អង្គុលិបតោទកសិក្ខាបទ ១ ឧទកេហាសធម្មសិក្ខាបទ ១ បហារទានសិក្ខាបទ ១ ឧគ្គិរណសិក្ខាបទ[៤] ១ សេក្ខិយ ៥៣ អជក្ខសិក្ខាបទ ១ គាមន្តរគមនសិក្ខាបទ ១ អវស្សុតខាទនីយ-

---

១ គឺអនុប្បខជ្ជសិក្ខាបទ ក្នុងភូតគាមវគ្គសិក្ខាបទទី ៦ ។ ២ គឺភិក្ខុអង្គុយក្នុងទីកំបាំងជាមួយនឹងភិក្ខុនី ។ ៣ គឺបឋមរហោនិសជ្ជ ១ ទុតិយរហោនិសជ្ជ ១ (អចេលកវគ្គ សិក្ខាបទទី ៤-៥) ។ ៤ គឺតលសត្តិកសិក្ខាបទ ។

តលមដ្ឋញ្ច សុទ្ធិកា
វស្សំ វុត្ថា ច ឱរកំ
ជានុពន្ធេ បវត្តិនឹ
ឆសត្តតិ ឥមេ សិក្ខា
កាយមានសិកា កតា
សព្វេ ឯកសមុដ្ឋានា
បឋមំ បារាជិកំ យថា ។

បឋមបារាជិកសមុដ្ឋានំ និដ្ឋិតំ ។

[៨២៨] អទិន្នំ វិគ្គហុត្តរឹ[១]
ទុដ្ឋុល្លា អត្តកាមិនំ
អមូលា អញ្ញភាគិយា
អនិយតា ទុតិយិកា
អច្ឆិន្ទេ បរិណាមនេ
មុសា ឱមសបេសុណា
ទុដ្ឋុល្លា បឋវីខណោ

១ ម. វិគ្គហុត្តរិ ។

គហនសិក្ខាបទ[១] ១ តលឃាដកសិក្ខាបទ ១ ជតុមដ្ឋក-សិក្ខាបទ ១ ឧទកសុទ្ធិកសិក្ខាបទ ១ វស្សវុត្ថានសិក្ខាបទ ១ ឱវាទគមនសិក្ខាបទ ១ វុដ្ឋាបិតបវត្តននានុពន្ធសិក្ខាបទ ១ រួមត្រូវជា ៧៦ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានមួយ គឺ តាំងឡើងអំពីកាយចិត្ត ដូចបឋមបារាជិកសិក្ខាបទដែរ ។

ចប់ បឋមបារាជិកសមុដ្ឋាន ។

[៨២៨] អទិន្នាទានសិក្ខាបទ ១ មនុស្សវិគ្គហសិក្ខាបទ ១ ឧត្តរិមនុស្សធម្មសិក្ខាបទ ១ ទុដ្ឋុល្លវាចសិក្ខាបទ ១ អត្តកាមបារិចរិយសិក្ខាបទ ១ អមូលកសិក្ខាបទ ១ អញ្ញភាគិយសិក្ខាបទ ១ ទុតិយានិយតសិក្ខាបទ ១ ចីវរច្ឆិន្ទនសិក្ខាបទ ១ បរិណាមនសិក្ខាបទ ១ មុសាវាទសិក្ខាបទ ១ ឱមសវាទសិក្ខាបទ ១ បេសុញ្ញសិក្ខាបទ ១ ទុដ្ឋុល្លារោចនសិក្ខាបទ ១ បឋវីខណនសិក្ខាបទ ១

---

១ គឺខាទនីយគហណសិក្ខាបទ ។

៣៤៩

សមុដ្ឋានសីសសង្ខេបំ  ទុតិយបារាជិកសមុដ្ឋានំ

ភូតំ  អញ្ញាយ  ឧជ្ឈបេ

និក្កឌ្ឍនំ  សិញ្ចនញ្ច

អាមិសហេតុ  ភុត្តាវី

ឃហិ  អជានិ  ភឹសា

អបនិដេ  ច  ជីវិតំ

ជានំ  សប្បាណកំ  កម្មំ

ឩនសំវាសជាសជា

សហធម្មិកវិលេខា

មោហោ  អមូលកេន  ច

កុក្កុច្ចំ  ធម្មិកំ[១]  ទត្វា

បរិណាមេយ្យ  បុគ្គលេ

ភិន្ទេ  អកាលអច្ឆិន្នេ

ទុក្កហិ  និរយេន  ច

គណំ  វិភង្គំ  ទុព្វលំ

---

១ ម. កុក្កុច្ចធម្មិកំ ។

ភូតគាមសិក្ខាបទ ១ អញ្ញវាទកសិក្ខាបទ ១ ឧជ្ឈាបនកសិក្ខាបទ ១ និកឌ្ឍនសិក្ខាបទ ១ សិញ្ចនសិក្ខាបទ[១] ១ អាមិសហេតុសិក្ខាបទ ១ កុត្តាវីសិក្ខាបទ[២] ១ ឯហិសិក្ខាបទ[៣] ១ អនាទរិយសិក្ខាបទ ១ ភឹសាបនសិក្ខាបទ ១ អបនិធានសិក្ខាបទ ១ ជីវិតាវោរោបនសិក្ខាបទ[៤] ១ សប្បាណកសិក្ខាបទ ១ កម្មឧក្កោដនសិក្ខាបទ ១ ឩនវីសតិវស្សសិក្ខាបទ ១ សំវាសសិក្ខាបទ[៥] ១ នាសិតកសាមណេរសម្ភោគសិក្ខាបទ[៦] ១ សហធម្មិកសិក្ខាបទ ១ វិលេខនសិក្ខាបទ ១ មោហនកសិក្ខាបទ ១ អមូលកសិក្ខាបទ[៧] ១ កុក្កុច្ចឧបទហនសិក្ខាបទ[៨] ១ ធម្មិកសិក្ខាបទ[៩] ១ ចីវរំទត្វាខិយ្យនធម្មសិក្ខាបទ[១០] ១ បុគ្គលបរិណាមនសិក្ខាបទ ១ កិន្តេសិក្ខាបទ[១១] ១ អកាលចីវរសិក្ខាបទ (ភាជាបនៈ) ១ អច្ឆិន្នសិក្ខាបទ ១ ទុគ្គហិតសិក្ខាបទ (ឧជ្ឈាបនកៈ) ១ និរយសិក្ខាបទ (អភិសបន) ១ គណាចីវរលាភសិក្ខាបទ ១ ចីវរវិភង្គសិក្ខាបទ ១ ទុព្វលចីវរសិក្ខាបទ ១

---

១ គឺសប្បាណកសិក្ខាបទទី ១០ ក្នុងភូតគាមវគ្គ ។ ២ គឺទុតិយបវារណាសិក្ខាបទ ។ ៣ គឺឧយ្យោជនសិក្ខាបទ ។ ៤ គឺសញ្ចិច្ចបាណសិក្ខាបទ ។ ៥ គឺឧក្ខិត្តសម្ភោគសិក្ខាបទ ។ ៦ គឺកណ្ដកសិក្ខាបទ ។ ៧ គឺអមូលកសិក្ខាបទទី ៦ ក្នុងសហធម្មិកវគ្គ ។ ៨ គឺសញ្ចិច្ចសិក្ខាបទ ។ ៩ គឺកម្មប្បដិពាហនសិក្ខាបទ ។ ១០ គឺខិយ្យធម្មសិក្ខាបទ ។ ១១ មានក្នុងភិក្ខុនីវិភង្គ ។

កឋិនជាសុបស្សយំ
អក្កោសចណ្ឌី មច្ឆរី
គព្ភិនី ច បាយន្តិយា
ទ្វេ វស្សា សិក្ខា សង្ឃេន
តយោ ចេវ គិហិគតា
កុមារីភូតា តិស្សោ ច
ឩនទ្វាទសសម្មតា
អលង្ការ សោកាវស្សំ
ឆន្ទា អនុវស្សា ច ទ្វេ
សិក្ខាបទា សត្តតីមេ
សមុដ្ឋានា តិកា កតា
កាយចិត្តេន ន វាចា
វាចាចិត្តា ន កាយិកា
តីហិ ទ្វារេហិ ជាយន្តិ
បារាជិកំ ទុតិយំ យថា

ទុតិយបារាជិកសមុដ្ឋានំ និដ្ឋិតំ ។

កឋិនផាសុកសិក្ខាបទ ១ ឧបស្សយសិក្ខាបទ ១ អក្កោសនសិក្ខាបទ ១ ចណ្ឌីកតាសិក្ខាបទ ១ កុលមច្ឆរីសិក្ខាបទ ១ គព្ភិនីវុដ្ឋាបនសិក្ខាបទ ១ បាយន្តីវុដ្ឋាបនសិក្ខាបទ ១ ទ្វេវស្សាអសិក្ខិតសិក្ខមានាសិក្ខាបទ ១ សិក្ខិតសិក្ខាសង្ឃេនអសម្មតាសិក្ខាបទ ១ គិហិគតាសិក្ខាបទ[១] មាន ៣ កុមារីភូតាសិក្ខាបទ[២] មាន ៣ ឩនទ្វាទសវស្សាវុដ្ឋាបនសិក្ខាបទ ១ អសម្មតវុដ្ឋាបនសិក្ខាបទ ១ អលន្តាវសិក្ខាបទ ១ សោកាវស្សាសិក្ខាបទ ១ បារិវាសិកច្ឆន្ទទានសិក្ខាបទ ១ អនុវស្សសិក្ខាបទ ១ ឯកវស្សទ្វេវុដ្ឋាបនសិក្ខាបទ ១ រួមទាំងអស់ត្រូវជា ៧០ សិក្ខាបទ សិក្ខាបទទាំងនេះ សុទ្ធតែមានសមុដ្ឋាន ៣ ។ គឺកើតឡើងអំពីកាយចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីវាចានិងចិត្តមិនកើតឡើងអំពីកាយ ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចាចិត្ត ១ ដូចក្នុងទុតិយបារាជិកសិក្ខាបទ ។

ចប់ ទុតិយបារាជិកសមុដ្ឋាន ។

---

១ គឺឩនទ្វាទសវស្សាគិហិគតា ១ បរិបុណ្ណទ្វាទសវស្សាអសិក្ខិតសិក្ខាគិហិគតា ១ ទ្វេវស្សានិសិក្ខិតាសង្ឃេនអសម្មតាគិហិគតា ១ ។ ២ គឺចែកដូចគ្នានឹងគិហិគតាសិក្ខាបទ ។

៣៤១

## សមុដ្ឋានសីសសង្ខេបំ សញ្ចរិត្តសមុដ្ឋានំ

[៨២៩] សញ្ចរិ កុដិ វិហារោ
ធោវនញ្ច បដិគ្គហោ
វិញ្ញត្តុត្តរិ អភិហដ្ឋុំ
ឧភិន្នំ ទូតកេន ច
កោសិយា សុទ្ធទ្វេភាគា
ឆព្វស្សានិ និសីទនំ
រិញ្ចន្តិ រូបិកា ចេវ
ឧភោ នានប្បការកា
ឩនពន្ធនវស្សិកា
សុត្តំ វិកប្បនេន ច
ទ្វារទានសិព្វិនី ច
បូវបច្ចយជោតិ ច
រតនំ សូចិ មញ្ចោ ច
តូលំ និសីទនកណ្ឌុ ច

## សមុដ្ឋានសីសសង្ខេប សញ្ចរិត្តសមុដ្ឋាន

[៨២៩] សញ្ចរិត្តសិក្ខាបទ ១ កុដិការសិក្ខាបទ ១ វិហារសិក្ខាបទ (មហល្លក:) ១ ចីវរធោវនសិក្ខាបទ ១ ចីវរប្បដិគ្គហណសិក្ខាបទ ១ អញ្ញាតកវិញ្ញត្តិសិក្ខាបទ ១ តទុត្តរិអភិហដ្ឋសិក្ខាបទ[១] ១ ឧបក្ខដសិក្ខាបទ ២ (គឺបឋមឧបក្ខដ: ១ ទុតិយឧបក្ខដ: ១) ទូតសិក្ខាបទ[២] ១ កោសិយសិក្ខាបទ ១ សុទ្ធកាឡកសិក្ខាបទ ១ ទ្វេភាគសិក្ខាបទ ១ ឆព្វស្សសិក្ខាបទ ៦ និសីទនសន្ថតសិក្ខាបទ ១ រិញ្ចន្តិសិក្ខាបទ[៣] ១ រូបិយសិក្ខាបទ ១ នានប្បការកសិក្ខាបទ ២ (គឺរូបិយសំវោហារសិក្ខាបទ ១ កយវិក្កយសិក្ខាបទ ១) ឩនបញ្ចពន្ធនសិក្ខាបទ ១ វស្សិកសាដិកសិក្ខាបទ ១ សុត្តវិញ្ញត្តិសិក្ខាបទ ១ វិកប្បនសិក្ខាបទ[៤] ១ ទ្វារសិក្ខាបទ[៥] ១ ចីវរទានសិក្ខាបទ ១ ចីវរសិព្វនសិក្ខាបទ ១ បូវសិក្ខាបទ[៦] ១ បច្ចយសិក្ខាបទ[៧] ១ ជោតិសមាទហនសិក្ខាបទ ១ រតនសិក្ខាបទ ១ សុចិឃរសិក្ខាបទ ១ មញ្ចសិក្ខាបទ ១ តូលោនទ្ធសិក្ខាបទ ១ និសីទនសិក្ខាបទ ១ កណ្ឌុបដិច្ឆាទិសិក្ខាបទ ១

---

១ គួរហៅថា តទុត្តរិសិក្ខាបទប៉ុណ្ណោះ ។ ២ គឺរាជសិក្ខាបទ ។ ៣ គឺឯឡកលោមធោវាបនសិក្ខាបទ ។ ៤ គឺមហាបេសការសិក្ខាបទ ។ ៥ គឺមហាល្លកសិក្ខាបទ ទី ៩ ក្នុងភូតគាមវគ្គ ។ ៦ គឺកាណមាតាសិក្ខាបទ ។ ៧ គឺមហានាមសិក្ខាបទ ។

វស្សកា ច សុកតេន
វិញ្ញត្តិ អញ្ញចេតាបនា
ទ្វេ សង្ឃិកា មហាជនិកា
ទ្វេ បុគ្គលា លហុកា គរុ
ទ្វេ វិឃាសា សាដិកា ច
សមណចីវរេន ច
សមបញ្ញាសិមេ ធម្មា
ឆហិ ឋានេហិ ជាយរេ
កាយតោ ន វាចាចិត្តា
វាចតោ ន កាយមនា
កាយវាចា ន ចិត្តតោ[១]
កាយចិត្តា ន វាចតោ[២]
វាចាចិត្តា ន កាយេន
តីហិ ឋានេហិ[៣] ជាយរេ
ឆសមុដ្ឋានិកា ចេតេ[៤]
សញ្ចរិត្តេន សាទិសា ។

សញ្ចរិត្តសមុដ្ឋានំ និដ្ឋិតំ ។

---

១ ឱ. ម. ន ច ចិត្តា ។ ២ ន វាចិកា ។ ៣ ទ្វារេហិ ។ ៤ ឱ. ម. ឯតេ ។

វស្សិកសាដិកាសិក្ខាបទ ១ សុគតចីវរសិក្ខាបទ[១] ១ វិញ្ញត្តិ-សិក្ខាបទ ១ អញ្ញចេតាបនសិក្ខាបទ ១ សង្ឃិកចីវរសិក្ខាបទ ២ មហាជនិកសិក្ខាបទ ១ បុគ្គលបរិណាមនសិក្ខាបទ ២ លហុ-បាបុរណសិក្ខាបទ ១ គរុបាបុរណសិក្ខាបទ ១ វិឃាសាសិក្ខា-បទ ២ ឧទកសាដិកាសិក្ខាបទ ១ សមណចីវរទានសិក្ខាបទ ១ រួមទាំងអស់ត្រូវជាសិក្ខាបទ ៥០ គត់ សិក្ខាបទទាំងនេះ សុទ្ធតែមានសមុដ្ឋានប្រាំមួយ ៗ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចានិងចិត្ត ១ កើតឡើងអំពីវាចា មិនកើតឡើងអំពីកាយនិងចិត្ត ១ កើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចានិងចិត្ត ១ សិក្ខាបទទាំងនេះសុទ្ធតែមានសមុដ្ឋាន ៦ ដូចគ្នានឹងសញ្ចរិត្តសិក្ខាបទដែរ ។

ចប់ សញ្ចរិត្តសមុដ្ឋាន ។

---

១ គឺ នន្ទត្ថេរសិក្ខាបទ ។

សមុដ្ឋានសីសសង្ខេបំ សមនុភាសនសមុដ្ឋានំ

[៨៣០] ភេទានុវត្តទុព្វច
ទូសទុដ្ឋុល្លទិដ្ឋិ ច
ឆន្ទំ ឧជ្ជគ្ឃិកា ទ្វេ ច
ទ្វេ ច សទ្ទា ន ព្យាហរេ
ឆមា នីចាសនេ ឋានំ
បច្ឆតោ ឧប្បថេន ច
វជ្ជានុវត្តិ គហណា
ឱសារេ បច្ចាចិក្ខនា
កិស្មឹ សំសដ្ឋា ទ្វេ វធី
វិសិព្វេ ទុក្ខិតាយ ច
បុន សំសដ្ឋា ន វូបសមេ
អារាមញ្ច បវារណា
អន្វឌ្ឍមាសំ សហជីវិនី
ទ្វេ ចីវរំ អនុពន្ធនា
សត្តតឹស ឥមេ ធម្មា

សមុដ្ឋានសីសសង្ខេប សមនុភាសនសមុដ្ឋាន

[៨៣០] សង្ឃភេទសិក្ខាបទ ១ ភេទានុវត្តកសិក្ខាបទ ១ ទុព្វចជាតិកសិក្ខាបទ ១ កុលទូសកសិក្ខាបទ ១ ទុដ្ឋុល្លប្បដិច្ឆាទនសិក្ខាបទ ១ ទិដ្ឋិអប្បដិនិស្សជ្ជនសិក្ខាបទ ១ ឆន្ទំអទត្វាគមនសិក្ខាបទ ១ ឧជ្ឈាបនកសិក្ខាបទ ២ អប្បសន្នសិក្ខាបទ ២ នព្យាហរណសិក្ខាបទ ១ ធមាយសិក្ខាបទ ១ នីចាសនសិក្ខាបទ ១ ឋានសិក្ខាបទ ១ បច្ឆតោសិក្ខាបទ ១ ឧប្បថេនសិក្ខាបទ ១ វជ្ជប្បដិច្ឆាទនសិក្ខាបទ ១ ឧក្ខិត្តានុវត្តនសិក្ខាបទ ១ ហត្ថគ្គហណសិក្ខាបទ ១ ឱសារណសិក្ខាបទ ១ បច្ចាចិក្ខនាសិក្ខាបទ ១ កិស្មិញ្ចិអធិករណេបច្ចាគតាសិក្ខាបទ ១ សំសដ្ឋសិក្ខាបទ[១] ១ វធិសិក្ខាបទ ២ វិសិព្វនសិក្ខាបទ ១ ទុក្ខិតាសហជីវិនីសិក្ខាបទ ១ សំសដ្ឋាសិក្ខាបទ[២] មួយទៀត ១ នរូបសមនសិក្ខាបទ ១ អារាមសិក្ខាបទ ១ ឧភតោសង្ឃបវារណាសិក្ខាបទ ១ អនុវឌ្ឍមាសសិក្ខាបទ ១ សហជីវិនីសិក្ខាបទ[៣] ២ ចីវរទានសិក្ខាបទ ១ អនុពន្ធនសិក្ខាបទ ១ រួមទាំងអស់ត្រូវជា ៣៧ សិក្ខាបទ សិក្ខាបទទាំងអស់នេះ

១ គឺ ភិក្ខុនិយាសំសដ្ឋសិក្ខាបទ ។ ២ គឺ គិហិសំសដ្ឋសិក្ខាបទ ។ ៣ សហជីវិនីនានុគ្គហណសិក្ខាបទ ១ សហជីវិនីនវុបកាសនសិក្ខាបទ ១ ។

កាយវាចាយ ចិត្តតោ
សព្វេ ឯកសមុដ្ឋានា
សមនុភាសនា យថា ។

សមនុភាសនសមុដ្ឋានំ និដ្ឋិតំ ។

[៨៣១] ឧព្ភតំ កឋិនំ តីណិ
បឋមំ បត្តភេសជ្ជំ
អច្ចេកញ្ចាបិ[១] សាសង្កំ
បក្កមន្តេន វា ទុវេ
ឧបស្សយំ បរម្បរា
អននុវិត្តំ និមន្តនា
វិកប្បំ រញ្ញោ វិកាលេ
វោសាសារញ្ញកេន ច
ឧស្សយា[២] សន្និចយញ្ច
បុរេ បច្ឆា វិកាលេ ច
បញ្ចាហិកា សង្កមនី

១ ឱ. អច្ចេកំ វាបិ ។ ២ ឱ. ម. ឧស្សយា ។

សុទ្ធតែមានសមុដ្ឋានមួយ ៗ គឺកើតឡើងអំពីកាយវាចានិងចិត្ត ដូចក្នុងសមនុភាសនសិក្ខាបទដែរ(១) ។

ចប់ សមនុភាសនសមុដ្ឋាន ។

[៨៣១] ឧព្ភតកឋិនសិក្ខាបទ(២) ៣ បឋមបត្តសិក្ខាបទ ១ ភេសជ្ជសិក្ខាបទ ១ អច្ចេកចីវរសិក្ខាបទ ១ សាសង្កសិក្ខាបទ ១ បក្កមន្តសិក្ខាបទ(៣) ២ ភិក្ខុនូបស្សយសិក្ខាបទ ១ បរម្បរភោជនសិក្ខាបទ ១ អនតិរិត្តសិក្ខាបទ(៤) ១ និមន្តនសិក្ខាបទ(៥) ១ វិកប្បនសិក្ខាបទ ១ រាជសិក្ខាបទ(៦) វិកាលេគាមប្បវេសនសិក្ខាបទ ១ វោសាសសិក្ខាបទ ១ អារញ្ញិកសិក្ខាបទ ១ ឧស្សយវាទិកសិក្ខាបទ ១ បត្តសន្និចយសិក្ខាបទ ១ បុរេភត្តសិក្ខាបទ ១ បច្ឆាភត្តសិក្ខាបទ ១ វិកាលេឧបសង្កមនសិក្ខាបទ ១ បញ្ចាហិកធារណសិក្ខាបទ ១ ចីវរសង្កមនីយ-

---

១ សង្ឃាទិសេសសិក្ខាបទ ៤ គឺតាំងពីសង្ឃភេទដល់កុលទូសកៈ ឈ្មោះថា សមនុភាសនា ឬហៅថា យាវតតិយកា ។ ២ ឧព្ភតកឋិនសិក្ខាបទ ៣ នោះ គឺបឋមកឋិន ១ ទុតិយកឋិន ១ តតិយកឋិន ១ ។ ៣ បក្កមនសិក្ខាបទ ២ នោះ គឺបឋមសេនាសនៈ ១ ទុតិយសេនាសនៈ ១ ។ ៤ គឺបឋមបវារណា ។ ៥ គឺទុតិយបវារណា ។ ៦ គឺអន្តេបុរសិក្ខាបទ ។ ៧ អាវាសថសិក្ខាបទ ២ នោះ គឺអាវាសថចីវរានិស្សជ្ជនសិក្ខាបទ ១ អាវាសថចីវរបក្កមនៈ ១ ។

សមុដ្ឋានសីសសង្ខេបំ ឯឡកលោមសមុដ្ឋានំ

ទ្វេបិ(១) អាវសថេន ច
បសាខេ អាសនេ ចេវ
តឹសឯកូនកា ឥមេ
កាយវាចា ន ចិត្តតោ(២)
តីហិ ទ្វារេហិ ជាយរេ
ទ្វិសមុដ្ឋានិកា សព្វេ
កឋិនេន សហា សមា ។

កឋិនសមុដ្ឋានំ និដ្ឋិតំ ។

[៨៣២] ឯឡកលោមា ទ្វេ សេយ្យា
អាហច្ចបិណ្ឌភោជនំ
គណវិកាលេ សន្និធិ
ទន្តថោណោនចេលកា
ឧយ្យុត្តំ វសេ(៣) ឧយ្យោជិ
សុរា ឱវេន ឆ្ឆាយជា

---

១ ឱ. ម. ទ្វេ ។ ឱ. ន ច ចិត្តា ។ ៣ ឱ. សេនំ ។

សិក្ខាបទ ១ អាវសថ[១]សិក្ខាបទ ២ បសាខសិក្ខាបទ ១ អាសននិសីទនសិក្ខាបទ ១ រួមទាំងអស់ត្រូវជា ២៩ សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរ ៗ គឺកើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចានិងចិត្ត ១ ដូចកឋិនសិក្ខាបទដែរ ។

ចប់ កឋិនសមុដ្ឋាន ។

[៨៣២] ឯឡកលោមសិក្ខាបទ ១ សហសេយ្យសិក្ខាបទ[២] ២ អាហច្ចនសិក្ខាបទ[៣] ១ អាវសថបិណ្ឌភោជនសិក្ខាបទ ១ គណភោជនសិក្ខាបទ ១ វិកាលភោជនសិក្ខាបទ ១ សន្និធិការសិក្ខាបទ ១ ទន្តបោណសិក្ខាបទ ១ អចេលកសិក្ខាបទ ១ ឧយ្យុត្តសិក្ខាបទ ១ សេនាវាសសិក្ខាបទ ១ ឧយ្យោធិកសិក្ខាបទ ១ សុរាបានសិក្ខាបទ ១ ឱរេនឌ្ឍមាសនហានសិក្ខាបទ ១

---

១ អាវសថសិក្ខាបទ ២ នោះ គឺអាវាសថចីវរានិស្សជ្ជនសិក្ខាបទ ១ អាវាសថចីវរបក្កមនៈ ១ ។ ២ បឋមសហសេយ្យសិក្ខាបទ ១ ទុតិយសហសេយ្យសិក្ខាបទ ១ ។ ៣ វេហាសកុដិសិក្ខាបទ ។

ទុព្វណ្ណោ ទ្វេ ទេសនិកា
លសុណុត្តិដ្ឋេ នច្ចា
ន្ហានំ អត្ថរណំ(១) សេយ្យា
អន្តោរដ្ឋេ តថា ពហិ
អន្តោវស្សំ ចិត្តាគារំ
អាសន្ទិ សុត្តកន្តនា
វេយ្យាវច្ចំ សហត្ថា ច
អភិក្ខុកាវាសេន ច
ឆត្តំ យានញ្ច សង្ឃាណឹ
អលង្ការំ គន្ធវាសិតំ
ភិក្ខុនី សិក្ខមានា ច
សាមណេរី គិហិនិយា
អសង្កិច្ចិកា(២)អាបត្តិ

---

១ ឱ. ម. ន្ហានមត្ថរណំ ។ ២ ម. អសង្កច្ចិកា ។

ទុព្វណ្ណករណសិក្ខាបទ ១ បាដិទេសនីយសិក្ខាបទ ២ លសុណសិក្ខាបទ ១ ឧតិដ្ឋសិក្ខាបទ ១ នច្ចនសិក្ខាបទ ១ ។ នហានសិក្ខាបទ ១ អត្ថរណតុវដ្តសិក្ខាបទ ១ ឯកសេយ្យតុវដ្តសិក្ខាបទ ១ អន្តោរដ្ឋេសាសង្កសិក្ខាបទ ១ ពហិរដ្ឋេសាសង្កសិក្ខាបទ ១ អន្តោវស្សសិក្ខាបទ ១ ចិត្តាគារសិក្ខាបទ ១ អាសន្ទិបរិភុញ្ជនសិក្ខាបទ ១ សុត្តកន្តនសិក្ខាបទ ១ គិហិវេយ្យាវច្ចករណសិក្ខាបទ ១ សហត្ថាទានសិក្ខាបទ ១ អភិក្ខុកាវាសសិក្ខាបទ ១ ឆត្តធារណសិក្ខាបទ ១ យានសិក្ខាបទ ១ សង្ឃាណិធារណសិក្ខាបទ ១ អលង្ការធារណសិក្ខាបទ ១ គន្ធនហានសិក្ខាបទ ១ វាសិតនហានសិក្ខាបទ ១ ភិក្ខុនីឧម្មទ្ទាបនសិក្ខាបទ ១ សិក្ខមានាឧម្មទ្ទាបនសិក្ខាបទ ១ សាមណេរីឧម្មទ្ទាបនសិក្ខាបទ ១ គិហិនីឧម្មទ្ទាបនសិក្ខាបទ ១ អសង្កច្ចិកាបត្តិសិក្ខាបទ ១

សមុដ្ឋានសីសសង្ខេបំ បទសោធម្មសមុដ្ឋានំ

ចត្តារីសា ចតុត្តរិ
កាយេន ន វាចាចិត្តេន
កាយចិត្តេន ន វាចតោ
ទ្វិសមុដ្ឋានិកា សព្វេ
សមា ឯឡកលោមកា ។

ឯឡកលោមសមុដ្ឋានំ និដ្ឋិតំ ។

[៨៣៣] បទញ្ញត្រ អសម្មតា
តថា អត្ថង្គតេន ច
តិរច្ឆានវិជ្ជា ទ្វេ វុត្តា
អនោកាសេ ច បុច្ឆនា
សត្តសិក្ខាបទា ឯតេ
វាចា ន កាយចិត្តតោ[១]
វាចាចិត្តេន ជាយន្តិ
ន តុ កាយេន ជាយរេ
ទ្វិសមុដ្ឋានិកា សព្វេ
បទសោធម្មសាទិសា ។

បទសោធម្មសមុដ្ឋានំ និដ្ឋិតំ ។

---

១ ម. វាចា ន កាយចិត្តកា ។

រួមទាំងអស់ត្រូវជា ៤៤ សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរ ៗ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចានិងចិត្ត ១ កើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ ដូចឯឡូកលោមសិក្ខាបទដែរ ។

ចប់ ឯឡូកលោមសមុដ្ឋាន ។

[៨៣៣] បទសោធម្មសិក្ខាបទ ១ ធម្មទេសនាសិក្ខាបទ ១ អសម្មតោភិក្ខុនោវាទសិក្ខាបទ ១ អត្ថង្គតសិក្ខាបទ ១ តិរច្ឆានវិជ្ជាសិក្ខាបទ ២[១] អនោកាសបុច្ឆនសិក្ខាបទ ១ រួមទាំងអស់ត្រូវជា ៧ សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរ ៗ គឺកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយនិងចិត្ត ១ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ ១ ដូចបទសោធម្មសិក្ខាបទដែរ ។

ចប់ បទសោធម្មសមុដ្ឋាន ។

---

១ តិរច្ឆានវិជ្ជា ២ នោះ គឺតិរច្ឆានវិជ្ជាបរិយាបុនសិក្ខាបទ ១ តិរច្ឆានវិជ្ជាវាចនសិក្ខាប ១ ។

[៨៣៤] អដ្ឋានជាវំ បណីតំ
មាតុគ្គាមេន សង្ឃរេ[១]
ធញ្ញំ និមន្តិតា ចេវ
អដ្ឋ ច ចាដិទេសនី
សិក្ខា បណ្ណរសា ឯតេ
កាយា ន វាចា ន មនា
កាយវាចាយ ជាយន្តិ
ន តេ ចិត្តេន ជាយរេ
កាយចិត្តេន ជាយន្តិ
ន តេ ជាយន្តិ វាចតោ
កាយវាចាយ[២] ចិត្តេន
សមុដ្ឋានា ចតុព្វិធា
បញ្ញត្តា ពុទ្ធញាណេន
អដ្ឋានេន សមា នយា[៣]

អទ្ធានសមុដ្ឋានំ និដ្ឋិតំ ។

---

១ ម. សង្ខរេ ។ ២ ម. កាយវាចាហិ ។ ៣ ឱ. សហា សមា ។ ម. សហ សមា ។

[៨៣៤] អទ្ធានគមនសិក្ខាបទ[១] ១ នាវាភិរូហនសិក្ខាបទ ១ បណីតភោជនសិក្ខាបទ ១ មាតុគ្គាមសំវិធានសិក្ខាបទ ១ លោមសំហរណសិក្ខាបទ ១ ធញ្ញវិញ្ញាបនសិក្ខាបទ ១ និមន្តនសិក្ខាបទ ១ បាដិទេសនីយសិក្ខាបទ ៨ រួមទាំងអស់ត្រូវជា ១៥ សិក្ខាបទ សិក្ខាបទទាំងអស់នេះ ព្រះពុទ្ធទ្រង់ញាណបានបញ្ញត្តហើយដោយសមុដ្ឋានបួន ។ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា ទាំងមិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីកាយវាចានិងចិត្ត ១ មានទំនងដូចអទ្ធានគមនសិក្ខាបទដែរ ។

ចប់ អទ្ធានសមុដ្ឋាន ។

---

១ គឺសំវិធានសិក្ខាបទ ។

សមុដ្ឋានសីសសង្ខេបំ ថេយ្យសត្ថសមុដ្ឋានំ ធម្មទេសនាសមុដ្ឋានំ

[៨៣៥] ថេយ្យសត្ថំ ឧបស្សុតំ
សូបវិញ្ញាបនេន ច
រត្តិ ឆន្នញ្ច ឱកាសំ
ឯតេ ព្យ្ហោន សត្តមា
កាយចិត្តេន ជាយន្តិ
ន តេ ជាយន្តិ វាចតោ
តីហិ ទ្វារេហិ ជាយន្តិ
ទ្វិសមុដ្ឋានិកា ឥមេ
ថេយ្យសត្ថសមុដ្ឋានា
ទេសិតាទិច្ចពន្ធុនា ។

ថេយ្យសត្ថសមុដ្ឋានំ និដ្ឋិតំ ។

[៨៣៦] ឆត្តបាណិស្ស សទ្ធម្មំ
ន ទេសេន្តិ តថាគតា
តថេវ[១] ទណ្ឌបាណិស្ស
សត្ថអាវុធបាណិនំ
បាទុកុបាហនា យានំ
សេយ្យា បល្លត្ថិកាយ ច

---
១ ឱ. ម. ឯវមេវ ។

សមុដ្ឋានសីសសង្ខេប ថេយ្យសត្ថសមុដ្ឋាន និងធម្មទេសនាសមុដ្ឋាន

[៨៣៥] ថេយ្យសត្ថសិក្ខាបទ ១ ឧបស្សុតិសិក្ខាបទ ១ សូបវិញ្ញាបនសិក្ខាបទ ១ រត្តន្ធការសិក្ខាបទ ១ បដិច្ឆន្នសិក្ខាបទ ១ អជ្ឈោកាសសិក្ខាបទ ១ ព្យូហសិក្ខាបទ ១ សិក្ខាបទទាំងអស់នេះ រួមគ្នាត្រូវជា ៧ សិក្ខាបទទាំងនោះ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់សម្តែងហើយថា មានសមុដ្ឋានពីរ ៗ គឺកើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចាចិត្ត ១ ដូចសមុដ្ឋានរបស់ថេយ្យសត្ថសិក្ខាបទដែរ ។

ចប់ ថេយ្យសត្ថសមុដ្ឋាន ។

[៨៣៦] ព្រះតថាគតទាំងឡាយ មិនសម្តែងនូវព្រះសទ្ធម្មដល់បុគ្គល (មិនមានជម្ងឺ) មានឆត្រក្នុងដៃ ១ មានឈើច្រត់ក្នុងដៃ ១ មានសស្ត្រាក្នុងដៃ ១ មានអាវុធក្នុងដៃ ១ ពាក់ទ្រនាប់ជើងឈើឬស្មៅ ១ ពាក់ទ្រនាប់ជើងស្បែក ១ នៅលើយាន ១ នៅលើដំណេក ១ អង្គុយត្របោមក្បាលជង្គង់ ១

វេបិតោកុណ្ឌិតោ ចេវ
ឯកាទសសមុដ្ឋានា
វាចាចិត្តេន ជាយន្តិ
ន តេ ជាយន្តិ កាយតោ
សព្វេ ឯកសមុដ្ឋានា
សមកា ធម្មទេសនា(១) ។

ធម្មទេសនាសមុដ្ឋានំ និដ្ឋិតំ ។

[៨៣៧] ភូតំ កាយេន ជាយតិ
ន វាចាយ ន ចិត្តតោ
វាចតោ ច សមុដ្ឋាតិ
ន កាយា ន ច ចិត្តតោ
កាយវាចាយ ជាយតិ
ន ច(២) ជាយតិ ចិត្តតោ
ភូតារោចនកាដ្ឋាម
តីហិ ឋានេហិ ជាយតិ ។

ភូតារោចនសមុដ្ឋានំ និដ្ឋិតំ ។

១ ឱ. ម. ធម្មទេសនេ ។ ឱ. ម. តុ ។

ជួតឈ្នួតក្បាល ១ ទទូរក្បាល ១ (រឿងទាំងនេះរួមគ្នាជា) សិក្ខាបទ ១១ គត់ សិក្ខាបទទាំងអស់នោះ សុទ្ធតែមានសមុដ្ឋានមួយ ៗ គឺកើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយទេ ដូចធម្មទេសនាសិក្ខាបទដែរ ។

ចប់ ធម្មទេសនាសមុដ្ឋាន ។

[៨៣៧] ភូតសិក្ខាបទ ឈ្មោះថា ភូតារោចនសិក្ខាបទ កើតឡើងអំពីសមុដ្ឋាន ៣ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ ទាំងមិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ ។

ចប់ ភូតារោចនសមុដ្ឋាន ។

សមុដ្ឋានសីសសង្ខេបំ ចោរីវុដ្ឋាបនសមុដ្ឋានំ អននុញ្ញាតសមុដ្ឋានំ

[៨៣៨] ចោរី វាចាយ ចិត្តេន
ន តំ ជាយតិ កាយតោ
ជាយតិ តីហិ ទ្វារេហិ
ចោរីវុដ្ឋាបនំ ឥទំ
អកតំ ទ្វិសមុដ្ឋានំ
ធម្មរាជេន ឋបិតំ[១] ។

ចោរីវុដ្ឋាបនសមុដ្ឋានំ និដ្ឋិតំ ។

[៨៣៩] អននុញ្ញាតំ វាចាយ
ន កាយា ន ច ចិត្តតោ
ជាយតិ កាយវាចាយ
ន តំ ជាយតិ ចិត្តតោ
ជាយតិ វាចាចិត្តេន
ន តំ ជាយតិ កាយតោ
ជាយតិ តីហិ ឋានេហិ[២]
អកតំ ចតុដ្ឋានិកំ ។

អននុញ្ញាតសមុដ្ឋានំ និដ្ឋិតំ ។

---

១ ឱ. ម. ភាសិតំ ។ ២ ឱ. ម. ទ្វារេហិ ។

សមុដ្ឋានសីសសង្ខេប ចោរីវុដ្ឋាបនសមុដ្ឋាននិងអននុញ្ញាតសមុដ្ឋាន

[៣៨៨] ចោរីវុដ្ឋាបនសិក្ខាបទ កើតឡើងអំពីវាចានិងចិត្ត សិក្ខាបទនោះ មិនកើតឡើងអំពីកាយ ១ (ម្យ៉ាងទៀត) ចោរីវុដ្ឋាបនសិក្ខាបទកើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចានិងចិត្ត ១ សិក្ខាបទនេះ ព្រះសម្មាសម្ពុទ្ធ ជាធម្មរាជទ្រង់សម្តែងហើយថា មានសមុដ្ឋានពីរនិងជាអកិរិយា (ត្រូវអាបត្តិព្រោះមិនធ្វើ គឺមិនបានប្រាប់គេជាមុនហើយបំបួស) ។

ចប់ ចោរីវុដ្ឋាបនសមុដ្ឋាន ។

[៨៣៩] អននុញ្ញាតសិក្ខាបទមានសមុដ្ឋាន ៤ ជាអកិរិយា គឺកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ ទាំងមិនកើតឡើងអំពីចិត្ត ១ សិក្ខាបទនោះ កើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ សិក្ខាបទនោះ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ ១ កើតឡើងអំពីសមុដ្ឋានទាំង ៣ គឺកាយវាចានិងចិត្ត ១ ។

ចប់ អននុញ្ញាតសមុដ្ឋាន ។

[៨៤០] សមុដ្ឋានំ ហិ សង្ខេបំ
ឧស តីណិ សុទេសិតំ
អសម្មោហាករណដ្ឋានំ[១]
នេត្តិធម្មានុលោមិកំ
ធារយន្តោ ឥមំ វិញ្ញូ
សមុដ្ឋានេ ន មុយ្ហតីតិ ។

សមុដ្ឋានសីសសង្ខេបំ និដ្ឋិតំ ។

---

១ ឱ. អសម្មោហករណំ ឋានំ ។ ម. អសម្មោហករំ ឋានំ ។

[៨៤០] សេចក្តីថា សមុដ្ឋានសង្ខេបទាំង ១៣ (នេះ) ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងប្រពៃហើយ ដើម្បីធ្វើមិនឲ្យភាន់ច្រឡំ សមគួរដល់វិន័យនិងបាលីនិងធម៌ បណ្ឌិតអ្នកទ្រទ្រង់វិន័យនេះ កុំភាន់ច្រឡំក្នុងសមុដ្ឋានឡើយ ។

ចប់ សមុដ្ឋានសីសសង្ខេប ។

# កតិបុច្ឆាវារំ

[៨៤១] កតិ អាបត្តិយោ ។ កតិ អាបត្តិក្ខន្ធា ។ កតិ វិនីតវត្ថូនិ ។ កតិ អគារវា ។ កតិ គារវា ។ កតិ វិនីតវត្ថូនិ ។ កតិ វិបត្តិយោ ។ កតិ អាបត្តិសមុដ្ឋានា ។ កតិ វិវាទមូលានិ ។ កតិ អនុវាទមូលានិ ។ កតិ សារាណីយា ធម្មា ។ កតិ ភេទករវត្ថូនិ ។ កតិ អធិករណានិ ។ កតិ សមថា ។

[៨៤២] បញ្ច អាបត្តិយោ ។ បញ្ច អាបត្តិក្ខន្ធា ។ បញ្ច វិនីតវត្ថូនិ ។ សត្ត អាបត្តិយោ ។ សត្ត អាបត្តិក្ខន្ធា ។ សត្ត វិនីតវត្ថូនិ ។ ឆ អគារវា ។ ឆ គារវា ។ ឆ វិនីតវត្ថូនិ ។ ចតស្សោ វិបត្តិយោ ។ ឆ អាបត្តិសមុដ្ឋានា ។ ឆ វិវាទមូលានិ ។ ឆ អនុវាទមូលានិ ។

# កតិបុច្ឆាវារៈ

[៨៤១] សួរថា អាបត្តិ មានប៉ុន្មាន ។ កងនៃអាបត្តិ មានប៉ុន្មាន ។ វិនីតវត្ថុ មានប៉ុន្មាន ។ សេចក្តីមិនគោរព មានប៉ុន្មាន ។ សេចក្តីគោរព មានប៉ុន្មាន ។ វិនីតវត្ថុ មានប៉ុន្មាន ។ វិបត្តិមានប៉ុន្មាន ។ សមុដ្ឋាននៃអាបត្តិ មានប៉ុន្មាន ។ មូលនៃវិវាទ មានប៉ុន្មាន ។ មូលនៃអនុវាទ មានប៉ុន្មាន ។ សារាណីយធម៌ មានប៉ុន្មាន ។ ភេទករវត្ថុ (រឿងដែលធ្វើឲ្យបែកគ្នា) មានប៉ុន្មាន ។ អធិករណ៍ មានប៉ុន្មាន ។ សមថៈ មានប៉ុន្មាន ។

[៨៤២] ឆ្លើយថា អាបត្តិមាន ៥ ។ កងនៃអាបត្តិមាន ៥ ។ វិនីវត្ថុមាន ៥ ។ អាបត្តិមាន ៧ ។ កងនៃអាបត្តិមាន ៧ ។ វិនីតវត្ថុមាន ៧ ។ សេចក្តីមិនគោរពមាន ៦ ។ សេចក្តីគោរពមាន ៦ ។ វិនីតវត្ថុមាន ៦ ។ វិបត្តិមាន ៤ ។ សមុដ្ឋាននៃអាបត្តិមាន ៦ ។ មូលនៃវិវាទមាន ៦ ។ មូលនៃអនុវាទ

ឆ សារាណីយា ធម្មា ។ អដ្ឋារស ភេទករវត្ថូនិ ។ ចត្តារិ អធិករណានិ ។ សត្ត សមថា ។

[៨៤៣] តត្ថ កតមា បញ្ច អាបត្តិយោ ។ បារាជិកាបត្តិ សង្ឃាទិសេសាបត្តិ បាចិត្តិយាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ ។ ឥមា បញ្ច អាបត្តិយោ ។

[៨៤៤] តត្ថ កតមេ បញ្ច អាបត្តិក្ខន្ធា ។ បារាជិកាបត្តិក្ខន្ធោ សង្ឃាទិសេសាបត្តិក្ខន្ធោ បាចិត្តិយាបត្តិក្ខន្ធោ បាដិទេសនីយាបត្តិក្ខន្ធោ ទុក្កដាបត្តិក្ខន្ធោ ។ ឥមេ បញ្ច អាបត្តិក្ខន្ធា ។

[៨៤៥] តត្ថ កតមានិ បញ្ច វិនីតវត្ថូនិ ។ បញ្ចហិ អាបត្តិក្ខន្ធេហិ អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ។ ឥមានិ បញ្ច វិនីតវត្ថូនិ ។

មាន ៦ ។ សារាណីយធម៌មាន ៦ ។ ភេទករវត្ថុមាន ១៨ ។ អធិករណ៍មាន ៤ ។ សមថៈមាន ៧ ។

[៨៤៣] អាបត្តិ ៥ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (អាបត្តិ៥) គឺអាបត្តិបារាជិក ១ អាបត្តិសង្ឃាទិសេស ១ អាបត្តិបាចិត្តិយៈ ១ អាបត្តិបាដិទេសនីយៈ ១ អាបត្តិទុក្កដ ១ ។ នេះ ជាអាបត្តិ ៥ ។

[៨៤៤] កងនៃអាបត្តិទាំង ៥ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (កងនៃអាបត្តិ ៥) គឺកងនៃអាបត្តិបារាជិក ១ កងនៃអាបត្តិសង្ឃា-ទិសេស ១ កងនៃអាបត្តិបាចិត្តិយៈ ១ កងនៃអាបត្តិបាដិទេសនីយៈ ១ កងនៃអាបត្តិទុក្កដ ១ ។ នេះ ជាកងនៃអាបត្តិ ៥ ។

[៨៤៥] វិនីតវត្ថុមាន ៥ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (វិនីតវត្ថុ ៥) គឺកិរិយាវៀរឲ្យឆ្ងាយ វៀរឲ្យស្រឡះ វៀរចំពោះ ចៀសវាងចាកកងនៃអាបត្តិទាំង ៥ គឺថា កិរិយាមិនធ្វើ មិនបង្កើត (នូវកងអាបត្តិ) មិនឲ្យត្រូវអាបត្តិ មិនកន្លងនូវដែន (នៃអាបត្តិ) សម្រាប់បង់នូវកងនៃអាបត្តិ ។ នេះ ជាវិនីតវត្ថុ ៥ ។

[៨៤៦] តត្ថ កតមា សត្ត អាបត្តិយោ ។ បារា-ជិកាបត្តិ សង្ឃាទិសេសាបត្តិ ថុល្លច្ចយាបត្តិ បាចិត្តិ-យាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ ទុព្ភាសិតា-បត្តិ ។ ឥមា សត្ត អាបត្តិយោ ។

[៨៤៧] តត្ថ កតមេ សត្ត អាបត្តិក្ខន្ធា ។ បារា-ជិកាបត្តិក្ខន្ធោ សង្ឃាទិសេសាបត្តិក្ខន្ធោ ថុល្លច្ច-យាបត្តិក្ខន្ធោ បាចិត្តិយាបត្តិក្ខន្ធោ បាដិទេសនីយា-បត្តិក្ខន្ធោ ទុក្កដាបត្តិក្ខន្ធោ ទុព្ភាសិតាបត្តិក្ខន្ធោ ។ ឥមេ សត្ត អាបត្តិក្ខន្ធា ។

[៨៤៨] តត្ថ កតមានិ សត្ត វិនីតវត្ថូនិ ។ សត្តហិ អាបត្តិក្ខន្ធេហិ អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃា-តោ ។ ឥមានិ សត្ត វិនីតវត្ថូនិ ។

កតិបុច្ឆាវារៈ អាបត្តិ ៧ វិនីតវត្ថុ ៨

[៨៤៦] អាបត្តិ ៧ ក្នុងមាតិកាទាំងនោះ ដូចម្ដេចខ្លះ ។ អាបត្តិ ៧ គឺអាបត្តិបារាជិក ១ អាបត្តិសង្ឃាទិសេស ១ អាបត្តិថុល្លច្ច័យ ១ អាបត្តិបាចិត្តិយៈ ១ អាបត្តិបាដិទេសនីយៈ ១ អាបត្តិទុក្កដ ១ អាបត្តិទុព្ភាសិត ១ ។ នេះ ជាអាបត្តិ ៧ ។

[៨៤៧] កងនៃអាបត្តិ ៧ ក្នុងមាតិកាទាំងនោះ ដូចម្ដេចខ្លះ ។ (កងនៃអាបត្តិ ៧) គឺកងនៃអាបត្តិបារាជិក ១ កងនៃអាបត្តិសង្ឃាទិ-សេស ១ កងនៃអាបត្តិថុល្លច្ច័យ ១ កងនៃអាបត្តិបាចិត្តិយៈ ១ កងនៃអាបត្តិបាដិទេសនីយៈ ១ កងនៃអាបត្តិទុក្កដ ១ កងនៃអាបត្តិទុព្ភាសិត ១ ។ នេះ ជាកងនៃអាបត្តិ ៧ ។

[៨៤៨] វិនីតវត្ថុ មាន ៧ ក្នុងមាតិកាទាំងនោះ ដូចម្ដេចខ្លះ ។ (វិនីតវត្ថុមាន ៧) គឺកិរិយាវៀរឲ្យឆ្ងាយ វៀរឲ្យស្រឡះ វៀរចំពោះ ចៀសវាងចាកកងនៃអាបត្តិទាំង ៧ គឺជាកិរិយាមិនធ្វើ មិនបង្កើត (នូវកងនៃអាបត្តិ) មិនឲ្យត្រូវអាបត្តិ មិនកន្លងនូវដែន (នៃអាបត្តិ) សម្រាប់បង់នូវកងនៃអាបត្តិ ។ នេះ ជាវិនីតវត្ថុ ៧ ។

[៨៤៩] តត្ថ កតមេ ឆ អគារវា ។ ពុទ្ធេ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ អប្បមាទេ អគារវោ បដិសន្ថារេ អគារវោ ។ ឥមេ ឆ អគារវា ។

[៨៥០] តត្ថ កតមេ ឆ គារវា ។ ពុទ្ធេ គារវោ ធម្មេ គារវោ សង្ឃេ គារវោ សិក្ខាយ គារវោ អប្បមាទេ គារវោ បដិសន្ថារេ គារវោ ។ ឥមេ ឆ គារវា ។

[៨៥១] តត្ថ កតមានិ ឆ វិនីតវត្ថូនិ ។ ឆហិ អគារវេហិ អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ។ ឥមានិ ឆ វិនីតវត្ថូនិ ។

[៨៤៩] សេចក្តីមិនគោរព ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (សេចក្តីមិនគោរព ៦) គឺ ការមិនគោរពព្រះពុទ្ធ ១ មិនគោរពព្រះធម៌ ១ មិនគោរពព្រះសង្ឃ ១ មិនគោរពសិក្ខា ១ មិនគោរពសេចក្តីមិនប្រមាទ ១ មិនគោរពការបដិសន្ថារៈ ១ ។ នេះ ជាសេចក្តីមិនគោរព ៦ ។

[៨៥០] សេចក្តីគោរព ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (សេចក្តីគោរព ៦) គឺការគោរពព្រះពុទ្ធ ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសេចក្តីមិនប្រមាទ ១ គោរពក្នុងការបដិសន្ថារៈ ១ ។ នេះ ជាសេចក្តីគោរព ៦ យ៉ាង ។

[៨៥១] វិនីតវត្ថុ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (វិនីតវត្ថុ ៦) គឺកិរិយាវៀរឲ្យឆ្ងាយ វៀរឲ្យស្រឡះ វៀរចំពោះ ចៀសវាងចាកសេចក្តីមិនគោរពទាំង ៦ គឺថា កិរិយាមិនធ្វើ មិនបង្កើត (នូវសេចក្តីមិនគោរព) មិនឲ្យត្រូវ មិនកន្លងដែន (នៃសេចក្តីមិនគោរព) សម្រាប់បង់នូវអគារវៈ ។ នេះ ជាវិនីតវត្ថុ ៦ ។

៣៦៧

កតិបុច្ឆាវារំ ចតស្សោ វិបត្តិយោ ឆ អាបត្តិសមុដ្ឋានា

[៨៤២] តត្ថ កតមោ ចតស្សោ វិបត្តិយោ ។ សីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ អាជីវវិបត្តិ ។ ឥមា ចតស្សោ វិបត្តិយោ ។

[៨៤៣] តត្ថ កតមេ ឆ អាបត្តិសមុដ្ឋានា ។ អត្ថាបត្តិ កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ អត្ថាបត្តិ វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ អត្ថាបត្តិ កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ អត្ថាបត្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ អត្ថាបត្តិ វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ អត្ថាបត្តិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ ឥមេ ឆ អាបត្តិសមុដ្ឋានា ។

[៨៤៤] តត្ថ កតមានិ ឆ វិវាទមូលានិ ។ ឥធ ភិក្ខុ កោធនោ ហោតិ ឧបនាហី យោ សោ ភិក្ខុ កោធនោ ហោតិ ឧបនាហី សោ សត្ថរិបិ អគារវោ វិហរតិ អប្បដិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បដិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បដិស្សោ សិក្ខាយបិ ន បរិបូរិការី ហោតិ ។ យោ សោ ភិក្ខុ

កតិបុច្ឆាវារៈ វិបត្តិ ៤ សមុដ្ឋាននៃអាបត្តិ ៦

[៨៥២] វិបត្តិ ៤ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ វិបត្តិ ៤ គឺ សីលវិបត្តិ ១ អាចារវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ អាជីវវិបត្តិ ១ ។ នេះ ជាវិបត្តិ ៤ ។

[៨៥៣] សមុដ្ឋាននៃអាបត្តិ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (សមុដ្ឋាននៃអាបត្តិ ៦) គឺអាបត្តិកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើងអំពីកាយផង អំពីវាចាផង មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើងអំពីកាយផង អំពីចិត្តផង មិនកើតឡើងអំពីវាចា ១ អាបត្តិកើតឡើងអំពីវាចាផង អំពីចិត្តផង មិនកើតឡើងអំពីកាយ ១ អាបត្តិកើតឡើងអំពីកាយផង អំពីវាចាផង អំពីចិត្តផង ១ ។ នេះ ជាសមុដ្ឋាននៃអាបត្តិទាំង ៦ ។

[៨៥៤] មូលនៃវិវាទ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (មូលនៃវិវាទទាំង ៦) គឺភិក្ខុក្នុងសាសនានេះ ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុណា ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុនោះឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោនក្នុងព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ។ ភិក្ខុណា

សត្ថរិបិ អគារវោ វិហរតិ អប្បដិស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ ។ បេ ។ សិក្ខាយបិ ន បរិបូរការី ហោតិ សោ សង្ឃេ វិវាទំ ជនេតិ ។ យោ សោ ហោតិ វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជ-នស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ស-មនុបស្សេយ្យាថ តត្ថ តុម្ហេ តស្សេវ បាបកស្ស វិវាទ-មូលស្ស បហានាយ វាយមេយ្យាថ ឯវរូបញ្ចេ តុម្ហេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេ-យ្យាថ តត្រ តុម្ហេ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស

មិនគោរព មិនឱនលំទោនក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ក្នុងព្រះសង្ឃផង ។ បេ ។ មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះ ឈ្មោះថា ជាអ្នកញ៉ាំងវិវាទឲ្យកើតឡើងក្នុងសង្ឃ ។ វិវាទណា ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីសេចក្តីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ បើអ្នកទាំងឡាយ ពិ-ចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមលះបង់ នូវមូលនៃវិវាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួន និងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួន ឬក្នុងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយ មិនបានពិចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តានបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីកុំឲ្យមូលនៃវិវាទដ៏លាមកនោះឯងប្រព្រឹត្តទៅក្នុងអនាគតទៀតបាន ក្នុងសន្តាននៃខ្លួន និងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះ ។ ការលះបង់នូវមូលនៃវិវាទដ៏លាមកនោះ រមែងមានដោយប្រការយ៉ាងនេះ ការ

ចាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ ហោតិ ។ ឥធ ចបរំ ភិក្ខុ មក្ខី ហោតិ បឡាសី ។ បេ ។ ឥស្សុកី ហោតិ មច្ឆរី សឋោ ហោតិ មាយាវី ចាបិច្ឆោ ហោតិ មិច្ឆាទិដ្ឋិ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី យោ សោ ភិក្ខុ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី សោ សត្ថរិបិ អគារវោ វិហរតិ អប្បដិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បដិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បដិស្សោ សិក្ខាយបិ ន បរិបូរិការី ហោតិ ។ យោ សោ ភិក្ខុ សត្ថរិបិ អគារវោ វិហរតិ អប្បដិ-ស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ ។ បេ ។ សិក្ខាយបិ ន បរិបូរិការី ហោតិ សោ សង្ឃេ វិវាទំ ជនេតិ ។ យោ សោ ហោតិ វិវាទោ ពហុជនាហិតាយ ពហុ-ជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ

ដែលមិនឲ្យមូលនៃវិវាទដ៏លាមកនោះ ប្រព្រឹត្តទៅក្នុងអនាគតទៀត រមែងមានដោយប្រការយ៉ាងនេះ ។ ពាក្យខាងមុខនៅមានទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកលើកខ្លួន (ប្រណាំងវាសនា) ។ បេ ។ ជាអ្នកប្រ-ណែន ជាអ្នកកំណាញ់ ជាអ្នកអួតអាង លាក់ពុត ជាអ្នកមានសេចក្តីប្រាថ្នាលាមក មានទិដ្ឋិអាក្រក់ ជាអ្នកប្រកាន់តាមសេចក្តីយល់របស់ខ្លួនទាំងប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុណា ជាអ្នកប្រកាន់តាមសេច-ក្តីយល់របស់ខ្លួន ទាំងប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុនោះឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោនក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោន ក្នុងព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ។ ភិក្ខុណា មិនគោរព មិនឱនលំទោនក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ក្នុងព្រះសង្ឃផង ។ បេ ។ មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញុំាងវិវាទឲ្យកើតឡើងក្នុងសង្ឃ ។ វិវាទណា ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីសេចក្តីមិនចំរើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំង-ឡាយ ។ បើអ្នកទាំងឡាយ ពិចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ

តុម្ហេ តស្សេវ បាបកស្ស វិវាទមូលស្ស បហាណាយ វាយមេយ្យាថ ឯវរូបញ្ចេ តុម្ហេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្ស-វាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។ ឥមានិ ឆ វិវាទមូលានិ ។

[៨៤៤] តត្ថ កតមានិ ឆ អនុវាទមូលានិ ។ ឥធ ភិក្ខុ កោធនោ ហោតិ ឧបណាហី យោ សោ ភិក្ខុ កោធនោ ហោតិ ឧបណាហី សោ សត្ថរិបិ អគា-រវោ វិហរតិ អប្បដិស្សោ ធម្មេបិ អគារវោ វិហរតិ អប្ប-ដិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បដិស្សោ សិក្ខា-យបិ ន បរិបូរការី ហោតិ ។ យោ សោ ភិក្ខុ សត្ថរិបិ

ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមលះបង់នូវមូលនៃវិវាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយមិនបានពិចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬ ក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីកុំឲ្យមូលនៃវិវាទដ៏លាមកនោះឯងប្រព្រឹត្តតទៅក្នុងអនាគតទៀតបាន ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះ ។ ការលះបង់នូវមូលនៃវិវាទដ៏លាមកនុ៎ះ រមែងមានដោយប្រការយ៉ាងនេះ ការដែលមិនឲ្យមូលនៃវិវាទដ៏លាមកនុ៎ះ ប្រព្រឹត្តទៅក្នុងអនាគតទៀតបាន រមែងបានដោយប្រការយ៉ាងនេះ ។ នេះ ជាមូលនៃវិវាទ ៦ ។

[៨៥៥] មូលនៃអនុវាទ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (មូលនៃអនុវាទ ៦ គឺ) ភិក្ខុក្នុងសាសនានេះ ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុណា ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុនោះឈ្មោះថា មិនគោរព មិនឳនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឳនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឳនលំទោនក្នុងព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ។ ភិក្ខុណា

